**សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ**

**របាយការណ៍គ្រប់គ្រង**
**ទាក់ទងនឹងរបាយការណ៍ស៊ើបអង្កេតអនុលោមភាពរបស់ CAO**

**ស្តីពី**

**ធនាគារអេស៊ីលីដា, អម្រឹត, ហត្ថា, ប្រាសាក់, អិលអូអិលស៊ី និងស្ថាបនា**
**កម្ពុជា—អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក**
**(គម្រោងលេខ 21856, 27827, 31467, 34748, 38609, 39167, 41294, 42480, 44211, 44231, 44742, 44882, 45535)**

ថ្ងៃទី 5 ខែកុម្ភៈ ឆ្នាំ 2026

## តារាងមាតិកា

អក្សរកាត់ និងពាក្យកាត់ ..... 2
សេចក្តីសង្ខេបប្រតិបត្តិ ..... 4
I. សេចក្តីផ្តើម ..... 6
II. ការប្តេជ្ញាចិត្តរបស់ WBG ចំពោះបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ..... 7
III. ការវិវត្តនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ..... 10
IV. ការស៊ើបអង្កេតរបស់ CAO ..... 12
V. ការគាំទ្ររបស់ IFC ក្នុងការដោះស្រាយករណីជាក់លាក់របស់ម្ចាស់បណ្តឹង ..... 15
VI. ការគាំទ្ររបស់ IFC ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ..... 18
VII. ការគាំទ្ររបស់ IFC នៅកម្រិតវិស័យ និងកម្រិតនិយ័តកម្ម ..... 19
VIII. កិច្ចសហប្រតិបត្តិការរបស់ IFC ជាមួយដៃគូអភិវឌ្ឍន៍ ..... 23
IX. ការឆ្លើយតបរបស់ IFC ចំពោះលទ្ធផលរកឃើញ និងអនុសាសន៍របស់ស្ថាប័ន CAO ..... 25
X. សេចក្តីសន្និដ្ឋាន ..... 33
ឧបសម្ព័ន្ធ A. ការចូលរួមរបស់ភាគីពាក់ព័ន្ធរបស់ IFC ..... i
ឧបសម្ព័ន្ធ B. ការវិនិយោគរបស់ IFC ដែលស្ថិតក្រោមការស៊ើបអង្កេតរបស់ CAO ..... iii

# អក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| ABC | សមាគមធនាគារនៅកម្ពុជា |
| ACLEDA | ធនាគារអេស៊ីលីដា ភីអិលស៊ី |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AMRET | គ្រឹះស្ថានអម្រឹត ភីអិលស៊ី |
| AS | សេវាប្រឹក្សាយោបល់ |
| BFI | គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ |
| CAFT | សមាគមហិរញ្ញវត្ថុ និងបច្ចេកវិទ្យាកម្ពុជា |
| CAO | ការិយាល័យទីប្រឹក្សាអនុលោមភាព |
| CBC | ការិយាល័យឥណទានកម្ពុជា |
| CCM | យន្តការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ |
| CERISE | Comité d’échange, de réflexion et d’information sur les systèmes d’épargne-crédits |
| CMA | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា |
| CSO | អង្គការសង្គមស៊ីវិល |
| DFI | គ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍ |
| EC | អង្គការសមធម៌កម្ពុជា |
| E&S | បរិស្ថាន និងសង្គម |
| ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច |
| FCC | មជ្ឈមណ្ឌលអ្នកប្រើប្រាស់ហិរញ្ញវត្ថុ |
| FI | អន្តរការីហិរញ្ញវត្ថុ |
| FMO | Financierings-Maatschappij voor Ontwikkelingslanden N.V |
| G20 | ក្រុមប្រទេសទាំងម្ភៃ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GGSF | មូលនិធិយេនឌ័រឆ្លាតវៃសកល |
| GIIP | ការអនុវត្តឧស្សាហកម្មអន្តរជាតិល្អ |
| GRM | យន្តការឆ្លើយតបនឹងបណ្តឹងសាទុក្ខ |
| HKL | ហត្ថាកសិករលីមីតធីត |
| HTB | ធនាគារហត្ថា ភីអិលស៊ី (អតីតហត្ថាកសិករ លីមីតធីត) |
| IBF | វិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ |
| ICLT | ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច |
| IDA | សមាគមអភិវឌ្ឍន៍អន្តរជាតិ |
| IEG | ក្រុមវាយតម្លៃឯករាជ្យ |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) |
| LOLC | អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| MAP | ផែនការសកម្មភាពគ្រប់គ្រង |
| MEF | Microfinance Enhancement Facility S.A., SICAV-SIF |
| MFI | ស្ថាប័នមីក្រូហិរញ្ញវត្ថុ |
| MIFA | Microfinance Initiative for Asia Debt Fund SA. SICAV-SIF |
| MIMOSA | សន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការផ្សព្វផ្សាយ និងតិត្ថិភាពទីផ្សារ |
| MSME | សហគ្រាសធុនមីក្រូ តូច និងមធ្យម |
| NAADR | អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ |
| NBC | ធនាគារជាតិនៃកម្ពុជា |
| PRASAC | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ភីអិលស៊ី ឬ (ធនាគារ ខេប៊ី ប្រាសាក់ ភីអិលស៊ី) |
| Sathapana | ធនាគារស្ថាបនា ភីអិលស៊ី |
| SME | សហគ្រាសធុនតូចនិងមធ្យម |
| SPTF | អង្គការ Social Performance Task Force |
| US$ | ដុល្លារអាមេរិក |
| UN | អង្គការសហប្រជាជាតិ |

| | |
|---|---|
| UNRC | អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ |
| WBG | ក្រុមធនាគារពិភពលោក |

## សេចក្តីសង្ខេបប្រតិបត្តិ

i. សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាផ្នែកមួយនៃក្រុមធនាគារពិភពលោក ប្តេជ្ញាជំរុញបរិយាបន្នហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវទូទាំងពិភពលោក។ បរិយាបន្នហិរញ្ញវត្ថុជំរុញសហគ្រិនភាព កំណើនសេដ្ឋកិច្ច និងការងារ ព្រមទាំងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

ii. IFC បានវិនិយោគនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ 1999។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការផ្តល់ហិរញ្ញប្បទានដោយផ្ទាល់របស់ IFC ក្នុងភាពជាដៃគូជាមួយស្ថាប័នហិរញ្ញវត្ថុអភិវឌ្ឍន៍ដទៃទៀត បានគាំទ្រដល់ការទទួលបានហិរញ្ញប្បទានសម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ប្រមាណ 400,000 ស្ថាប័នជារៀងរាល់ឆ្នាំ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើអាជីវកម្មដែលគ្រប់គ្រងដោយស្ត្រី និងអ្នកខ្ចីប្រាក់ជាលក្ខណៈបុគ្គល។

iii. របាយការណ៍គ្រប់គ្រងនេះ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេតរបស់ការិយាល័យទីប្រឹក្សាអនុលោមភាព (CAO) លើការវិនិយោគផ្ទាល់ និងប្រយោលចំនួន 13 របស់ IFC នៅក្នុងគ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាចំនួនប្រាំមួយ ដែលផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ។ អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន 18 នាក់ដែលជាម្ចាស់បណ្តឹងបានរៀបរាប់ថា ការអនុវត្តការផ្តល់ប្រាក់កម្ចី និងការទារបំណុលបានរួមចំណែកធ្វើឱ្យមានបំណុលលើសលប់ ក៏ដូចជាបង្កផលប៉ះពាល់សង្គមយ៉ាងទូលំទូលាយលើជីវិត និងជីវភាពរស់នៅរបស់ពួកគេ។

iv. ម្ចាស់បណ្តឹងបានបង្ហាញពីស្ថានភាពដ៏ស្មុគស្មាញនៃការលំបាកផ្នែកសេដ្ឋកិច្ច និងវដ្តនៃភាពក្រីក្រពហុវិមាត្រ ដែលមិនមែនកើតចេញពីប្រភពតែមួយនោះទេ។ សក្ខីកម្មរបស់ពួកគេចង្អុលបង្ហាញអំពីចន្លោះប្រហោងនៅក្នុងបទប្បញ្ញត្តិស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ការអប់រំអ្នកប្រើប្រាស់ និងការអនុវត្តហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ព្រមទាំងបញ្ហាប្រឈមផ្សេងទៀតដែលអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកំពុងជួបប្រទះនៅក្នុងប្រទេសកម្ពុជា។ IFC យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះកង្វល់ទាំងនេះ និងដោះស្រាយបញ្ហាទាំងនោះនៅកម្រិតម្ចាស់បណ្តឹង កម្រិតគ្រឹះស្ថានហិរញ្ញវត្ថុ និងកម្រិតវិស័យទាំងមូល ដូចមានចែងលម្អិតនៅក្នុងរបាយការណ៍នេះ។

v. IFC បានព្រមព្រៀងជាមួយម្ចាស់បណ្តឹង និងស្ថាប័នមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនរបស់ខ្លួន ដើម្បីសម្របសម្រួលដល់ការពិនិត្យឡើងវិញ និងការដោះស្រាយករណីរបស់ពួកគេ តាមរយៈយន្តការនានាដែលមាននៅក្នុងប្រទេសកម្ពុជា។ IFC ប្តេជ្ញាគាំទ្រម្ចាស់បណ្តឹងក្នុងការនាំយកកង្វល់របស់ពួកគេទៅកាន់អតិថិជនរបស់ IFC រៀងៗខ្លួន ប្រកបដោយសុវត្ថិភាព និងភាពសម្ងាត់ ឬប្រសិនបើមានបំណង អាចនាំយកទៅកាន់យន្តការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ដែលមាននៅទូទាំងវិស័យទាំងមូល។ IFC នឹងបន្តធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីពង្រឹងយន្តការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់ និងធានាឱ្យមានការអនុលោមទៅតាមការអនុវត្តល្អនៅក្នុងឧស្សាហកម្ម។

vi. ក្នុងការឆ្លើយតបទៅនឹងបណ្តឹងតវ៉ារបស់ CAO ស្ថាប័ន IFC កំពុងចាត់វិធានការសំខាន់ៗជាច្រើន ដើម្បីដោះស្រាយកង្វល់ពាក់ព័ន្ធនឹងការផ្តល់ប្រាក់កម្ចី និងការទារបំណុលទាំងសាហាវ។ IFC បានរៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលដល់អតិថិជនផ្ទាល់ និងអតិថិជនប្រយោល ព្រមទាំងភាគីពាក់ព័ន្ធក្នុងវិស័យនេះ អំពីការផ្តល់ប្រាក់កម្ចី និងការទារបំណុលប្រកបដោយការទទួលខុសត្រូវ ការចាត់ចែងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់ និងការគ្រប់គ្រងហានិភ័យនៃការសងសឹកក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ IFC នឹងពង្រីកវិសាលភាពនៃការផ្តល់ជូនទាំងនេះ ដើម្បីដោះស្រាយផងដែរនូវហានិភ័យនានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីជាទ្រព្យបញ្ចាំ។

vii. នៅកម្រិតវិស័យ IFC កំពុងពង្រឹងបរិយាកាសស្ថាប័ន និងបទប្បញ្ញត្តិសម្រាប់បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់។ នៅក្នុងឆ្នាំ 2009, IFC បានគាំទ្រដល់ការបង្កើតការិយាល័យឥណទានកម្ពុជា ដែលបានណែនាំប្រព័ន្ធរាយការណ៍ឥណទានមជ្ឈការ ដើម្បីលើកកម្ពស់តម្លាភាព ពង្រីកការទទួលបានហិរញ្ញវត្ថុ និងកាត់បន្ថយហានិភ័យនៃបំណុលលើសលប់។

viii. លើសពីនេះទៅទៀត IFC បានសហការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដើម្បីដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ ក្នុងគោលបំណងជួយបង្ការបំណុលលើសលប់ ការពារអ្នកប្រើប្រាស់ និងធ្វើឱ្យនីតិវិធីនៃការផ្តល់កម្ចីមានស្តង់ដាររួមមួយ។ នៅក្នុងឆ្នាំ 2022 ប្រទេសកម្ពុជាបានដាក់ឱ្យប្រើប្រាស់លក្ខខណ្ឌកិច្ចសន្យាស្តង់ដាសម្រាប់ការផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ ដើម្បីសម្របសម្រួលដល់ការអប់រំអ្នកប្រើប្រាស់។

ix. ថ្មីៗបំផុតនេះ IFC បានជួយបង្កើតមជ្ឈមណ្ឌលការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុរបស់កម្ពុជា ដែលបានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅក្នុងខែកក្កដា ឆ្នាំ 2025។ មជ្ឈមណ្ឌលនេះ ផ្តល់នូវយន្តការមជ្ឈការទូទាំងវិស័យសម្រាប់ការដោះស្រាយបណ្តឹង ការផ្តល់ប្រឹក្សា និងការដោះស្រាយវិវាទ ដោយមានលទ្ធភាពផ្តល់សេវាកម្មអ្នកស៊ើបអង្កេតបណ្តឹងហិរញ្ញវត្ថុ នៅដំណាក់កាលបន្ទាប់ ព្រមទាំងបំពេញការងារលើការផ្តល់អំណាចផ្នែកហិរញ្ញវត្ថុ និងអក្ខរកម្មហិរញ្ញវត្ថុផងដែរ។

x. IFC សហការយ៉ាងជិតស្និទ្ធជាមួយសមភាគីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងភាគីដទៃទៀត ដើម្បីដោះស្រាយហានិភ័យនានាពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ។ បច្ចុប្បន្ននេះ IFC កំពុងចូលរួមចំណែកយ៉ាងសកម្មនៅក្នុងគំនិតផ្តួចផ្តើមមួយរបស់អង្គការសហប្រជាជាតិ និងធនាគារជាតិនៃកម្ពុជា ដែលត្រូវបានដាក់ឱ្យដំណើរការក្នុងឆ្នាំ 2023 ក្នុងគោលបំណងពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ ការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវ យន្តការការពារផ្នែកច្បាប់ និងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុសម្រាប់អ្នកខ្ចីប្រាក់នៅតាមជនបទ។

xi. ទោះជាយ៉ាងណាក៏ដោយ IFC មិនយល់ស្របនឹងអំណះអំណាងរបស់ CAO ពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃគោលនយោបាយចីរភាពរបស់ IFC និងស្តង់ដាប្រតិបត្តិការផ្នែកបរិស្ថាន និងសង្គមនោះទេ។ ជំហររបស់ IFC គឺស្របគ្នាទៅនឹងរបាយការណ៍ឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងរបស់ខ្លួននាខែវិច្ឆិកា ឆ្នាំ 2022 ដែលក្នុងនោះ IFC បានបញ្ជាក់ច្បាស់ថា ហានិភ័យ និងផលប៉ះពាល់នានាពាក់ព័ន្ធនឹងការអនុវត្តការផ្តល់ប្រាក់កម្ចី និងការទារបំណុល គឺមិនស្ថិតនៅក្នុងវិសាលភាពនៃក្របខ័ណ្ឌចីរភាពរបស់ IFC នោះឡើយ។ ហេតុដូច្នេះហើយ IFC មិនបង្ហាញផែនការសកម្មភាពគ្រប់គ្រង ដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេតខាងអនុលោមភាពរបស់ CAO នេះទេ។

xii. ទៅថ្ងៃអនាគត ទន្ទឹមនឹងការគាំទ្រដល់ការពិនិត្យឡើងវិញ និងការដោះស្រាយករណីវិវាទរវាងម្ចាស់បណ្តឹង និងអតិថិជនរបស់ IFC, IFC នឹងបន្តជំរុញវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ គាំទ្រដល់កំណែទម្រង់បទប្បញ្ញត្តិ និងកសាងសមត្ថភាពនៅទូទាំងវិស័យទាំងមូល។ តាមរយៈការលើកកម្ពស់ការអនុវត្តល្អៗនៅទូទាំងវិស័យ និងការបន្តកិច្ចសហការជាមួយភាគីពាក់ព័ន្ធ IFC រួមចំណែកដល់ការបង្កើតប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុមួយដែលមានលក្ខណៈកាន់តែបរិយាបន្ន និងមានភាពធន់នៅក្នុងប្រទេសកម្ពុជា។

# I. សេចក្តីផ្តើម

1. នៅថ្ងៃទី 14 ខែតុលា ឆ្នាំ 2025 ការិយាល័យទីប្រឹក្សាអនុលោមភាព (CAO) បានដាក់ជូននូវរបាយការណ៍ស៊ើបអង្កេតរបស់ខ្លួនស្តីពីការវិនិយោគរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៅក្នុងគ្រឹះស្ថានផ្តល់សេវាមីក្រូហិរញ្ញវត្ថុកម្ពុជាចំនួនបី រួមមានធនាគារ អេស៊ីលីដា ភីអិលស៊ី (ACLEDA) គ្រឹះស្ថានអម្រឹត ភីអិលស៊ី (Amret) និងធនាគារហត្ថា ភីអិលស៊ី (HTB) និងអតិថិជនរងចំនួនបីទៀត រួមមានក្រុមហ៊ុនអិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី (LOLC) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ភីអិលស៊ី (បច្ចុប្បន្នជាធនាគារខេប៊ី ប្រាសាក់ ភីអិលស៊ី) និងធនាគារស្ថាបនា ភីអិលស៊ី (Sathapana) តាមរយៈការវិនិយោគដោយមូលនិធិចំនួនបីគឺ Microfinance Enhancement Facility S.A., SICAV-SIF (MEF), Microfinance Initiative for Asia Debt Fund SA. SICAV-SIF (MIFA) និង North Haven Thai Private Equity L.P. (North Haven) ព្រមទាំងក្រុមហ៊ុនគ្រប់គ្រងការវិនិយោគឈ្មោះ Advans SA SICAR (Advans)។ CAO បានអនុវត្តការស៊ើបអង្កេតទូទាំងវិស័យមួយនេះ តាមរយៈការពិនិត្យឡើងវិញលើគម្រោងចំនួន 13 របស់ IFC ដែលបានអនុវត្តចន្លោះឆ្នាំ 2004 និងឆ្នាំ 2021។

2. ការស៊ើបអង្កេតនេះត្រូវបានធ្វើឡើងតាមរយៈបណ្តឹងកាលពីខែកុម្ភៈ ឆ្នាំ 2022 ដែលដាក់ជូនដោយសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (LICADHO) និងអង្គការសមធម៌កម្ពុជា (EC) ដែលជាអង្គការសង្គមស៊ីវិល (CSOs) កម្ពុជាចំនួនពីរ តំណាងឱ្យអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន 18 នាក់ ដោយបានចោទប្រកាន់ថាមានផលប៉ះពាល់អវិជ្ជមានដល់សង្គម ដែលបណ្តាលមកពីការជំពាក់បំណុលរបស់ពួកគេ និងការអនុវត្តការផ្តល់ប្រាក់កម្ចីព្រមទាំងការទារបំណុលរបស់អតិថិជន និងអតិថិជនរងរបស់ IFC។[1]

3. ក្នុងអំឡុងពេលដំណើរការរបស់ CAO ម្ចាស់បណ្តឹងបានបដិសេធមិនចូលរួមពិភាក្សាជាមួយ IFC ឬអតិថិជនរបស់ខ្លួនឡើយ ហេតុដូច្នេះហើយ IFC ទទួលបានព័ត៌មានតិចតួចបំផុត ដើម្បីស្វែងយល់ និងវាយតម្លៃលើផលប៉ះពាល់អវិជ្ជមានដែលត្រូវបានចោទប្រកាន់ទាំងនោះ។[2] មានតែនៅក្នុងខែវិច្ឆិកា ឆ្នាំ 2025 ប៉ុណ្ណោះ ទើប IFC មានលទ្ធភាពជួបជាមួយម្ចាស់បណ្តឹងដោយផ្ទាល់ និងបានស្តាប់រឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេម្នាក់ៗ។ ពួកគេបានរៀបរាប់អំពីការតស៊ូប្រឹងប្រែងដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ រួមទាំងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺ COVID-19 និងព្រឹត្តិការណ៍អាកាសធាតុអាក្រក់នានាផងដែរ។ ពួកគេក៏បានចែករំលែកអំពីបញ្ហាប្រឈមរបស់ពួកគេក្នុងការសងបំណុលវិញ ហើយបានលើកឡើងថា ពួកគេមានអារម្មណ៍ថារងសម្ពាធពីសំណាក់មន្ត្រីឥណទាននៃគ្រឹះស្ថានផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុក្នុងការបង្ខំឱ្យសងបំណុលទាំងនោះ។ ដោយសារតែការខ្វះការយល់ដឹង និងការមិនធ្លាប់ឆ្លងកាត់ការដោះស្រាយកង្វល់របស់ខ្លួនតាមរយៈយន្តការដែលមានស្រាប់នៅក្នុងមូលដ្ឋាន ពួកគេបានស្វាគមន៍ចំពោះសំណើរបស់ IFC ក្នុងការសម្របសម្រួលដល់ការពិនិត្យឡើងវិញ និងការដោះស្រាយករណីរបស់ពួកគេ តាមរយៈយន្តការដោះស្រាយបណ្តឹងអ្នកប្រើប្រាស់ (CCMs) របស់អតិថិជនរៀងៗខ្លួន ប្រកបដោយសុវត្ថិភាព និងភាពសម្ងាត់។

4. របាយការណ៍គ្រប់គ្រងនេះបង្ហាញពីការឆ្លើយតបរបស់ IFC ទៅនឹងការស៊ើបអង្កេតរបស់ CAO។ IFC ទទួលស្គាល់ថា ផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម-សេដ្ឋកិច្ចដែលត្រូវបានរកឃើញក្នុងអំឡុងពេលស៊ើបអង្កេត គឺមានសភាពធ្ងន់ធ្ងរ ហើយក៏យល់ស្របជាមួយ CAO ផងដែរថា បញ្ហាទាំងនេះកើតចេញពីចន្លោះប្រហោងជាប្រព័ន្ធ និងស្ថានភាពសង្គម-សេដ្ឋកិច្ចដ៏ពិសេសនៅក្នុងប្រទេសកម្ពុជា ជាជាងកើតចេញពីកម្ចីមីក្រូហិរញ្ញវត្ថុតែមួយពីសំណាក់អតិថិជនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) ផ្ទាល់ ឬប្រយោលរបស់ IFC។ ម្ចាស់បណ្តឹងបានចែករំលែកអំពីប្រវត្តិនៃការខ្ចីប្រាក់ដ៏ស្មុគស្មាញរបស់ពួកគេក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមក ដែលជារឿយៗពាក់ព័ន្ធនឹងអ្នកផ្តល់កម្ចីក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធជាច្រើន (ដែលមិនមែនទាំងអស់សុទ្ធតែពាក់ព័ន្ធនឹង IFC នោះទេ) ដែលចុងក្រោយបានដឹកនាំឱ្យពួកគេជួបប្រទះនូវផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម-សេដ្ឋកិច្ចទាំងនេះ។ លទ្ធផលរកឃើញរបស់ CAO ទទួលស្គាល់ពីតួនាទីរបស់ IFC និងគូសបញ្ជាក់អំពីតម្រូវការសម្រាប់ក្របខ័ណ្ឌកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុដ៏រឹងមាំ និងក្របខ័ណ្ឌមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។

5. ផ្នែកទី II នៃរបាយការណ៍នេះ រៀបរាប់អំពីការប្តេជ្ញាចិត្តរបស់ក្រុមធនាគារពិភពលោក (WBG) ចំពោះបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ខណៈពេលដែលផ្នែកទី III ផ្តល់នូវទិដ្ឋភាពទូទៅនៃការវិវត្តនៃវិស័យមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ ផ្នែកទី IV រៀបរាប់អំពីដំណើរការរបស់ CAO និង

---

[1] បណ្តឹងឆ្នាំ 2022 នោះ រួមមានម្ចាស់បណ្តឹងចំនួន 19 នាក់ ទោះជាយ៉ាងណាក៏ដោយ ក្នុងអំឡុងពេលដំណើរការរយៈពេលបួនឆ្នាំរបស់ CAO មានម្ចាស់បណ្តឹងម្នាក់បានដាច់ការទាក់ទង។

[2] រហូតមកដល់ពេលនេះ មិនទាន់មានព័ត៌មានណាមួយអំពីម្ចាស់បណ្តឹងត្រូវបានចែករំលែកទៅកាន់ MFI ដែលជាអតិថិជនផ្ទាល់ និងប្រយោលរបស់ IFC នៅឡើយទេ ដែលការណ៍នេះនឹងអាចអនុញ្ញាតឱ្យមានការពិនិត្យឡើងវិញលើដំណើរការពិចារណាផ្តល់ឥណទាន ឬឥរិយាបថរបស់មន្ត្រីឥណទាន ឬការវាយតម្លៃលើការផ្សារភ្ជាប់ណាមួយទៅនឹងផលប៉ះពាល់អវិជ្ជមាននោះ។

បទពិសោធរបស់ម្ចាស់បណ្ដឹង។ ផ្នែក V-VIII បង្ហាញពីរបៀបដែល IFC កំពុងដោះស្រាយបញ្ហានានា និងផលប៉ះពាល់អវិជ្ជមានដែលត្រូវបានលើកឡើងនៅក្នុងការស៊ើបអង្កេតរបស់ CAO រួមទាំងការគាំទ្រដែលបានគ្រោងទុកដើម្បីសម្របសម្រួលដល់ការដោះស្រាយករណីរបស់ម្ចាស់បណ្ដឹង សកម្មភាពជាមួយ MFIs ការងារនៅកម្រិតវិស័យ និងកម្រិតបទប្បញ្ញត្តិ ព្រមទាំងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត។ ផ្នែកទី IX ឆ្លើយតបទៅនឹងលទ្ធផលនៃការរកឃើញ និងអនុសាសន៍របស់ CAO ពាក់ព័ន្ធនឹងគោលនយោបាយចីរភាពរបស់ IFC។

6. ដោយសារតែហានិភ័យ និងផលប៉ះពាល់ពាក់ព័ន្ធទាំងនោះ មិនស្ថិតនៅក្រោមក្របខ័ណ្ឌចីរភាពរបស់ IFC ឡើយ[3] ហេតុដូច្នេះហើយ IFC មិនបង្ហាញផែនការសកម្មភាពគ្រប់គ្រង (MAP) ដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេតខាងអនុលោមភាពនេះទេ។ ផ្ទុយទៅវិញ ផ្នាក់គ្រប់គ្រងពន្យល់អំពីរបៀបដែលសកម្មភាព និងគំនិតផ្ដួចផ្ដើមតាមកម្មវិធីនានារបស់ខ្លួន ដែលកំណត់គោលដៅចំពោះការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងបទប្បញ្ញត្តិនៃកិច្ចការពារអ្នកប្រើប្រាស់នៅកម្ពុជា អាចឆ្លើយតបទៅនឹងបញ្ហានានាដែលត្រូវបានលើកឡើង។

## II. ការប្ដេជ្ញាចិត្តរបស់ WBG ចំពោះបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ

7. WBG ប្ដេជ្ញាចិត្តក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅទូទាំងសកលលោក ដែលនេះជាគ្រឹះដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ច ការបង្កើតការងារ ការបង្កើនអំណាចសេដ្ឋកិច្ចរបស់ស្ត្រី និងការលុបបំបាត់ភាពក្រីក្រ។ បរិយាបន្នហិរញ្ញវត្ថុបានជួយឱ្យបុគ្គល និងអាជីវកម្មនានាអាចទទួលបាននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលមានតម្លៃសមរម្យ និងមានប្រយោជន៍ជាច្រើន រួមមានសេវាទូទាត់ប្រាក់ ការសន្សំ ឥណទាន និងធានារ៉ាប់រង ដែលត្រូវបានរៀបចំឡើងស្របតាមតម្រូវការជាក់លាក់របស់ពួកគេ។[4] ដើម្បីបង្កើនអត្ថប្រយោជន៍របស់ពួកគេជាអតិបរមា ផលិតផល និងសេវាកម្មហិរញ្ញវត្ថុទាំងនោះត្រូវតែត្រូវបានផ្ដល់ជូនប្រកបដោយការទទួលខុសត្រូវ និងមានលក្ខណៈចីរភាព។ កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ គឺជាផ្នែកបំពេញបន្ថែមដ៏សំខាន់មួយដល់បរិយាបន្នហិរញ្ញវត្ថុ ដើម្បីជួយធានាថាអ្នកប្រើប្រាស់ទទួលបានផលប្រយោជន៍ពីសេវាហិរញ្ញវត្ថុ និងមិនប្រឈមនឹងផលប៉ះពាល់អវិជ្ជមានណាមួយឡើយ។

8. WBG ជំរុញបរិយាបន្នហិរញ្ញវត្ថុយ៉ាងសកម្ម តាមរយៈការផ្ដល់ហិរញ្ញប្បទាន និងការផ្ដល់ប្រឹក្សាដល់អ្នករៀបចំគោលនយោបាយក្នុងការអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិឱ្យមានប្រសិទ្ធភាព។ គោលបំណងគឺដើម្បីបង្កើតលក្ខខណ្ឌទីផ្សារ និងការវិនិយោគនានា ដើម្បីបង្កើនអំណាចដល់គ្រួសារដែលមានចំណូលទាប និងសហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ជាពិសេសសហគ្រាសដែលងាយរងគ្រោះដោយសារសម្ពាធពីខាងក្រៅ ឱ្យមានលទ្ធភាពវិនិយោគ គ្រប់គ្រងហានិភ័យ កែលម្អជីវភាពរស់នៅ និងបង្កើតការងារ។ WBG បានធ្វើការជាយូរណាស់មកហើយជាមួយអាជ្ញាធរទីផ្សារដែលទទួលបន្ទុកលើគោលនយោបាយប្រកួតប្រជែង និងកិច្ចការពារអ្នកប្រើប្រាស់ ជាពិសេសនៅក្នុងវិស័យហិរញ្ញវត្ថុ។ ការគាំទ្ររបស់ WBG ផ្ដោតលើការកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិ និងការរៀបចំរចនាសម្ព័ន្ធស្ថាប័ន ព្រមទាំងការពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ 2023 ក្រុមវាយតម្លៃឯករាជ្យ (IEG) របស់ WBG បានរកឃើញថា វិធានការអន្តរាគមន៍ទាំងនោះមានអត្រាជោគជ័យរហូតដល់ 82 ភាគរយ។[5]

9. នៅក្នុងប្រទេសដែលមានចំណូលទាប និងនៅក្នុងស្ថានភាពដែលងាយរងគ្រោះ ឬរងផលប៉ះពាល់ដោយសារជម្លោះ MFIs ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្ដល់សេវាហិរញ្ញវត្ថុដ៏ចាំបាច់ដល់ MSMEs និងបុគ្គលដែលមានចំណូលទាប ដែលជាញឹកញាប់ត្រូវបានផាត់ចេញពីប្រព័ន្ធធនាគារបែបប្រពៃណី។ សម្រាប់គ្រួសារក្រីក្រ មីក្រូហិរញ្ញវត្ថុផ្ដល់ឱកាសក្នុងការវិនិយោគលើមុខរបរចិញ្ចឹមជីវិត គ្រប់គ្រងហានិភ័យដែលកើតឡើងដោយមិនបានរំពឹងទុក និងពង្រឹងសន្តិសុខហិរញ្ញវត្ថុ ដែលជួយឱ្យក្រុមគ្រួសារទាំងនោះអាចកសាងអនាគតមួយដែលមានស្ថិរភាព និងវិបុលភាពជាងមុន។ តាមរយៈការងាររបស់ខ្លួន WBG ខិតខំប្រឹងប្រែងធានាឱ្យបានថា បុគ្គល និងអាជីវកម្មនានាអាចទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងមានលក្ខណៈចីរភាព ដែលជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន។

10. WBG ទទួលស្គាល់ថា ការវិវត្តនៃបរិយាបន្នហិរញ្ញវត្ថុពីវិស័យមិនស្វែងរកប្រាក់ចំណេញ និងគោលនយោបាយសាធារណៈទៅជាវិស័យមួយដែលមានការចូលរួមពីតួអង្គពាណិជ្ជកម្មចម្រុះ និងការរីកចម្រើនយ៉ាងរហ័សតាមរយៈមធ្យោបាយឌីជីថលមានបញ្ហាប្រឈមនានា។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះទាមទារឱ្យមានកំណែទម្រ

---

[3] ក្របខ័ណ្ឌចីរភាពរបស់ IFC (ឆ្នាំ 2012) រួមមាន៖ (i) គោលនយោបាយស្ដីពីចីរភាពបរិស្ថាន និងសង្គម (គោលនយោបាយចីរភាព); (ii) ស្តង់ដារប្រតិបត្តិការស្ដីពីចីរភាពបរិស្ថាន និងសង្គម (ស្តង់ដារប្រតិបត្តិការ) និង (iii) គោលនយោបាយស្ដីពីការទទួលបានព័ត៌មាន។

[4] WBG IEG, 2023, បរិយាបន្នហិរញ្ញវត្ថុ - មេរៀនពីបទពិសោធរបស់ WBG ឆ្នាំសារពើពន្ធ 2014-22, https://ieg.worldbankgroup.org/evaluations/financial-inclusion/overview

[5] Ibid.

ង់បទប្បញ្ញត្តិ និងគោលនយោបាយគ្រប់ជ្រុងជ្រោយ។ WBG ផ្តល់ប្រឹក្សា និងគាំទ្រដល់រដ្ឋាភិបាល ស្ថាប័នរៀបចំបទប្បញ្ញត្តិ និងធនាគារកណ្តាល ក្នុងការបង្កើតក្របខ័ណ្ឌច្បាប់ បទប្បញ្ញត្តិ និងការត្រួតពិនិត្យ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ។ ការងារនេះរួមបញ្ចូលទាំងការជួយដល់អាជ្ញាធរក្នុងការអភិវឌ្ឍ ត្រួតពិនិត្យ និងអនុវត្តវិធានការការពារផ្នែកបទប្បញ្ញត្តិដ៏រឹងមាំ ដែលចាំបាច់ដើម្បីបង្ការការអនុវត្តការផ្តល់ប្រាក់កម្ចី និងការទារបំណុលទាំងសាហាវ និងការបង្កើនការគាំទ្ររបស់ WBG ឱ្យកាន់តែខ្លាំងឡើងនៅក្នុងផ្នែកផ្សេងទៀតនៃកិច្ចការពារអ្នកប្រើប្រាស់ ជាពិសេសផ្នែកដែលពាក់ព័ន្ធនឹងទីផ្សារឌីជីថល។ ការពង្រឹងប្រព័ន្ធអេកូឡូស៊ីមីក្រូហិរញ្ញវត្ថុគឺជាដំណើរការមួយដែលត្រូវវិវត្តជាបន្តបន្ទាប់ ជាពិសេសនៅក្នុងទីផ្សារដែលមានការប្រឈមខ្លាំង និងមិនសូវលូតលាស់ ដូចជាប្រទេសកម្ពុជាជាដើម។ IFC មានការប្តេជ្ញាក្នុងការគាំទ្រដល់ការកែលម្អជាប្រចាំ និងជាបន្តបន្ទាប់នូវប្រព័ន្ធទាំងនេះ។

11. ចាប់តាំងពីការវិនិយោគដំបូងបង្អស់របស់ខ្លួនលើវិស័យមីក្រូហិរញ្ញវត្ថុនាពាក់កណ្តាលទសវត្សរ៍ឆ្នាំ 1990 មក IFC តែងតែដាក់បញ្ចូលវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុទៅជាស្នូលនៃការងារលើបរិយាបន្នហិរញ្ញវត្ថុរបស់ខ្លួន។ វិបត្តិហិរញ្ញវត្ថុសកលឆ្នាំ 2007-2008 និងបញ្ហាប្រឈមជាបន្តបន្ទាប់នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ បានគូសបញ្ជាក់កាន់តែច្បាស់អំពីតម្រូវការចាំបាច់សម្រាប់ការអនុវត្តប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ IFC បានសហការបង្កើតវេទិកាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវក្នុងឆ្នាំ 2009 ជាមួយស្ថាប័នហិរញ្ញប្បទានអភិវឌ្ឍន៍ (DFIs) ដទៃទៀត និងសហគមន៍ភាពជាដៃគូសកលរបស់ក្រុមប្រទេស G20 សម្រាប់បរិយាបន្នហិរញ្ញវត្ថុ ដើម្បីជំរុញឱ្យមានកិច្ចសន្ទនា និងសកម្មភាពនានាក្នុងចំណោមវិស័យឯកជន រដ្ឋាភិបាល អ្នកអនុវត្តផ្ទាល់ អ្នករៀបចំគោលនយោបាយ គ្រូមហាវិទ្យាល័យថ្នាក់ខ្ពស់ និងអង្គការអ្នកប្រើប្រាស់ ដោយមានគោលបំណងដោះស្រាយសំណួរសំខាន់បំផុតក្នុងការបំពេញចន្លោះប្រហោងនៃកិច្ចការពារអ្នកប្រើប្រាស់ ព្រមទាំងលើកកម្ពស់លទ្ធផលសម្រាប់ប្រជាពលរដ្ឋដែលមានចំណូលទាប និងងាយរងគ្រោះ។[6]

12. នៅក្នុងឆ្នាំដដែលនោះ យុទ្ធនាការស្មាត[7]—ដឹកនាំដោយមជ្ឈមណ្ឌលសម្រាប់បរិយាបន្នហិរញ្ញវត្ថុដោយមានការគាំទ្រពី IFC — បានបង្កើតក្រមសីលធម៌ស្ម័គ្រចិត្តមួយ ដែលផ្អែកលើគោលការណ៍ការពារអតិថិជន និងកម្មវិធីផ្តល់វិញ្ញាបនបត្រ ដើម្បីផ្ទៀងផ្ទាត់អនុលោមភាពរបស់គ្រឹះស្ថានហិរញ្ញវត្ថុ។ ឬឡូនេះ គោលការណ៍ការពារអតិថិជន និងកម្មវិធីផ្តល់វិញ្ញាបនបត្រស្ថិតនៅក្រោមការថែទាំគ្រប់គ្រងរបស់ស្ថាប័ន Cerise+SPTF ដែលបានដាក់ឱ្យដំណើរការផែនទីផ្លូវការពារអតិថិជន ក្នុងខែកញ្ញា ឆ្នាំ 2021 ដោយផ្តល់នូវការណែនាំជាក់ស្តែងដល់គ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងការអនុវត្តការការពារអតិថិជនឱ្យបានល្អ។[8] IFC និងស្ថាប័ន DFIs ដទៃទៀត វិនិយោគិនមីក្រូហិរញ្ញវត្ថុបណ្តាញ និងសមាគមនានាបានបញ្ជ្រាបការអនុវត្តល្អៗនៅក្នុងឧស្សាហកម្មដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយទាំងនេះ ទៅក្នុងដំណើរការវិនិយោគមីក្រូហិរញ្ញវត្ថុរបស់ពួកគេ។ IFC នៅតែបន្តសហការជាមួយ Cerise+SPTF ដើម្បីបន្តគំនិតផ្តួចផ្តើមនានាក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងការអនុវត្តវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។

---

[6] សម្រាប់ព័ត៌មានសារគារស្តីពីវេទិកាហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ សូមចូលទៅកាន់គេហទំព័រ https://globalrff.org/history-of-rff

[7] Smart Campaign គឺជាគំនិតផ្តួចផ្តើមសកលមួយ ដើម្បីបង្កើតបរិយាកាសមួយដែលសេវាកម្មហិរញ្ញវត្ថុត្រូវបានផ្តល់ជូនប្រកបដោយសុវត្ថិភាព និងការទទួលខុសត្រូវ។ យុទ្ធនាការនេះបានបង្កើតគោលការណ៍ការពារអតិថិជន ដែលជាស្តង់ដាកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុសកលដំបូងគេបង្អស់ និងបានបង្កើតកម្មវិធីផ្តល់វិញ្ញាបនបត្រដ៏តឹងរ៉ឹងមួយ ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តប្រកបដោយការទទួលខុសត្រូវដោយអ្នកផ្តល់សេវាហិរញ្ញវត្ថុ។ Smart Campaign បានផ្ទេរកម្មវិធីផ្តល់វិញ្ញាបនបត្រ និងស្តង់ដាការពារអតិថិជនទៅឱ្យ Cerise+SPTF នៅក្នុងឆ្នាំ 2020។ នៅក្នុងខែកញ្ញា ឆ្នាំ 2021, Cerise+SPTF បានដាក់ឱ្យដំណើរការផែនទីផ្លូវការពារអតិថិជនដែលជាគំនិតផ្តួចផ្តើមដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីគាំទ្រដល់ការអនុវត្តយន្តការការពារអតិថិជន។

[8] បន្ថែមពីលើស្តង់ដា និងផែនទីផ្លូវការពារអតិថិជន Cerise+SPTF ក៏កំពុងលើកកម្ពស់ស្តង់ដាសម្រាប់សេវាហិរញ្ញវត្ថុឌីជីថលផងដែរ។ ចាប់តាំងពីឆ្នាំ 2022 មក គំនិតផ្តួចផ្តើមនេះក៏បានគស្ស៊ូមតិសម្រាប់ស្តង់ដាសកលនៃការគ្រប់គ្រងប្រតិបត្តិការផ្នែកសង្គម និងបរិស្ថានផងដែរ។ ស្តង់ដាទាំងនោះមិនស្របគ្នាទៅនឹងក្របខ័ណ្ឌចីរភាពរបស់ IFC និងគោលការណ៍អេក្វាទ័រ (Equator Principles) នោះឡើយ។

13. វិធីសាស្ត្ររបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ គឺចាប់ផ្តើមដំបូងចេញពីការជ្រើសរើសស្ថាប័នជាដៃគូរបស់ខ្លួន ដែលផ្តែកលើចក្ខុវិស័យរួមគ្នាមួយស្តីពីហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។ IFC វិនិយោគលើ MFIs ណាដែលបង្ហាញពីការប្តេជ្ញាចិត្តចំពោះការអនុវត្តល្អនៅក្នុងឧស្សាហកម្ម និងគ្រឹះស្ថានណាដែលស្វែងរកការកែលម្អជាបន្តបន្ទាប់ពាក់ព័ន្ធនឹងចំណុចនេះ។ IFC បញ្ជាក់ពីភស្តុតាងនៃការប្តេជ្ញាចិត្តនេះ តាមរយៈការពិនិត្យឡើងវិញលើប្រព័ន្ធអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធធនធានមនុស្សរបស់ MFI ក៏ដូចជាកំណត់ត្រាតាមដានការផ្តល់ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវរបស់ខ្លួននៅក្នុងទីផ្សារផងដែរ។ លើសពីនេះ IFC ក៏បញ្ជាក់ផងដែរថា គោលការណ៍ការពារអតិថិជនត្រូវបានបញ្ចូលទៅក្នុងគោលនយោបាយ និងនីតិវិធីរបស់ MFI ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ៖ (i) អនុលោមភាពតាមបទប្បញ្ញត្តិមូលដ្ឋានស្តីពីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ និង (ii) គោលនយោបាយព្រមទាំងការអនុវត្តនានាពាក់ព័ន្ធនឹងការរចនា និងការផ្តល់ផលិតផល ការបង្ការបំណុលលើសលប់ តម្លាភាពនិងការកំណត់តម្លៃប្រកបដោយការទទួលខុសត្រូវ ការអនុវត្តការផ្តល់ប្រាក់កម្ចីនិងការទារបំណុល គោលនយោបាយទ្រព្យបញ្ចាំ ឯកជនភាពទិន្នន័យ និងយន្តការដោះស្រាយបណ្តឹងតវ៉ារបស់អតិថិជន។

14. សំណុំឯកសារកម្ចីគំរូ ត្រូវបានយកមកពិនិត្យឡើងវិញ ដើម្បីពិនិត្យភាពស៊ីចង្វាក់គ្នារវាងគោលនយោបាយដែលមានស្រាប់ និងការអនុវត្តជាក់ស្តែង។ IFC ក៏បញ្ចូលការព្រមព្រៀងជាវិជ្ជមានដែលស្របតាមគោលការណ៍ការពារអតិថិជនទៅក្នុងកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានរបស់ខ្លួនជាមួយអតិថិជនពាក់ព័ន្ធផងដែរ។ កិច្ចប្រឹងប្រែងទាំងនេះ មានគោលបំណងតម្រែតម្រង់ទិសដៅនៃគោលនយោបាយ និងការអនុវត្តរបស់អតិថិជនឱ្យស្របទៅនឹងវិធីសាស្ត្ររបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ដោយធានាថាការអនុវត្តល្អជាអន្តរជាតិត្រូវបានយកមកអនុវត្ត និងរក្សាបានពេញមួយវដ្តនៃការវិនិយោគរបស់ IFC។ តាមរយៈគម្រោងផ្តល់ប្រឹក្សា IFC ជួយពង្រឹងបន្ថែមទៀតនូវវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ទាំងនៅកម្រិតវិស័យទាំងមូល និងជាមួយអតិថិជនជាដៃគូរបស់ខ្លួននៅទូទាំងសកលលោក។

15. បន្ទាប់ពីការវិនិយោគ IFC ពិនិត្យតាមដានលើការបន្តអនុវត្តកាតព្វកិច្ចរបស់ MFI ក្រោមគម្រោងកិច្ចព្រមព្រៀងគតិយុត្ត តាមរយៈការរួមបញ្ចូលគ្នារវាងការមើលខុសត្រូវ និងការកំណត់ស្តង់ដាទីផ្សារ។ IFC ធ្វើការពិនិត្យឡើងវិញលើប្រតិបត្តិការជាទៀងទាត់ រួមទាំងការចុះទៅពិនិត្យផ្ទាល់ដល់ទីកន្លែងជាប្រចាំឆ្នាំ និងការសម្ភាសន៍ជាមួយថ្នាក់គ្រប់គ្រងព្រមទាំងបុគ្គលិក ដើម្បីវាយតម្លៃការអនុវត្តការងារប្រចាំថ្ងៃ និងប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង។ នៅពេលដែលបញ្ហានានាត្រូវបានរកឃើញ ស្ថាប័ននោះត្រូវបានតម្រូវឱ្យធ្វើការស៊ើបអង្កេត ហើយក្នុងករណីចាំបាច់ ត្រូវអនុវត្តវិធានការកែតម្រូវ។[9] IFC ចូលរួមជាមួយអតិថិជនតាំងពីដំណាក់កាលដំបូង និងប្រកបដោយភាពបុរេសកម្មដើម្បីដោះស្រាយកង្វល់ និងបញ្ហានានា កាត់បន្ថយហានិភ័យ និងកែលម្អលទ្ធផលនៃគម្រោង។

16. IFC ទទួលស្គាល់ថា សូម្បីតែក្របខ័ណ្ឌកិច្ចការពារអ្នកប្រើប្រាស់ដែលរឹងមាំបំផុត ក៏មិនអាចលុបបំបាត់ទាំងស្រុងនូវហានិភ័យនៃគម្លាតខុសឆ្គងនៅក្នុងករណីបុគ្គលម្នាក់ៗបានដែរ ជាពិសេសដោយសារទំហំនៃប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងចំនួនដ៏ច្រើនលើសលប់នៃកម្ចី។ ទោះបីជាមានការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពយ៉ាងណាក៏ដោយ ក៏អ្នកខ្ចីប្រាក់មួយចំនួននៅតែអាចធ្លាក់ចូលទៅក្នុងស្ថានភាពជំពាក់បំណុលលើសលប់ ឬប្រឈមមុខនឹងកាលៈទេសៈនានាដែលធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពសងបំណុលរបស់ពួកគេដដែល។ នៅក្នុងបរិបទនេះ អាទិភាពរបស់ IFC គឺផ្តោតលើការធានាឱ្យបានថា ប្រព័ន្ធ ការលើកទឹកចិត្ត និងការរៀបចំអភិបាលកិច្ចសមស្រប ត្រូវបានដាក់ចេញ និងដំណើរការប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហានានានៅពេលដែលវាកើតឡើង។

17. ទោះបីជាហានិភ័យដែលមានស្រាប់ និងបញ្ហាប្រឈមនានាដែលត្រូវបានកត់ត្រាទុកជាឯកសារយ៉ាងច្បាស់លាស់នៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ IFC បានសម្រេចចិត្តដោយដឹងខ្លួនក្នុងការបន្តចូលរួមដោយមានការជ្រើសរើសយ៉ាងសម្រិតសម្រាំង នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា ដោយការទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់វិស័យនេះក្នុងការផ្តល់លទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់អ្នកខ្ចីប្រាក់ដែលមានចំណូលទាប ដែលភាគច្រើននៃពួកគេគឺជាសហគ្រិនខ្នាតមីក្រូ។ ការគាំទ្រជាបន្តបន្ទាប់ ជាពិសេសក្នុងអំឡុងពេលមានសម្ពាធសេដ្ឋកិច្ច ដូចជាការរីករាលដាលនៃជំងឺ COVID-19 គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការទ្រទ្រង់មុខរបរចិញ្ចឹមជីវិត និងសកម្មភាពសេដ្ឋកិច្ច ព្រមទាំងធ្វើការងារជាមួយគ្រឹះស្ថានដែលមានការទទួលខុសត្រូវ ក្នុងគោលបំណងពង្រឹងស្តង់ដាឧស្សាហកម្ម និងកាត់បន្ថយហានិភ័យចំពោះអ្នកខ្ចីប្រាក់។

[9] IFC កត់សម្គាល់ឃើញថា ករណីរបស់ម្ចាស់បណ្តឹងទាំង 18 នាក់នោះ រហូតមកដល់ពេលនេះ មិនទាន់ត្រូវបានចែករំលែកទៅកាន់អតិថិជនរបស់ IFC នៅឡើយទេ ហេតុដូច្នេះហើយ នីតិវិធីនៃការពិចារណាផ្តល់ឥណទាន និងការទារបំណុលមិនទាន់អាចយកមកពិនិត្យឡើងវិញបានទេ ហើយក៏មិនទាន់អាចវាយតម្លៃលើផលប៉ះពាល់អវិជ្ជមានណាមួយដែលពាក់ព័ន្ធបានដែរ។

18. ការអនុវត្តរបស់ WBG នៅតែបន្តវិវត្ត និងកែលម្អជាលំដាប់។ ថ្មីៗបំផុតនេះ ការងារលើបរិយាបន្នហិរញ្ញវត្ថុរបស់ខ្លួន ត្រូវបានពង្រឹងបន្ថែមទៀត បន្ទាប់ពីមានការពិនិត្យឡើងវិញក្នុងឆ្នាំ 2023 ដោយ IEG[10] របស់ WBG ហើយបច្ចុប្បន្ន ការងារនេះបានគ្របដណ្តប់លើអ្នកផ្តល់សេវាហិរញ្ញវត្ថុដ៏សម្បូរបែប និងកំពុងពង្រីកវិសាលភាពកាន់តែធំ រួមមានធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ អ្នកផ្តល់ឥណទានអ្នកប្រើប្រាស់ និងក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) ដែលបម្រើសេវាដល់អតិថិជនដែលមានចំណូលទាប។ កត្តានេះ បានធ្វើឱ្យប្រជាពលរដ្ឋកាន់តែច្រើនឡើងទទួលបានសេវាហិរញ្ញវត្ថុផ្លូវការ។ ទោះជាយ៉ាងណាក៏ដោយ ការពង្រីកវិសាលភាពនៃសេវាហិរញ្ញវត្ថុឌីជីថលបានធ្វើឱ្យហានិភ័យដែលមានស្រាប់ចំពោះអ្នកប្រើប្រាស់កាន់តែធ្ងន់ធ្ងរឡើង ព្រមទាំងបានបង្កើតឱ្យមានហានិភ័យថ្មីៗបន្ថែមទៀតផងដែរ។ សម្រាប់ចំណែករបស់ខ្លួន IFC កំពុងលើកកម្ពស់វិធីសាស្ត្ររបស់ខ្លួនចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ តាមរយៈនីតិវិធីដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់ការពិនិត្យផ្ទៀងផ្ទាត់ និងមើលខុសត្រូវដោយហ្មត់ចត់លើគម្រោង ព្រមទាំងការបង្កើនលក្ខខណ្ឌតម្រូវផ្នែកច្បាប់ និងការរាយការណ៍ ដើម្បីពង្រឹងការតាមដានត្រួតពិនិត្យ និងគណនេយ្យភាព (សូមមើលផ្នែកទី IX ផងដែរ)។

19. ការអង្កេតចុងក្រោយបង្អស់របស់ WBG ស្តីពីបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់បង្ហាញថា ដែនសមត្ថកិច្ចដែលបានផ្តល់ការឆ្លើយតបជាង 97 ភាគរយ មានក្របខ័ណ្ឌផ្លូវច្បាប់ទម្រង់ណាមួយសម្រាប់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ។ នេះគឺជាជំហានវិជ្ជមានមួយ ប៉ុន្តែ WBG សង្កត់ធ្ងន់ថា ក្របខ័ណ្ឌទាំងឡាយត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចបត់បែនបាន ដើម្បីគ្របដណ្តប់លើរាល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុទាំងអស់ក្នុងចំណោមការវិវត្តជាបន្តបន្ទាប់នៃវិស័យនេះ។ ខណៈពេលដែលស្វ័យនិយ័តកម្មឧស្សាហកម្មអាចជួយបំពេញចន្លោះប្រហោងផ្នែកបទប្បញ្ញត្តិបានមួយគ្រា ប៉ុន្តែវាមិនអាចជំនួសឱ្យបទប្បញ្ញត្តិកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុបានឡើយ។ កិច្ចសហការជាបន្តបន្ទាប់នៅទូទាំង WBG នៅតែមានសារៈសំខាន់ណាស់ក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព កាត់បន្ថយហានិភ័យ និងបង្ការផលប៉ះពាល់អវិជ្ជមានដល់សង្គម ជាពិសេសសម្រាប់អ្នកប្រើប្រាស់ដែលងាយរងគ្រោះ។

## III. ការវិវត្តនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា

20. គ្រួសារក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា ប្រឈមមុខនឹងបញ្ហាប្រឈមពហុវិមាត្រ ក្នុងការចាកចេញពីភាពក្រីក្រ។ គ្រួសារជាច្រើនពឹងផ្អែកលើការងារក្រៅប្រព័ន្ធ ឬការងារដែលទទួលបានប្រាក់កម្រៃទាបនៅក្នុងវិស័យកសិកម្ម កាត់ដេរ សំណង់ ឬការធ្វើចំណាកស្រុកឆ្លងដែន ដែលកត្តាទាំងនេះធ្វើឱ្យចំណូលរបស់ពួកគេងាយរងគ្រោះខ្លាំងដោយសារសម្ពាធនៃតម្លៃទំនិញ ព្រឹត្តិការណ៍អាកាសធាតុមិនអំណោយផល និងការប្រែប្រួលនៃតម្រូវការសកល។ ការកើនឡើងនៃតម្លៃម្ហូបអាហារ ថាមពល សេវាថែទាំសុខភាព និងការអប់រំ បាននិងកំពុងបង្កើតសម្ពាធកាន់តែខ្លាំងដល់ថវិកាគ្រួសារ ខណៈពេលដែលលទ្ធភាពទទួលបានសេវាសាធារណៈនៅមានកម្រិត បានបង្ខំឱ្យក្រុមគ្រួសារទាំងនោះត្រូវពឹងផ្អែកលើការចំណាយដោយផ្ទាល់ពីហោប៉ៅ និងការខ្ចីប្រាក់ដើម្បីបំពេញតម្រូវការមូលដ្ឋាន។ នៅពេលដែលត្រូវបានផ្តល់ជូនប្រកបដោយចីរភាព និងការទទួលខុសត្រូវ មីក្រូហិរញ្ញវត្ថុអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងបរិបទបែបនេះ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុដ៏ចាំបាច់។

21. ចាប់តាំងពីប្រទេសកម្ពុជាបានចាកចេញពីដំណាក់កាលជម្លោះក្នុងទសវត្សរ៍ឆ្នាំ 1990 មក វិស័យមីក្រូហិរញ្ញវត្ថុបានជួយកសាងវិស័យហិរញ្ញវត្ថុរបស់ប្រទេសឡើងវិញ ដោយបានចូលរួមកាត់បន្ថយភាពក្រីក្រ ទ្រទ្រង់មុខរបរចិញ្ចឹមជីវិត និងបង្កើតឱកាសការងារ។ នៅក្នុងឆ្នាំខ្លះ ចំនួនស្ត្រីមានរហូតដល់ទៅ 80 ភាគរយនៃចំនួនអតិថិជនមីក្រូហិរញ្ញវត្ថុទាំងអស់ ដែលនេះបានគូសបញ្ជាក់ពីការរួមចំណែករបស់វិស័យនេះ ដល់បរិយាបន្នហិរញ្ញវត្ថុ និងការចូលរួមរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា។[11]

22. កំណើននៅក្នុងវិស័យហិរញ្ញវត្ថុរបស់កម្ពុជា ត្រូវបានជំរុញដោយក្របខ័ណ្ឌបទប្បញ្ញត្តិដែលផ្តល់ការគាំទ្រ បរិយាកាសសេដ្ឋកិច្ចវិជ្ជមានចន្លោះឆ្នាំ 2000 និងឆ្នាំ 2019 ព្រមទាំងលំហូរចូលនៃការវិនិយោគពីបរទេស។ ធនាគារជាតិនៃកម្ពុជា (NBC) ដែលជាធនាគារកណ្តាលរបស់ប្រទេស បានដាក់ចេញនូវបទប្បញ្ញនានាដែលអនុញ្ញាតឱ្យ MFIs ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចប្រមូលប្រាក់បញ្ញើបាន ដែលនេះបានជួយឱ្យពួកគេធ្វើពិពិធកម្មប្រភពមូលនិធិលើសពីទុនបរទេស។ កំណើនសេដ្ឋកិច្ចជាតិយ៉ាងរហ័ស (គិតជាមធ្យមលើសពី 7-8 ភាគរយជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ 2000 ដល់ឆ្នាំ 2019) បានផ្តល់នូវកាលានុវត្តភាពយ៉ាងល្អសម្រាប់ការពង្រីកកម្ចី ដែលស្របគ្នាទៅ

[10] WBG IEG, 2023, បរិយាបន្នហិរញ្ញវត្ថុ, មេរៀនពីបទពិសោធរបស់ក្រុមធនាគារពិភពលោក, ឆ្នាំសារពើពន្ធ 2014-22, https://ieg.worldbankgroup.org/evaluations/financial-inclusion
[11] ធនាគារជាតិនៃកម្ពុជា, 2017, បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា៖ បញ្ហា និងបញ្ហាប្រឈម https://www.imf.org/-/media/files/news/seminars/2017/cambodia-seminar-2017-oap/session-iv1-khou-vouthy.pdf?utm_source=chatgpt.com

នឹងការថយចុះនៃអត្រាភាពក្រីក្រផ្លូវការ ដែលកត្តានេះបានលើកទឹកចិត្តដល់ការវិនិយោគបន្ថែមនៅក្នុងវិស័យនេះ។

23. វិស័យមីក្រូហិរញ្ញវត្ថុ ដែលធ្លាប់តែត្រូវបានជំរុញភាគច្រើនដោយអង្គការមិនមែនរដ្ឋាភិបាលនោះ បានប្រែក្លាយទៅជាឧស្សាហកម្មហិរញ្ញវត្ថុបែបពាណិជ្ជកម្មដ៏សំខាន់មួយ និងកំពុងមានការរីកចម្រើនយ៉ាងខ្លាំងក្លា ដោយកើនឡើងពី MFIs ចំនួន 16 ស្ថាប័នក្នុងឆ្នាំ 2005 រហូតដល់ 89 ស្ថាប័នក្នុងឆ្នាំ 2024។[12] លើសពីនេះទៅទៀត ក៏មានធនាគារ និងប្រតិបត្តិករឥណទានជនបទជាច្រើន ក៏ដូចជាអ្នកផ្តល់កម្ចីក្រៅប្រព័ន្ធ និងមិនមានការគ្រប់គ្រងស្របច្បាប់ផងដែរ។ ចំនួនអ្នកខ្ចីប្រាក់បានកើនឡើងយ៉ាងគំហុក គឺពីប្រមាណ377,505 នាក់ក្នុងឆ្នាំ 2005 ដល់ 1.47 លាននាក់ក្នុងឆ្នាំ 2024។[13] ក្នុងអំឡុងពេលនេះ ការផ្តល់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុបានផ្លាស់ប្តូរពីទម្រង់ដើម ដែលជាកម្ចីជាក្រុមមិនមានទ្រព្យបញ្ចាំ ដែលការសងប្រាក់ត្រូវបានលើកទឹកចិត្តតាមរយៈការទទួលខុសត្រូវរួមគ្នា ទៅជាកម្ចីជាលក្ខណៈបុគ្គលដែលមានទ្រព្យបញ្ចាំវិញ។ ទម្រង់ទូទៅបំផុតនៃទ្រព្យបញ្ចាំគឺប័ណ្ណកម្មសិទ្ធិដី។

24. នៅក្នុងប្រទេសកម្ពុជា ភាពជាម្ចាស់ដីធ្លីមានលក្ខណៈទូលំទូលាយ ដែលផ្តល់អំណាចដល់ក្រុមប្រជាជនក្រីក្រ និងងាយរងគ្រោះ។ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីដែលមាន "ប្លង់ទន់" ធ្វើជាទ្រព្យបញ្ចាំបាន ដែលប្លង់ទន់នេះតំណាងឱ្យសិទ្ធិកាន់កាប់ជាជាងសិទ្ធិកម្មសិទ្ធិស្របច្បាប់ពេញលេញ ហើយវាត្រូវបានប្រើប្រាស់ជាទូទៅដោយសារតែចំណាយទាប និងមាននីតិវិធីផ្ទេរសិទ្ធិងាយស្រួលជាង ដែលចៀសវាងការបង់ពន្ធផ្ទេរសិទ្ធិថ្នាក់ជាតិ។ ផ្ទុយទៅវិញ "ប្លង់រឹង" គឺជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលបានចុះបញ្ជីថ្នាក់ជាតិ ដែលផ្តល់នូវសុវត្ថិភាពគតិយុត្តកម្រិតខ្ពស់បំផុត ប៉ុន្តែទាមទារដំណើរការផ្ទេរសិទ្ធិយូរជាង និងត្រូវជាប់កាតព្វកិច្ចបង់ពន្ធផ្ទេរសិទ្ធិចំនួន 4 ភាគរយជាដាច់ខាត។ លក្ខណៈនៃប្លង់ទន់ធ្វើឱ្យមានការលំបាកក្នុងការផ្ទៀងផ្ទាត់ និងងាយនឹងកើតមានជម្លោះ ជាពិសេសនៅពេលមានការជាន់គ្នាជាមួយនឹងប័ណ្ណកម្មសិទ្ធិដីឯកជន ដីសាធារណៈ ឬដីសហគមន៍ រួមទាំងប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិច (ICLTs) ផងដែរ។

25. អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចប្រើប្រាស់បានទាំងប្លង់ទន់ និងប្លង់រឹង ធ្វើជាទ្រព្យបញ្ចាំដីធ្លី។ ស្រដៀងគ្នានឹងបណ្តាប្រទេសដទៃទៀតដែរ ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្វើជាទ្រព្យបញ្ចាំអាចទទួលបានទំហំឥណទានធំជាង អាត្រាការប្រាក់ទាបជាង និងរយៈពេលសងប្រាក់វែងជាង បើប្រៀបធៀបទៅនឹងកម្ចីដែលគ្មានទ្រព្យធានា។ ការផ្លាស់ប្តូរទៅរកការផ្តល់កម្ចីបុគ្គលដែលមានទ្រព្យបញ្ចាំ រួមផ្សំនឹងកត្តាទីផ្សារផ្សេងៗទៀត (ឧ. តម្លៃដីធ្លីកើនឡើង កម្រិតអត្រាការប្រាក់ ការប្រកួតប្រជែង និងការធ្លាក់ចុះសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរាតត្បាត) បានបណ្តាលឱ្យទំហំកម្ចីជាមធ្យមមានការកើនឡើងយ៉ាងខ្លាំង ដោយបានឈានដល់សមមូលជាង $5,162 ដុល្លារអាមេរិក គិតត្រឹមឆ្នាំ 2024 ដែលចំនួននេះមានទំហំច្រើនជាងបួនដងនៃចំណូលមធ្យមប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ៗនៅក្នុងប្រទេស។

26. ការសិក្សាមួយរបស់ធនាគារពិភពលោកក្នុងឆ្នាំ 2019 បានរកឃើញថា កំណើននៃមីក្រូឥណទានមានផលប៉ះពាល់វិជ្ជមានផ្នែកហិរញ្ញវត្ថុ និងសុខុមាលភាពសម្រាប់គ្រួសារនៅក្នុងប្រទេសកម្ពុជា។ ចំណែករបស់គ្រួសារដែលបានខ្ចីប្រាក់ពីប្រភពឥណទានផ្លូវការ បានកើនឡើងរហូតដល់បួនដងក្នុងអំឡុងឆ្នាំ 2004–2016។ ការផ្លាស់ប្តូរនេះបានបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ ក៏ដូចជាទទួលបានកម្ចីដែលមានរយៈពេលវែងជាងមុន និងមានអត្រាការប្រាក់មានប្រសិទ្ធភាពទាបជាងមុន សម្រាប់ផ្នែកនានានៃប្រជាជនដែលពីមុនធ្លាប់តែពឹងផ្អែកលើអ្នកផ្តល់កម្ចីក្រៅប្រព័ន្ធ ក៏ដូចជាអ្នកផ្តល់កម្ចីដែលគ្មានការគ្រប់គ្រងស្របច្បាប់។[14]

27. ការសិក្សាស្រាវជ្រាវជាច្រើនក្នុងអំឡុងពេលនោះ ក៏បានបង្កើតឱ្យមានការយល់ដឹងអំពីហានិភ័យកាន់តែខ្លាំងឡើងផ្នែកកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅក្នុងវិស័យនេះផងដែរ។ របាយការណ៍ទាំងនោះរួមមាន របាយការណ៍សន្ទស្សន៍មីក្រូហិរញ្ញវត្ថុនៃការផ្សព្វផ្សាយ និងតិត្ថិភាពទីផ្សារ (MIMOSA) ឆ្នាំ 2015 និង 2019, របាយការណ៍របស់ IFC ឆ្នាំ 2015 ស្តីពីការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា និងលិខិតគោលនយោបាយ

---

[12] របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ 2005 និង 2024 ចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា៖ https://www.nbc.gov.kh/english/publications/supervision_annual_reports.php?page=2, https://www.nbc.gov.kh/english/publications/supervision_annual_reports.php?page=1

[13] របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ 2005 ចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា៖ https://www.nbc.gov.kh/english/publications/supervision_annual_reports.php?page=2 និងរបាយការណ៍ប្រចាំឆ្នាំ CMA ឆ្នាំ 2024៖ https://www.cma-network.org/annual-reports

[14] Pimhidzai, Obert; Tong, Kimsun; Anantavrasilpa, Ratchada; Popovic, Andrej; Mel, Sokim; Sanchez Martin, Miguel Eduardo, 2019។ *មីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារ។ លិខិតគោលនយោបាយកម្ពុជា។ វ៉ាស៊ីនតោនឌីស៊ី៖ ក្រុមធនាគារពិភពលោក។*

របស់ WBG ឆ្នាំ 2019 ស្តីពីមីក្រូហិរញ្ញវត្ថុ និងសុខុមាលភាពគ្រួសារនៅកម្ពុជា។[15]

28. ជំងឺរាតត្បាត COVID-19 បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរលើប្រទេសកម្ពុជា ដោយបានបណ្ដាលឱ្យមានការធ្លាក់ចុះសេដ្ឋកិច្ចលើកដំបូងបង្អស់ក្នុងរយៈពេល 25 ឆ្នាំចុងក្រោយនេះ។ នៅក្នុងឆ្នាំ 2020 សេដ្ឋកិច្ចបានធ្លាក់ចុះ 3.6 ភាគរយ ហើយវិស័យគន្លឹះៗ ដូចជាវិស័យកាត់ដេរ ទេសចរណ៍ និងអចលនទ្រព្យត្រូវបានរអាក់រអួល។ វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលផ្ដល់ការងារដល់កម្លាំងពលកម្មប្រមាណ 93 ភាគរយ ត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយសារការកើនឡើងនៃអត្រាគ្មានការងារធ្វើ និងប្រាក់ចំណូលធ្លាក់ចុះ ជាពិសេសក្នុងចំណោមស្ត្រីនៅក្នុងវិស័យកាត់ដេរ។ ព្រឹត្តិការណ៍អាកាសធាតុអាក្រក់ ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ ក៏បានជះឥទ្ធិពលដល់ទិន្នផលកសិកម្ម និងសន្តិសុខស្បៀងផងដែរ។ ដោយសារបណ្ដាញសុវត្ថិភាពសង្គមនៅមានកម្រិតទាប បុគ្គលជាច្រើនបាន សម្រេចចិត្តខ្ចីប្រាក់ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដើម្បីបំពេញតម្រូវការចាំបាច់។ សេដ្ឋកិច្ចបាននឹងកំពុងជួបការលំបាកក្នុងការស្តារឡើងវិញឱ្យឈានទៅដល់កម្រិតកំណើនដូចកាលពីមុនពេលមានជំងឺរាតត្បាត។ កម្ចីមិនដំណើរការបាននឹងកំពុងកើនឡើង ហើយប្រទេសជាតិកំពុងប្រឈមមុខនឹងហានិភ័យកើនឡើងខ្ពស់មួយចំនួន រួមទាំងជម្លោះព្រំដែនជាមួយប្រទេសថៃ ដែលបានឆាបឆេះឡើងវិញនៅក្នុងខែកក្កដា ឆ្នាំ 2025 និងបានបណ្ដាលឱ្យមានការវិលត្រឡប់មកវិញនៃពលករចំណាកស្រុកអត់ការងារធ្វើចំនួនមួយលាននាក់ផងដែរ។[16]

29. ដោយទទួលស្គាល់ទាំងផលប៉ះពាល់លើការអភិវឌ្ឍ និងបញ្ហាប្រឈមនានានៅក្នុងវិស័យនេះក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ IFC បានសម្រេចចិត្តយ៉ាងដោយគិតគូរក្នុងការបន្តចូលរួមនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដោយធ្វើការជាមួយអតិថិជនដែលជ្រើសរើស និងគាំទ្រដល់ការផ្លាស់ប្ដូរគោលនយោបាយ ផ្លូវច្បាប់ និងបទប្បញ្ញត្តិ ព្រមទាំងស្ថាប័នកែទម្រង់នៅក្នុងប្រទេសកម្ពុជា ដែលជាប្រទេសជាសមាជិកនៃសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA)។

## IV. ការស៊ើបអង្កេតរបស់ CAO

30. នៅក្នុងខែកុម្ភៈ ឆ្នាំ 2022, CAO បានជូនដំណឹងដល់ IFC ថា មានពាក្យបណ្តឹងមួយត្រូវបានដាក់ដោយអង្គការ CSOs ក្នុងស្រុកចំនួនពីរ គឺអង្គការលីកាដូ (LICADHO) និងអង្គការសមធម៌កម្ពុជា (EC) ក្នុងនាមជាតំណាងឱ្យអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។[17] ដោយសារតែកង្វល់អំពីការរក្សាការសម្ងាត់ IFC ទើបតែបានដឹងនៅក្នុងខែមិថុនា ឆ្នាំ 2025 ប៉ុណ្ណោះថា ម្ចាស់បណ្តឹងគឺជាបុគ្គលចំនួន 18 នាក់ មកពីតំបន់ផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមម្ចាស់បណ្តឹងទាំង 18 នាក់នោះ មានប្រាំពីរនាក់បានកំណត់អត្តសញ្ញាណខ្លួនឯងថាជាជនជាតិដើមភាគតិច។[18] បើពិនិត្យទៅលើបរិបទរួម ប្រព័ន្ធមីក្រូហិរញ្ញវត្ថុរបស់កម្ពុជាបម្រើដល់ប្រជាជនយ៉ាងច្រើន និងមានភាពចម្រុះ ពោលគឺមានអ្នកខ្ចីប្រាក់ប្រមាណ 1.47 លាននាក់នៅទូទាំងប្រទេសក្នុងឆ្នាំ 2023 ។

---

[15] សូមមើលរបាយការណ៍ Mimosa ឆ្នាំ 2015 និង 2019, https://www.dropbox.com/scl/fi/102tz7legjbztjsog7kur/MIMOSA-White-Paper.pdf?rlkey=j6st07rx3vy99o5expic5gefz&e=2&st=7vim19l4&dl=0, https://www.dropbox.com/scl/fi/c2fav8r4543l4c2f3tfjf/MIMOSA-2.1-White-Paper-FINAL-corrected.pdf?rlkey=je001w7dua15pgwlpulg5vo74&e=2&st=zsnpdvj0&dl=0, Pimhidzai, O., et al., 2019., Microfinance and Household Welfare។ លិខិតគោលនយោបាយកម្ពុជា, https://documents1.worldbank.org/curated/en/144661552916327946/pdf/128266-REVISED-WP-PUBLIC-Nota-MFI-web.pdf, និង IFC, 2015, ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា, https://lib.ncdd.gov.kh/storage/app/public/library_backend/CAT_18831_1/2015-Cambodia+Financial+Consumer+protection-Final.pdf

[16] កាសែតខ្មែរថាមស៍ ថ្ងៃទី 19 ខែមករា ឆ្នាំ 2026, ប្រជាជនកម្ពុជាជិតមួយលាននាក់បានត្រឡប់មកពីប្រទេសថៃ ខណៈដែលរាជរដ្ឋាភិបាលដាក់ចេញនូវវិធានការគាំទ្រទូទាំងប្រទេស, អាចចូលមើលបានតាមរយៈគេហទំព័រ៖ https://www.khmertimeskh.com/501829110/nearly-one-million-cambodians-return-from-thailand-as-government-rolls-out-nationwide-support-measures/?utm_source=chatgpt.com

[17] CAO, 2022,ពាក្យបណ្តឹងពាក់ព័ន្ធនឹងការវិនិយោគគម្រោងរបស់ IFC នៅក្នុងធនាគារអេស៊ីលីដា, អម្រឹត, ប្រាសាក់, អិលអូអិលស៊ី, ធនាគារស្ថាបនា និងធនាគារហត្ថាកសិករ កំណែដែលត្រូវបានកែសម្រួលលុបព័ត៌មានសម្ងាត់, https://www.cao-ombudsman.org/sites/default/files/downloads/Cambodia%20FI%2004%20Complaint%20Redacted%20ENG.pdf

[18] ពាក្យបណ្តឹងនេះត្រូវបានដាក់ជូនក្នុងនាមជាតំណាងឱ្យបុគ្គលចំនួន 19 នាក់ ប៉ុន្តែម្ចាស់បណ្តឹងម្នាក់បានកាត់ផ្តាច់ការទាក់ទងក្នុងអំឡុងពេលដំណើរការពិនិត្យដោះស្រាយរបស់ CAO។

31. ពាក្យបណ្តឹងនេះគឺពាក់ព័ន្ធនឹងអតិថិជនរបស់ IFC ចំនួនបី គឺធនាគារអេស៊ីលីដា, គ្រឹះស្ថានអម្រឹតនិងធនាគារហត្ថាកសិករ និងអតិថិជនរងចំនួនបីទៀត គឺគ្រឹះស្ថានអិលអូអិលស៊ី, ប្រាសាក់ និងស្ថាបនា តាមរយៈការវិនិយោគដោយមូលនិធិចំនួនបីគឺ MEF, MIFA និង North Haven ព្រមទាំងក្រុមហ៊ុនកាន់កាប់វិនិយោគ Advans ដែល IFC មានការវិនិយោគផ្ទាល់។ សម្រាប់បរិបទបន្ថែម បច្ចុប្បន្ននេះមានគ្រឹះស្ថានហិរញ្ញវត្ថុទទួលបានអាជ្ញាបណ្ណប្រមាណ 240 នៅក្នុងប្រទេសកម្ពុជា។[19] អ្នកផ្តល់កម្ចីក្រៅប្រព័ន្ធ មិនត្រូវបានរាប់បញ្ចូលក្នុងចំនួនទាំងនេះទេ។[20]

32. ចាប់តាំងពីឆ្នាំ 2007 មក ម្ចាស់បណ្តឹងបានខ្ចីប្រាក់ពីអ្នកផ្តល់កម្ចីក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលក្នុងនោះមិនមែនសុទ្ធតែជាអតិថិជន ឬអតិថិជនរងរបស់ IFC ទាំងអស់នោះទេ។ ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ម្ចាស់បណ្តឹងបានយកកម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុមួយ ឬច្រើនក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុទាំងប្រាំមួយ ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹង។ ក្នុងចំណោមម្ចាស់បណ្តឹងទាំង 18 នាក់ មានដប់មួយនាក់ បានបញ្ជាក់ថា ពួកគេនៅតែជំពាក់បំណុលជាមួយអតិថិជន ឬអតិថិជនរងរបស់ IFC នៅឡើយ។

33. ម្ចាស់បណ្តឹងចោទថា ពួកគេបានរងគ្រោះថ្នាក់ដោយសារការអនុវត្តការផ្តល់ប្រាក់កម្ចី និងការទារបំណុលទាំងសាហាវ ដែលបានរួមចំណែកធ្វើឱ្យពួកគេធ្លាក់ក្នុងបំណុល។ ដើម្បីសងបំណុលទាំងនោះ ពួកគេបានលក់ដីធ្លីដែលបណ្តាលឱ្យបាត់បង់មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។ អ្នកខ្លះបានបញ្ជាក់ថា ពួកគេត្រូវកាត់បន្ថយការបរិភោគអាហារ ដែលជះឥទ្ធិពលដល់អាហារូបត្ថម្ភ និងសន្តិសុខស្បៀង ឬមិនមានលទ្ធភាពបង់ថ្លៃចំណាយលើសុខាភិបាល និងការអប់រំឡើយ។ ពួកគេក៏បានចែករំលែកផងដែរថា បំណុលរបស់ពួកគេ គឺជាប្រភពនៃការថប់បារម្ភ។

34. នៅក្នុងខែមេសា ឆ្នាំ 2022, CAO បានរកឃើញថា ពាក្យបណ្តឹងនេះមានសិទ្ធិគ្រប់គ្រាន់ និងបានចាប់ផ្តើមដំណើរការវាយតម្លៃ។ ទោះបីជាភាគីមួយចំនួនបានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការចូលរួមក្នុងដំណើរការដោះស្រាយវិវាទដែលដឹកនាំដោយ CAO ក៏ដោយ ក៏នៅពេលនោះមិនទាន់មានការឯកភាពគ្នាជាឯកច្ឆន្ទក្នុងចំណោមភាគីទាំងអស់ដើម្បីបន្តនីតិវិធីនៅឡើយទេ។ ហេតុដូច្នេះហើយ នៅក្នុងខែវិច្ឆិកា ឆ្នាំ 2022, CAO បានបញ្ជូនករណីនេះទៅកាន់ផ្នែកអនុលោមភាពរបស់ខ្លួន ដើម្បីធ្វើការពិនិត្យវាយតម្លៃក្នុងគោលបំណងកំណត់ថាតើគួរតែមានការស៊ើបអង្កេតលើបញ្ហាទាំងនោះដែរឬទេ។[21] ការសម្រេចចិត្តរបស់ CAO ក្នុងការកំណត់ថាពាក្យបណ្តឹងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរឬទេ គឺផ្អែកលើទស្សនៈរបស់ខ្លួនដែលថា ក្របខ័ណ្ឌចីរភាពរបស់ IFC គួរតែត្រូវបានអនុវត្តចំពោះអ្នកប្រើប្រាស់ ពោលគឺអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយសារតែការសម្រេចចិត្តខ្ចីប្រាក់របស់ពួកគេ បាននាំឱ្យមានផលប៉ះពាល់សង្គមដោយអចេតនា។

35. នៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងកាលពីខែវិច្ឆិកា ឆ្នាំ 2022 ដែលជាពេលនៃការបញ្ជូនពាក្យបណ្តឹងពីដំណាក់កាលវាយតម្លៃទៅដំណាក់កាលពិនិត្យវាយតម្លៃអនុលោមភាព IFC បានបំភ្លឺថា បញ្ហាពាក់ព័ន្ធនឹងការផ្តល់ប្រាក់កម្ចី និងការទារបំណុល ត្រូវបានគ្រប់គ្រងតាមរយៈក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសម្រាប់ហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវរបស់ IFC ជាជាងការអនុវត្តតាមក្របខ័ណ្ឌចីរភាពឆ្នាំ 2012។ IFC ក៏បានផ្តល់ការសម្របសម្រួលក្នុងការពិនិត្យឡើងវិញ និងគាំទ្រដល់ការដោះស្រាយករណីបណ្តឹងរបស់ម្ចាស់បណ្តឹងជាមួយនឹងអតិថិជនផ្ទាល់ និងអតិថិជនប្រយោលផងដែរ។ តំណាងម្ចាស់បណ្តឹងមិនបានទទួលយកការផ្តល់ជូនរបស់ IFC ក្នុងការសម្របសម្រួលដំណើរការពិនិត្យឡើងវិញលើករណីទាំងនោះឡើយ។ [22]

---

[19] គិតត្រឹមឆ្នាំ 2024 ប្រព័ន្ធហិរញ្ញវត្ថុទទួលបានអាជ្ញាបណ្ណរបស់ប្រទេសកម្ពុជា រួមមានធនាគារពាណិជ្ជចំនួន 59, ធនាគារឯកទេសចំនួនបួន, MFIs ចំនួន 89 និងគ្រឹះស្ថានឥណទានជនបទចំនួន 89 ដែលបាននឹងកំពុងរួមគ្នាផ្តល់សេវាជូនដល់គណនីប្រាក់បញ្ញើ និងឥណទានរាប់លានគណនីនៅទូទាំងប្រទេស។ *សូមមើល* ធនាគារជាតិនៃកម្ពុជា ឆ្នាំ 2024, របាយការណ៍ត្រួតពិនិត្យប្រចាំឆ្នាំ 2024, https://www.nbc.gov.kh/download_files/supervision/sup_an_rep_eng/EN%20Supervision%20Annual%20Report%2 02024.pdf

[20] អ្នកផ្តល់កម្ចីក្រៅប្រព័ន្ធ ឬអ្នកផ្តល់កម្ចីឯកជន គឺជាបុគ្គល ឬអ្នកផ្តល់កម្ចីប្រាក់ដែលមិនបានចុះបញ្ជី ដែលផ្តល់លទ្ធភាពទទួលបានសាច់ប្រាក់រហ័ស និងមានភាពបត់បែន ដែលភាគច្រើនមិនតម្រូវឱ្យមានឯកសារស្មុគស្មាញឡើយ ប៉ុន្តែពួកគេតែងតែគិតអត្រាការប្រាក់ខ្ពស់ ឬមិនមានតម្លាភាព។ ក្នុងនោះរួមបញ្ចូលទាំងហាងបញ្ចាំ ដែលផ្តល់កម្ចីរយៈពេលខ្លី ដោយមានការធានាជាទ្រព្យសម្បត្តិរូបវន្ត ដូចជាទោចក្រយានយន្ត ឬគ្រឿងអលង្ការជាដើម។

[21] CAO, 2022, របាយការណ៍វាយតម្លៃរបស់ CAO, https://www.cao-ombudsman.org/sites/default/files/downloads/CAO_Assessment_Report_Cambodia_FI-04%20November%202022.pdf

[22] IFC, 2022, ការឆ្លើយតបរបស់គណៈគ្រប់គ្រងចំពោះពាក្យបណ្តឹងរបស់ CAO, សូមមើលឧបសម្ព័ន្ធនៅក្នុងរបាយការណ៍វាយតម្លៃអនុលោមភាពរបស់ CAO, https://www.cao-ombudsman.org/sites/default/files/downloads/CAO%20Compliance%20Appraisal-Cambodia%20FI04%20-FINAL-%28For%20publication%29-ENG_0.pdf.

36. ក្នុងការបើកការស៊ើបអង្កេតលើអនុលោមភាពទូទាំងវិស័យចំពោះការវិនិយោគកន្លងមក និងបច្ចុប្បន្ន របស់ IFC ចំនួន 13 ករណី ដែលបានធ្វើឡើងនៅចន្លោះឆ្នាំ 2004 និង 2021, CAO បានលើកឡើងថា ដោយសារតែអ្នកប្រើប្រាស់មិនត្រូវបានដកចេញដោយច្បាស់លាស់ពីក្របខ័ណ្ឌចីរភាព កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ គួរតែត្រូវបានចាត់ទុកជាលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គម (E&S) ដែលត្រូវអនុវត្តចំពោះអតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ IFC។

37. នៅក្នុងបទបង្ហាញជូនក្រុមប្រឹក្សាភិបាលកាលពីខែកក្កដា ឆ្នាំ 2023, IFC បានពន្យល់ពីភាពខុសគ្នារវាងក្របខ័ណ្ឌចីរភាពរបស់ IFC និងវិធីសាស្ត្ររបស់ខ្លួនចំពោះមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។[23] ក្របខ័ណ្ឌចីរភាពរបស់ IFC ត្រូវបានកំណត់ឡើងជាពិសេស ដើម្បីគ្រប់គ្រងហានិភ័យ និងផលប៉ះពាល់ផ្នែក E&S ដែលពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មនៃគម្រោង និងគម្រោងរងដែលផ្តល់ហិរញ្ញប្បទានដោយ IFC ទៅលើសហគមន៍ជុំវិញ និងកម្មករនិយោជិត។ វិធីសាស្ត្ររបស់ IFC ចំពោះមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ គឺផ្អែកលើគោលការណ៍ការពារអតិថិជន និងកំណត់ចេញនូវលក្ខខណ្ឌតម្រូវសម្រាប់អតិថិជនលើការផ្តល់កម្ចីប្រកបដោយការទទួលខុសត្រូវ រួមទាំងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ ដូចជាការគ្រប់គ្រងហានិភ័យនៃបំណុលលើសលប់ជាដើម។[24]

38. នៅទូទាំងដំណើរការរបស់ CAO ម្ចាស់បណ្តឹងរបស់ IFC និងតំណាងរបស់ពួកគេបានចែករំលែកនូវកង្វល់ពាក់ព័ន្ធនឹងការគំរាមកំហែង និងការសងសឹក រួមទាំងសកម្មភាពពីភាគីទីបីផងដែរ។ IFC បានចាត់វិធានការ និងសហការជាមួយអតិថិជនរបស់ខ្លួន ដៃគូអភិវឌ្ឍន៍ ក៏ដូចជាទូទាំង WBG ដើម្បីដោះស្រាយបញ្ហាទាំងនោះ។

39. ជាចំណាំ គោលនយោបាយរបស់ CAO ចែងថា CAO មិនត្រូវទទួលយកពាក្យបណ្តឹងណា ដែលមានលក្ខណៈដូចគ្នាទាំងស្រុងក្នុងទិដ្ឋភាពសំខាន់ៗទៅនឹងពាក្យបណ្តឹងដែលត្រូវបានដាក់ជូន CAO កាលពីមុននោះឡើយ លុះត្រាតែ CAO កំណត់ថាមានការផ្លាស់ប្តូរជាដុំកំភួននៃកាលៈទេសៈ។[25] ទោះជាយ៉ាងណាក៏ដោយ ក្នុងអំឡុងពេលនៃការស៊ើបអង្កេតលើអនុលោមភាពរយៈពេលពីរឆ្នាំ CAO បានទទួលយកពាក្យបណ្តឹងផ្នែកមីក្រូហិរញ្ញវត្ថុចំនួនប្រាំបួនបន្ថែមទៀតលើការវិនិយោគដដែលរបស់ IFC ពីអ្នកខ្ចីប្រាក់ជាបុគ្គលផ្សេងទៀត ដោយមានការសម្របសម្រួលពី LICADHO និង EC។

40. នៅក្នុងខែតុលា ឆ្នាំ 2025, CAO បានចែករំលែករបាយការណ៍ស៊ើបអង្កេតរបស់ខ្លួន ហើយម្ចាស់បណ្តឹង និងតំណាងរបស់ពួកគេបានចូលរួមជាមួយ IFC ដោយផ្ទាល់។ នៅក្នុងខែវិច្ឆិកា ឆ្នាំ 2025, IFC បានជួបប្រជុំជាមួយម្ចាស់បណ្តឹងទាំងអស់ចំនួន 18 នាក់ នៅក្នុងករណីរបស់ CAO នេះ។ ការរៀបរាប់របស់ពួកគេបានបង្ហាញពីស្ថានភាពដ៏ស្មុគស្មាញនៃភាពលំបាកផ្នែកសេដ្ឋកិច្ច និងភាពក្រីក្រ ហើយក៏ជាសក្ខីកម្មឆ្លុះបញ្ចាំងពីបញ្ហាប្រឈមនានាដែលអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានប្រាក់ចំណូលទាបនៅក្នុងប្រទេសកម្ពុជាអាចជួបប្រទះ។

41. IFC បានដឹងថា ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ម្ចាស់បណ្តឹងទាំង 18 នាក់ មិនត្រឹមតែបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនផ្ទាល់ និងប្រយោលរបស់ IFC ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានខ្ចីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (BFIs) ផ្សេងទៀត និង/ឬអ្នកផ្តល់កម្ចីឯកជនផងដែរ។ កម្ចីរបស់ម្ចាស់បណ្តឹងមួយចំនួន ត្រូវបានដកយកទៅប្រើប្រាស់តាំងពីឆ្នាំ 2007 មកម្ល៉េះ ហើយត្រូវបានសងវិញ និង/ឬធ្វើបុនហិរញ្ញប្បទានក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ។ ហេតុដូច្នេះហើយ គេមិនអាចទម្លាក់កំហុសទៅលើកម្ចីរបស់បុគ្គលណាម្នាក់តែមួយថាជាមូលហេតុបង្កឱ្យមានបំណុលលើសលប់នោះឡើយ។

42. ម្ចាស់បណ្តឹងមួយចំនួនបានខ្ចីប្រាក់ដើម្បីទិញធាតុចូលកសិកម្ម ហើយមិនអាចសងត្រឡប់មកវិញបាននៅពេលដែលមានគ្រោះរាំងស្ងួត ឬទឹកជំនន់កើតឡើង ឬនៅពេលដែលតម្លៃកសិផលធ្លាក់ចុះ។ អ្នកខ្លះទៀតបានដកកម្ចីដើម្បីសាងសង់ ឬពង្រីកផ្ទះសម្បែងរបស់ពួកគេ ឬដើម្បីចំណាយលើការថែទាំសុខភាព និងការចំណាយក្នុងគ្រួសារ។ ក្នុងករណីខ្លះ ម្ចាស់បណ្តឹងបានរាយការណ៍ថា មន្ត្រីឥណទានពាក់ព័ន្ធបានលើកទឹកចិត្តពួកគេឱ្យលាក់បាំងពីគោលបំណងពិតប្រាកដនៃការប្រើប្រាស់កម្ចី។

43. ម្ចាស់បណ្តឹងទាំងអស់បានរាយការណ៍ថា ពួកគេមានអារម្មណ៍ថាត្រូវបានដាក់សម្ពាធ ឬត្រូវបានគំរាមកំហែងឱ្យសងបំណុលរបស់ពួកគេ ដោយមន្ត្រីឥណទានរបស់ BFIs រៀងៗខ្លួនរបស់ពួកគេ។ ពួកគេបានចាត់ទុកការ

---

[23] កិច្ចប្រជុំរបស់គណៈកម្មការសម្រាប់ការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព (CODE) បានប្រព្រឹត្តទៅកាលពីថ្ងៃទី 21 ខែកក្កដា ឆ្នាំ 2023។

[24] IFC, 2023, សំណើរបស់ IFC សុំការពិនិត្យឡើងវិញពីក្រុមប្រឹក្សាភិបាលលើការសម្រេចចិត្តស៊ើបអង្កេត, https://www.cao-ombudsman.org/sites/default/files/downloads/IFC%20Management%20Board%20Review%20Request%20%28por%20publication%29_0.pdf

[25] គោលនយោបាយរបស់ CAO, កថាខណ្ឌ 42.i.

ចុះជួបប្រចាំខែ ឬពីរសប្តាហ៍ម្តងរបស់មន្ត្រីឥណទាន ថាជាការរំខានបៀតបៀន។ ម្ចាស់បណ្តឹងបានរាយការណ៍ថា ពួកគេមានអារម្មណ៍ខ្មាស់អៀន នៅពេលដែលមន្ត្រីឥណទានចូលទៅជួបមេភូមិ ដែលជារឿយៗមេភូមិគឺជាអ្នកជួយធ្វើជាសាក្សីក្នុងដំណើរការរៀបចំធ្វើឯកសារប្លង់ដីសម្រាប់ដាក់ជាទ្រព្យបញ្ចាំ។ យោងតាមការរៀបរាប់របស់ម្ចាស់បណ្តឹងមួយចំនួន មន្ត្រីឥណទានខ្លះបានគំរាមថានឹងហៅប៉ូលិស ឬទាហាន ឬបញ្ជូនអ្នកខ្ចីប្រាក់ទៅតុលាការ ទោះបីជាមិនមានវិធានការផ្លូវច្បាប់ពីប៉ូលិស ឬប្រព័ន្ធតុលាការណាមួយត្រូវបានអនុវត្តចំពោះម្ចាស់បណ្តឹងណាម្នាក់ក៏ដោយ។

44. ម្ចាស់បណ្តឹងទាំងអស់បានបញ្ជាក់ថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលជាអតិថិជនផ្ទាល់ និងប្រយោលរបស់ IFC មិនបានធ្វើការរឹបអូសទ្រព្យបញ្ចាំជាដីធ្លី ឬបង្ខំឱ្យលក់ដីនោះទេ ហើយ BFIs ទាំងនោះ ក៏មិនបានពាក់ព័ន្ធនៅក្នុងការលក់ដីណាមួយឡើយ។ ទោះជាយ៉ាងណាក៏ដោយ ម្ចាស់បណ្តឹងភាគច្រើនបានរាយការណ៍ថា ពួកគេបានលក់ដី (ឬផ្នែកខ្លះនៃដី) របស់ខ្លួនដើម្បីសងបំណុល ហើយមានអារម្មណ៍ថាត្រូវបានគេដាក់សម្ពាធឱ្យធ្វើសកម្មភាពបែបនេះ។ [26]ជាលទ្ធផល ពួកគេបានបាត់បង់មុខរបរចិញ្ចឹមជីវិតទាំងស្រុង ឬមួយផ្នែក។

45. ក្នុងចំណោមម្ចាស់បណ្តឹងទាំង 18 នាក់នោះ វាមានប្រាំពីរនាក់បានកំណត់អត្តសញ្ញាណខ្លួនឯងថាជាជនជាតិដើមភាគតិច។ ពួកគេបានប្រើប្រាស់ប្លង់ទន់បុគ្គលធ្វើជាទ្រព្យបញ្ចាំដើម្បីខ្ចីប្រាក់ ដោយកម្ចីមួយចំនួនមានការដឹងឮ និងទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរសហគមន៍ជនជាតិដើមភាគតិចរបស់ពួកគេ។ ដោយសារមិនទាន់មានប្រព័ន្ធទិន្នន័យដីធ្លីមជ្ឈការ MFI ដែលជាអតិថិជនផ្ទាល់ ឬអតិថិជនប្រយោលរបស់ IFC បានទទួលយកប្លង់ទន់បុគ្គលទាំងនេះ ដោយមិនបានផ្ទៀងផ្ទាត់ថាតើដីទាំងនោះកំពុងមានការទាមទារសិទ្ធិ ឬវិវាទដីធ្លីផ្សេងទៀតដែរឬទេ។ ម្ចាស់បណ្តឹងបានបញ្ជាក់ថា អតិថិជនផ្ទាល់ និងប្រយោលរបស់ IFC មិនបានទទួលយកប្លង់ដីសហគមន៍ជនជាតិដើមភាគតិចធ្វើជាទ្រព្យបញ្ចាំដោយផ្ទាល់នោះទេ ហើយក៏មិនបានធ្វើការរឹបអូសទ្រព្យជានាជាដីធ្លីណាមួយរបស់ម្ចាស់បណ្តឹងទាំងប្រាំពីរនាក់នេះដែរ។

46. ម្ចាស់បណ្តឹងដែលជាជនជាតិដើមភាគតិច ក៏ដូចជាអ្នកខ្ចីប្រាក់ដែលមានវ័យជរា បានរាយការណ៍ថា ពួកគេមានកម្រិតអក្ខរកម្មទាបក្នុងការអានសរសេរភាសាខ្មែរ និងខ្វះសមត្ថភាពក្នុងការអាន ក៏ដូចជាស្វែងយល់លើឯកសារនានា។ ពួកគេបានចែករំលែកថា នៅពេលដែលពួកគេដកកម្ចី សមាជិកគ្រួសារ ឬសមាជិកសហគមន៍បានជួយក្នុងការបកប្រែ ឬជួយពន្យល់ឱ្យយល់ដឹងពីលក្ខខណ្ឌផ្សេងៗ។ ប៉ុន្តែក្រោយមក អ្នកខ្ចីប្រាក់ទាំងនោះបានជួបការលំបាកក្នុងការស្វែងយល់ដោយខ្លួនឯងអំពីលក្ខខណ្ឌតម្រូវនៃការសងប្រាក់ និងការធ្វើរចនាសម្ព័ន្ធឡើងវិញ។ មានម្ចាស់បណ្តឹងតែម្នាក់គត់ក្នុងចំណោម 18 នាក់ ដែលបានដឹង និងបានប្រើប្រាស់យន្តការដោះស្រាយបណ្តឹងអ្នកប្រើប្រាស់ដែលមានស្រាប់។ ចំណុចនេះបង្ហាញឱ្យឃើញពីឱកាសក្នុងការប្រើប្រាស់យន្តការដែលមានស្រាប់ដើម្បីដោះស្រាយករណីនានា ក៏ដូចជាតម្រូវការក្នុងការពង្រឹងការយល់ដឹងអំពីយន្តការទាំងនោះបន្ថែមទៀត។

47. IFC ទទួលស្គាល់ថា ផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម-សេដ្ឋកិច្ច ដែលត្រូវបានរៀបរាប់ដោយម្ចាស់បណ្តឹង គឺមានសភាពធ្ងន់ធ្ងរ និងទាមទារឱ្យមានការវិភាគ ក៏ដូចជាការចាត់វិធានការបន្ថែមទៀត។ បទពិសោធរបស់ម្ចាស់បណ្តឹង គឺស្របគ្នាទៅនឹងលំនាំនៃបញ្ហាជាប្រព័ន្ធ និងកម្រិតប្រទេស ដែលត្រូវបានបង្កើតឡើងដោយហាមវន្តរចនាសម្ព័ន្ធ រួមមានការធ្វើពាណិជ្ជូបនីយកម្មវិស័យនេះយ៉ាងឆាប់រហ័ស ប្រព័ន្ធការពារសង្គមខ្សោយ អសន្តិសុខនៃសិទ្ធិកាន់កាប់ដីធ្លី និងអក្ខរកម្មហិរញ្ញវត្ថុរបស់អ្នកប្រើប្រាស់នៅមានកម្រិតទាប។ បាតុភាពទាំងនេះត្រូវបានជំរុញដោយលក្ខខណ្ឌផ្នែកបរិបទបញ្ញត្តិ ទីផ្សារ និងសង្គម-សេដ្ឋកិច្ច ហើយបានគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ WBG នៅក្នុងប្រព័ន្ធអេកូឡូស៊ីមីក្រូហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយនៅក្នុងប្រទេសកម្ពុជា។

48. ផ្នែកខាងក្រោមនេះពិពណ៌នាអំពីរបៀបដែល IFC នឹងសហការជាមួយម្ចាស់បណ្តឹង និងអតិថិជន ដើម្បីសម្របសម្រួលដល់ការដោះស្រាយករណីទាំង 18 នេះ។ បន្ថែមលើនេះ ថ្នាក់គ្រប់គ្រងបង្ហាញពីរបៀបដែល IFC បាននឹងកំពុងបំពេញការងារនៅក្នុងប្រទេសកម្ពុជាទាំងនៅក្នុងកម្រិតវិស័យ និងកម្រិតបទប្បញ្ញត្តិ ព្រមទាំងគូសបញ្ជាក់ពីគំនិតផ្តួចផ្តើមនានាជាមួយដៃគូអភិវឌ្ឍន៍ផងដែរ។

## V. ការគាំទ្ររបស់ IFC ក្នុងការដោះស្រាយករណីជាក់លាក់របស់ម្ចាស់បណ្តឹង

49. ដូចដែលបានកំណត់នៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងរបស់ IFC កាលពីខែវិច្ឆិកា ឆ្នាំ 2022, IFC ប្តេជ្ញាចិត្តក្នុងការពិនិត្យឡើងវិញ និងគាំទ្រដល់ការដោះស្រាយបញ្ហានានាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ដែលពាក់ព័ន្ធនឹងមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ។

[26] CAO បានចែករំលែកថា ម្ចាស់បណ្តឹងភាគច្រើនមិនបានផ្តល់ឯកសារផ្លូវការអំពីការផ្ទេរកម្មសិទ្ធិដីធ្លីនោះទេ។ ភស្តុតាងចម្បងនៃការលក់ដី គឺមានតែតាមរយៈសក្ខីកម្មរបស់ម្ចាស់បណ្តឹងប៉ុណ្ណោះ។

50. នៅពេលដែល IFC បានជួបប្រជុំជាមួយម្ចាស់បណ្តឹងនៅក្នុងខែវិច្ឆិកា ឆ្នាំ 2025 ម្ចាស់បណ្តឹងចំនួន 17 នាក់ ក្នុងចំណោម 18 នាក់ មិនបានដឹងអំពីយន្តការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ដែលមានស្រាប់របស់គ្រឹះស្ថានផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុរៀងៗខ្លួននោះទេ ហើយក៏មិនទទួលបានព័ត៌មានអំពីយន្តការដោះស្រាយបណ្តឹងទូទាំងវិស័យដែលមានសម្រាប់ពួកគេនោះដែរ។[27] ភាគច្រើននៃពួកគេមិនបានចូលរួមជាមួយបុគ្គលិកមីក្រូហិរញ្ញវត្ថុផ្សេងទៀត ក្រៅពីមន្ត្រីឥណទានដែលគ្រប់គ្រងកម្ចីរបស់ពួកគេនោះឡើយ ហើយក៏មិនបានដឹងថាពួកគេអាចដាក់ពាក្យបណ្តឹងអំពីការអនុវត្តការផ្តល់ប្រាក់កម្ចី និងការទារបំណុលទាំងសាហាវនោះដែរ។ ជំនួសឱ្យការប្រើប្រាស់យន្តការមូលដ្ឋានទាំងនេះ អង្គការ LICADHO និងអង្គការ EC ក្នុងនាមជាតំណាងឱ្យអ្នកខ្ចីប្រាក់ទាំងនេះ បានដាក់ជូននូវកង្វល់របស់ពួកគេដោយផ្ទាល់ទៅកាន់ CAO ដោយលើកឡើងពីក្តីបារម្ភអំពីការសងសឹកនៅក្នុងប្រទេសកម្ពុជា។

51. ដោយសារតែកង្វល់អំពីការសម្ងាត់ និងការសងសឹក ករណីរបស់ម្ចាស់បណ្តឹងទាំងនេះ មិនទាន់ត្រូវបានចែករំលែកទៅកាន់អតិថិជនផ្ទាល់ និងប្រយោលរបស់ IFC នៅឡើយទេ។ ពួកគេមិនទាន់អាចធ្វើការវាយតម្លៃ និងឆ្លើយតបចំពោះកង្វល់របស់ម្ចាស់បណ្តឹងបាននៅឡើយទេ។ ដូចគ្នាដែរ រហូតមកទល់ពេលនេះ គេមិនទាន់អាចវាយតម្លៃបានទេថាតើឥរិយាបថរបស់មន្ត្រីឥណទានជាក់លាក់ ឬកំហុសឆ្គងនៅក្នុងនីតិវិធីនៃការពិនិត្យផ្តល់ឥណទានពាក់ព័ន្ធ បានរួមចំណែកដល់ផលប៉ះពាល់អវិជ្ជមានដូចដែលបានចោទប្រកាន់នោះដែរឬទេ។

52. IFC បានចែករំលែកព័ត៌មានជាមួយម្ចាស់បណ្តឹងអំពីCCMs ដែលមានសម្រាប់ពួកគេ និងរបៀបដែលយន្តការទាំងនោះដំណើរការ (សូមមើលរូបទី 1)។ ម្ចាស់បណ្តឹងទាំងអស់បានយល់ព្រមប្រើប្រាស់យន្តការ CCMs របស់អតិថិជនផ្ទាល់ ឬប្រយោល និង/ឬយន្តការកម្រិតវិស័យ ដើម្បីពិនិត្យមើលករណីរបស់ពួកគេឡើងវិញ ដោយមានការសម្របសម្រួលពី IFC។ ម្ចាស់បណ្តឹងបានបញ្ជាក់ថា បំណងប្រាថ្នារបស់ពួកគេគឺចង់ឱ្យមានការធ្វើរចនាសម្ព័ន្ធបំណុលឡើងវិញ ឬការលើកលែងបំណុល ដើម្បីឱ្យពួកគេអាចបន្តមានលទ្ធភាពទទួលបានសេវាផ្តល់ប្រាក់កម្ចីពី MFIs ផ្លូវការ ដែលផ្តល់នូវលក្ខខណ្ឌល្អជាងអ្នកផ្តល់កម្ចីក្រៅផ្លូវការ។ អ្នកខ្លះក៏បានសម្តែងនូវបំណងប្រាថ្នាចង់ទិញដីរបស់ពួកគេត្រឡប់មកវិញផងដែរ។

53. ដើម្បីសម្របសម្រួលដល់ការដោះស្រាយករណីជាក់លាក់ទាំង 18 នេះ IFC នឹងជួលទីប្រឹក្សាឯករាជ្យមួយរូប ដើម្បីជួយដល់អតិថិជនផ្ទាល់ និងប្រយោលក្នុងការដំណើរការពិនិត្យករណីរបស់ម្ចាស់បណ្តឹងតាមរយៈប្រព័ន្ធយន្តការ CCMs ដែលមានស្រាប់របស់ពួកគេ ដោយបង្កើតនូវបរិយាកាសមួយដ៏មានសុវត្ថិភាព និងក្នុងន័យស្ថាបនាសម្រាប់ម្ចាស់បណ្តឹងក្នុងការដោះស្រាយកង្វល់របស់ខ្លួន។ សកម្មភាពនេះនឹងរួមបញ្ចូលទាំងការប្រមូលទិន្នន័យសង្គម-សេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយអំពីម្ចាស់បណ្តឹងដើម្បីជាព័ត៌មានជំនួយដល់ដំណើរការនេះ។ ក្នុងករណីដែលកង្វល់អំពីការសងសឹកនៅតែបន្តមាន ពាក្យបណ្តឹងទាំងនោះនឹងត្រូវដំណើរការដោយរក្សាការសម្ងាត់។ ទោះបីជាម្ចាស់បណ្តឹងត្រូវតែបង្ហាញអត្តសញ្ញាណរបស់ខ្លួនដើម្បីឱ្យមានការពិនិត្យកម្ចីឡើងវិញក៏ដោយ ក៏អត្តសញ្ញាណរបស់ពួកគេអាចត្រូវបានរក្សាទុកជាការសម្ងាត់នៅក្នុងដំណើរការនៃយន្តការ CCM នេះបាន។ សាខាមីក្រូហិរញ្ញវត្ថុ ឬមន្ត្រីឥណទានពាក់ព័ន្ធមិនចាំបាច់ត្រូវបានជូនដំណឹងអំពីពាក្យបណ្តឹងនោះឡើយ។

54. ករណីនីមួយៗនឹងត្រូវយកមកពិនិត្យឡើងវិញជាបុគ្គល និងដំណើរការទៅតាមក្របខ័ណ្ឌនៃបទប្បញ្ញត្តិជាតិ និងការអនុវត្តឧស្សាហកម្មល្អ។ ដំណោះស្រាយទាំងនោះអាចរួមបញ្ចូលទាំងការធ្វើរចនាសម្ព័ន្ធកម្ចីឡើងវិញ (ឧ. ការពន្យារពេលសងប្រាក់) ការកាត់បន្ថយ ឬការពន្យារពេលការសងប្រាក់ត្រឡប់មកវិញ ការផ្តល់រយៈពេលអនុគ្រោះបណ្តោះអាសន្ន ឬការកែសម្រួលអត្រាការប្រាក់។[28] ថ្នាក់គ្រប់គ្រងកត់សម្គាល់ឃើញថា តំណាងអង្គការ CSO បានស្នើសុំ ហើយ CAO ក៏បានផ្តល់អនុសាសន៍ឱ្យអតិថិជន និងអតិថិជនរងរបស់ IFC ផ្តល់ការលើកលែងបំណុល និងការស្តារមុខរបរចិញ្ចឹមជីវិតឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ ជម្រើសទាំងនេះមិនស្ថិតនៅក្នុងវិសាលភាពនៃជម្រើសធ្វើរចនាសម្ព័ន្ធបំណុលឡើងវិញដែលត្រូវបានកំណត់ដោយបទប្បញ្ញត្តិជាតិឡើយ ហើយវាក៏មិនមែនជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនៃការអនុវត្តល្អក្នុងវិស័យនោះដែរ។[29]

55. នៅពេលដែលមិនអាចឈានទៅដល់ការដោះស្រាយនៅក្នុងកម្រិតអតិថិជនបាន ទីប្រឹក្សានឹងជម្រាបជូនម្ចាស់បណ្តឹងអំពីយន្តការដោះស្រាយបណ្តឹងកម្រិតវិស័យដែលមាន ហើយប្រសិនបើចាំបាច់ នឹងជួយសម្របសម្រួ

[27] កម្ចីរបស់ម្ចាស់បណ្តឹងត្រូវបានធ្វើឡើងមុនពេលមានការដាក់ឱ្យប្រើប្រាស់នូវលក្ខខណ្ឌកិច្ចសន្យាស្តង់ដាសម្រាប់កម្ចីមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ 2022 ដែលលក្ខខណ្ឌស្តង់ដានោះផ្តល់នូវព័ត៌មានអំពីយន្តការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ទាំងនៅក្នុងកម្រិតអតិថិជន និងទូទាំងវិស័យ។

[28] គំនិតផ្តួចផ្តើមរបស់ IFC គឺស្របគ្នាទៅនឹងវិធីសាស្ត្រដោះស្រាយដែលត្រូវបានផ្តល់ជូននៅក្នុងករណីបន្ថែមចំនួន 9 ផ្សេងទៀតរបស់ CAO ដែលបានជ្រើសរើសដំណើរការដោះស្រាយវិវាទ។ ទោះបីជាដំណើរការទាំងនោះជាការសម្ងាត់ក៏ដោយ ក៏របាយការណ៍របស់ CAO បានបង្ហាញថា រាល់កិច្ចព្រមព្រៀងទាំងអស់គឺស្ថិតនៅក្នុងវិសាលភាពនៃបទប្បញ្ញត្តិជាតិ។

[29] ស្តង់ដាការពារអតិថិជនរបស់ Cerise+SPTF បានចែងថា គ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុធ្វើការរៀបចំរចនាសម្ព័ន្ធកម្ចីឡើងវិញ ឬលុបចោលបំណុលតែនៅក្នុងករណីលើកលែងពិសេសប៉ុណ្ណោះ ដោយផ្អែកលើករណីជាក់លាក់ (ដែលបានកំណត់ទុកជាមុន) នៃស្ថានភាពជួបការលំបាកខ្លាំង។

លដល់ពួកគេក្នុងការទទួលបានយន្តការទាំងនោះ។ រូបទី 1 ពិពណ៌នាអំពីទម្រង់រចនាសម្ព័ន្ធនៃយន្តការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ដែលមានសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ នៅក្នុងអំឡុងពេលនៃការដាក់ពាក្យបណ្តឹងទៅកាន់ CAO កាលពីឆ្នាំ 2022 មិនមែនរាល់យន្តការដោះស្រាយសងការខូចខាតទូទាំងវិស័យទាំងអស់ត្រូវបានបង្កើតឡើង និងដាក់ឱ្យប្រើប្រាស់ទាំងអស់នោះទេ។

56. ម្ចាស់បណ្តឹងដែលមិនពេញចិត្តនឹងដំណោះស្រាយដែលផ្តល់ដោយយន្តការ CCM របស់គ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ អាចប្រើប្រាស់យន្តការដោះស្រាយបណ្តឹងរបស់មជ្ឈមណ្ឌលអ្នកប្រើប្រាស់ហិរញ្ញវត្ថុ (FCC) ឬ NBC បាន។ បន្ថែមលើនេះ ម្ចាស់បណ្តឹងក៏មានជម្រើសក្នុងការប្រើប្រាស់សេវាសម្រុះសម្រួលរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (NAADR) ឬយកករណីរបស់ខ្លួនទៅកាន់តុលាការផងដែរ។ ទាំង FCC និង NAADR មិនទាន់មានវត្តមាននៅឡើយទេកាលពីឆ្នាំ 2022 នៅពេលដែលម្ចាស់បណ្តឹងបានដាក់ករណីរបស់ពួកគេដោយផ្ទាល់ទៅកាន់ CAO។ នៅក្នុងខែវិច្ឆិកា ឆ្នាំ 2025 ម្ចាស់បណ្តឹង រួមជាមួយតំណាងរបស់ពួកគេ បានសម្តែងការស្វាគមន៍ចំពោះការប្រើប្រាស់យន្តការទូទាំងវិស័យទាំងនេះ។

**រូបទី 1៖ ទម្រង់រចនាសម្ព័ន្ធនៃយន្តការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា**




57. IFC កត់សម្គាល់ឃើញថា គិតត្រឹមខែវិច្ឆិកា ឆ្នាំ 2025 ម្ចាស់បណ្តឹងចំនួន 11 នាក់ ក្នុងចំណោម 18 នាក់ នៅមានកម្ចីដែលនៅសេសសល់ជាមួយអតិថិជនផ្ទាល់ ឬអតិថិជនប្រយោលរបស់ IFC។ ចំពោះម្ចាស់បណ្តឹងដែលលែងមានបំណុលដែលនៅសេសសល់ទាំងនោះ នឹងអាចទទួលបានការគាំទ្រពីទីប្រឹក្សា ដើម្បីចូលទៅប្រើប្រាស់យន្តការដោះស្រាយពាក្យបណ្តឹងតាមកម្រិតវិស័យដោយផ្ទាល់បាន។

58. CAO បានផ្តល់អនុសាសន៍ឱ្យពង្រីកគំនិតផ្តួចផ្តើមនេះ ឱ្យលើសពីម្ចាស់បណ្តឹងទាំង 18 នាក់ ដើម្បីគ្របដណ្តប់លើអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់ ដែលជាអតិថិជនផ្ទាល់ និងប្រយោលរបស់ IFC នៅក្នុងប្រទេសកម្ពុជា។ IFC កត់សម្គាល់ឃើញថា វិធីសាស្ត្របែបនេះនឹងធ្វើឱ្យប៉ះពាល់ដល់CCMs របស់អតិថិជន ក៏ដូចជារចនាសម្ព័ន្ធដោះស្រាយពាក្យបណ្តឹងអ្នកប្រើប្រាស់កម្រិតវិស័យ ដែលមានសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ដែលនេះមិនមែនជាផលប្រយោជន៍ល្អបំផុតនៃការអភិវឌ្ឍប្រកបដោយចីរភាពរយៈពេលវែងនៃវិស័យនេះឡើយ។

## VI. ការគាំទ្ររបស់ IFC ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

59. ដូចដែលបានរៀបរាប់ខាងលើ នៅពេលធ្វើការវិនិយោគលើគ្រឹះស្ថានផ្តល់សេវាមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា IFC ជ្រើសរើសចូលរួមសហការជាមួយ BFIs ទាំងឡាយណាដែលបង្ហាញពីការប្តេជ្ញាចិត្តចំពោះការអនុវត្តការផ្តល់ប្រាក់កម្ចីដោយការទទួលខុសត្រូវ ស្របតាមស្តង់ដាឧស្សាហកម្មដែលត្រូវបានទទួលស្គាល់។ នៅចន្លោះឆ្នាំ 2020 និង 2024 ការផ្តល់ហិរញ្ញប្បទានផ្ទាល់ដោយ IFC និងដៃគូ DFI ផ្សេងទៀត បានជួយឱ្យអតិថិជនរបស់ IFC ក្នុងប្រទេសកម្ពុជា (រួមមានអេស៊ីលីដា, ហត្ថាកម្ពុជា និងអម្រឹត) អាចបម្រើសេវាកម្មដល់ MSMEs ប្រមាណ 400,000 ក្នុងមួយឆ្នាំជាមធ្យម ដោយផ្តោតជាពិសេសទៅលើអាជីវកម្មដែលគ្រប់គ្រងដោយស្ត្រី និងអ្នកខ្ចីប្រាក់ជាលក្ខណៈបុគ្គល។

60. គ្រឹះស្ថានហិរញ្ញវត្ថុទាំងប្រាំមួយ ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹង ត្រូវបានចាត់ទុកជាសមូហភាពថា មានសារៈសំខាន់ជាប្រព័ន្ធសម្រាប់វិស័យហិរញ្ញវត្ថុកម្ពុជា។ ការវិនិយោគរបស់ IFC បានចាប់ផ្តើមតាំងពីដើមទសវត្សរ៍ឆ្នាំ 2000 មកម្ល៉េះ ហើយមានភាពស្របគ្នាទាំងស្រុងជាមួយនឹងក្របខ័ណ្ឌភាពជាដៃគូប្រចាំប្រទេសរបស់ WBG ឯកសារស្តីពីវិធីសាស្ត្រឆ្លើយតបនឹងវិបត្តិជំងឺ COVID-19 របស់ WBG និងអាទិភាពយុទ្ធសាស្ត្ររបស់ IFC សម្រាប់ប្រទេសកម្ពុជា។

61. ដូចបានរៀបរាប់ខាងលើ IFC បានចូលរួមសហការជាមួយ MFIs ក្នុងចំនួនកំណត់មួយនៅក្នុងប្រទេសកម្ពុជា ដោយផ្អែកលើភាពស្របគ្នានៃគោលជំហររបស់ពួកគេជាមួយនឹងវិធីសាស្ត្ររបស់ IFC ក្នុងវិស័យហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងសមត្ថភាពរបស់ពួកគេក្នុងការអនុវត្តស្តង់ដាដែលអាចអនុវត្តបានទៅតាមពេលវេលា។ IFC បានកំណត់ការប្តេជ្ញាចិត្តរបស់អនាគតគ្រឹះស្ថានចំពោះកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមរយៈការវាយតម្លៃដោយយកចិត្តទុកដាក់នៃនីតិវិធីវាយតម្លៃឥណទាន និងការប្រមូលបំណុលក្នុងអំឡុងពេលនៃការធ្វើការត្រួតពិនិត្យភាពត្រឹមត្រូវ ក៏ដូចជាតាមរយៈការតាមដានការអនុវត្តទាំងនេះជាប្រចាំ តាមរយៈការត្រួតពិនិត្យផលប័ត្រឥណទានជាទៀងទាត់ (សម្រាប់ព័ត៌មានបន្ថែម សូមមើលឧបសម្ព័ន្ធ B)។ លើសពីនេះ IFC បានផ្តល់ និងបន្តផ្តល់សេវាកម្មប្រឹក្សាយោបល់ដល់អតិថិជនរបស់ខ្លួន ដើម្បីពង្រឹងការអនុវត្តហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវរបស់ពួកគេ។ សេវាកម្មទាំងនេះរួមមានការវិនិច្ឆ័យ និងការគាំទ្រក្នុងការទទួលបានវិញ្ញាបនបត្រការពារអតិថិជនពីភាគីទីបី។ អតិថិជន និងអតិថិជនរងរបស់ IFC ទាំងអស់បានទទួលវិញ្ញាបនបត្រការពារអតិថិជនក្នុងចន្លោះឆ្នាំ 2015 ដល់ឆ្នាំ 2021។ នៅក្នុងឆ្នាំ 2025 គ្រឹះស្ថានអិលអូអិលស៊ី, អម្រឹត, អេស៊ីលីដា និងស្ថាបនាបានបន្តសុពលភាពវិញ្ញាបនបត្ររបស់ពួកគេ ដោយទទួលបានឋានៈ "មាស" ដែលជាកម្រិតសមិទ្ធផលខ្ពស់បំផុត។

62. ចាប់តាំងពីឆ្នាំ 2022 មក ដើម្បីឆ្លើយតបទៅនឹងករណីរបស់ CAO និងដើម្បីដោះស្រាយបញ្ហាការផ្តល់ប្រាក់កម្ចី និងការទារបំណុលទាំងសាហាវក្នុងវិស័យនេះ ព្រមទាំងកែសម្រួលវាឱ្យស្របទៅតាមការអនុវត្តល្អនៃឧស្សាហកម្មអន្តរជាតិ IFC បានផ្តល់ការកសាងសមត្ថភាពដល់អតិថិជនផ្ទាល់ និងអតិថិជនប្រយោលទាំងអស់របស់ IFC លើការគ្រប់គ្រងហានិភ័យនៃការសងសឹក ការចូលរួមពីភាគីពាក់ព័ន្ធ និងការគ្រប់គ្រងពាក្យបណ្តឹងអ្នកប្រើប្រាស់។ នៅឆ្នាំ 2024 ទម្រង់នៃការបណ្តុះបណ្តាលនេះត្រូវបានពង្រីក និងផ្តល់ជូនដល់តំណាងចំនួន 100 នាក់ ដែលមកពីស្ថាប័ននានាទូទាំងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

63. នៅឆ្នាំ 2023, IFC ក៏បានចាប់ផ្តើមធ្វើការជាមួយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF) ហើយបានត្រួតពិនិត្យមើល និងពង្រឹងកម្មវិធីសិក្សារបស់កម្ពុជាស្តីពីការផ្តល់កម្ចីដោយការទទួលខុសត្រូវ ដែលកំណត់អំពីការអនុវត្តការផ្តល់ប្រាក់កម្ចី និងការទារបំណុលប្រកបដោយក្រមសីលធម៌។ កម្មវិធីសិក្សានេះ គឺជាមូលដ្ឋានសម្រាប់ការផ្តល់វិញ្ញាបនបត្រជាកំហិតដល់មន្ត្រីឥណទានកម្ពុជាចំនួន 65,000 នាក់ ដែលកំពុងបម្រើការងារនៅក្នុង BFIs។ កំណែដែលបានធ្វើបច្ចុប្បន្នភាពដែលរួមបញ្ចូលទាំងខ្លឹមសារស្តីពីការបង្ការ និងការគ្រប់គ្រងការសងសឹក ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងខែធ្នូ ឆ្នាំ 2025។ IFC នឹងបន្តកិច្ចសហការនេះ ដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើមបន្ថែមទៀតក្នុងការបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងបុគ្គលិកនៃ BFIs នៅក្នុងប្រទេសកម្ពុជា។

64. អតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ IFC បានស្វាគមន៍ចំពោះការផ្តល់ជូនរបស់ IFC ក្នុងការគាំទ្រដល់ការពង្រឹងយន្តការដោះស្រាយពាក្យបណ្តឹងអ្នកប្រើប្រាស់របស់ពួកគេ និងការជំរុញឱ្យមានយន្តការដោះស្រាយពាក្យបណ្តឹងតាមកម្រិតវិស័យ។ នៅក្នុងឆ្នាំ 2025 ពួកគេបានរាយការណ៍ថា អ្នកខ្ចីប្រាក់អាចចូលទៅប្រើប្រាស់យន្តការ CCMs របស់ពួកគេតាមរយៈបណ្តាញចម្រុះជាច្រើន ឧ. គេហទំព័រ ការអញ្ជើញទៅកាន់សាខាផ្ទាល់ ខ្សែទូរសព្ទទាន់ហេតុការណ៍ បណ្តាញសង្គម ឬអ៊ីមែល។ ពាក្យបណ្តឹងត្រូវបានចាត់ថ្នាក់ និងផ្តល់អាទិភាព ព្រមទាំងទាមទារឲ្យមានការទទួលស្គាល់ ការស៊ើបអង្កេត ការកត់ត្រាឯកសារឱ្យបានត្រឹមត្រូវ និងការបញ្ជូនបន្តទៅថ្នាក់លើតា

មតម្រូវការ។ យន្តការ CCMs ទាំងនេះ បានធ្វើការរាយការណ៍ជាទៀងទាត់ទៅកាន់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងស្ថាប័ននិយ័តករ។

65. ការសម្របសម្រួលលើដំណើរការដោះស្រាយពាក្យបណ្តឹងទាំង 18 ករណី តាមរយៈយន្តការ CCMs របស់អតិថិជនពាក់ព័ន្ធ នឹងផ្តល់ឱកាសដើម្បីធ្វើតេស្ត និងពិនិត្យឡើងវិញនូវយន្តការទាំងនេះ ដែលនឹងជួយកំណត់នូវការអនុវត្តល្អៗ ដែលត្រូវចែករំលែកក្នុងចំណោមអតិថិជនរបស់ IFC និងដៃគូក្នុងវិស័យនេះ។ មេរៀនដែលទទួលបានពីបទពិសោធនេះ អាចត្រូវបានចែករំលែកនៅក្នុងកម្មវិធីបណ្តុះបណ្តាល និងទម្រង់ការងារផ្សព្វផ្សាយដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីលើកកម្ពស់យន្តការដោះស្រាយពាក្យបណ្តឹងអ្នកប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជា។

66. អតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ IFC ក៏បានបង្ហាញចំណាប់អារម្មណ៍លើការកសាងសមត្ថភាពក្នុងការកំណត់អត្តសញ្ញាណកម្មសិទ្ធិដីធ្លីសហគមន៍របស់ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ដើម្បីជៀសវាងការទទួលយកប័ណ្ណកម្មសិទ្ធិដីធ្លីលក្ខណៈបុគ្គលជាទ្រព្យបញ្ចាំ ដែលមានទីតាំងជាន់គ្នាជាមួយដីរបស់ជនជាតិដើមភាគតិច។[30] IFC កំពុងសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីកសាងសមត្ថភាពដល់វិស័យហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធផ្សេងទៀត រួមទាំងលើប្រធានបទពាក់ព័ន្ធនឹងសិទ្ធិដីធ្លី ការចេញប័ណ្ណកម្មសិទ្ធិ និងភាពអាចរកបាននៃប្រព័ន្ធទិន្នន័យដីធ្លី ឬប្រព័ន្ធសម្រាប់ផ្ទៀងផ្ទាត់ប័ណ្ណកម្មសិទ្ធិសម្រាប់យកមកធ្វើជាទ្រព្យបញ្ចាំ។

## VII. ការគាំទ្ររបស់ IFC នៅកម្រិតវិស័យ និងកម្រិតនិយ័តកម្ម

67. ចាប់តាំងពីឆ្នាំ 2008 មក IFC បានធ្វើការតគលប់ឈរ ដើម្បីពង្រឹងការអនុវត្តមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា តាមរយៈគម្រោងសេវាកម្មប្រឹក្សាយោបល់ (AS) ជាច្រើន។[31] ការស៊ើបអង្កេតរបស់ CAO ទទួលស្គាល់ថា ការងាររបស់ IFC នៅកម្ពុជា ត្រូវបានផ្តល់ព័ត៌មានដោយការស្រាវជ្រាវ ការវិនិច្ឆ័យ និងវេទិកាពិភាក្សានានាកម្រិតវិស័យយ៉ាងទូលំទូលាយ ដែលបានកំណត់នូវហានិភ័យនៃកិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុក្នុងវិស័យនេះ ហើយក៏បានកោតសរសើរចំពោះតួនាទីរបស់ IFC ក្នុងការពង្រឹងកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជាផងដែរ។[32]

68. ការចូលរួមរបស់ IFC បានជំរុញឱ្យមានគំនិតផ្តួចផ្តើមផ្នែកឧស្សាហកម្មក្នុងការផ្តល់ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ ដើម្បីកែលម្អក្របខ័ណ្ឌនិយ័តកម្មស្តីពីកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជា ទាំងដោយផ្ទាល់ និងដោយប្រយោល។ IFC ធ្វើការយ៉ាងជិតស្និទ្ធជាមួយ NBC ដែលធ្វើនិយ័តកម្មវិស័យធនាគារ និងមើលខុសត្រូវលើការអភិវឌ្ឍវិស័យនេះ រួមទាំងបរិយាបន្នហិរញ្ញវត្ថុ និងកិច្ចការពារអ្នកប្រើប្រាស់។ សមាគមធនាគារនៅកម្ពុជា (ABC) ក្នុងនាមជាស្ថាប័នឧស្សាហកម្មផ្លូវការដែលតំណាងឱ្យធនាគារទាំងអស់ ដែលលើកកម្ពស់ការអនុវត្តការផ្តល់ប្រាក់កម្ចីប្រកបដោយសុចរិត កិច្ចការពារអ្នកប្រើប្រាស់ និងការដោះស្រាយពាក្យបណ្តឹង ក៏ដូចជាការពិភាក្សាគោលនយោបាយរួមនៅក្នុងវិស័យនេះ គឺជាដៃគូដ៏សំខាន់មួយទៀត។ IFC ក៏ធ្វើការជាមួយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) ដែលតំណាងឱ្យMFIs និងលើកកម្ពស់ការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ អក្ខរកម្មហិរញ្ញវត្ថុ និងចីរភាពនៃវិស័យនេះផងដែរ។

69. IFC (រួមជាមួយធនាគារពិភពលោក) មិនធ្វើការដោយឯកឯងនោះទេ ប៉ុន្តែបានសម្របសម្រួល និងសហការយ៉ាងជិតស្និទ្ធជាមួយ DFIs និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ ដៃគូទាំងនេះរួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB), Agence Française de Développement និង Financierings-Maatschappij voor Ontwikkelingslanden N.V (FMO) ជាដើម។ អង្គការសហប្រជាជាតិ (UN) ក៏បានចាប់ផ្តើមដើរតួនាទីយ៉ាងសំខាន់ឡើងជាលំដាប់នាពេលថ្មីៗនេះ ក្នុងការពង្រឹងការអភិវឌ្ឍប្រកបដោយចីរភាពនៃវិស័យហិរញ្ញវត្ថុកម្ពុជា។

---

[30] នៅឆ្នាំ 2024 បទប្បញ្ញត្តិដែលហាមឃាត់ការប្រើប្រាស់ដីធ្លីសហគមន៍ជនជាតិដើមភាគតិចជាទ្រព្យបញ្ចាំបានចូលជាធរមាន។ ទោះបីជាអតិថិជនមួយចំនួនបានរាយការណ៍ថា ICLTs ដែលត្រូវបានដាក់ជាទ្រព្យបញ្ចាំត្រូវបានប្រគល់ជូនវិញក៏ដោយ ក៏ពួកគេនៅតែជួបប្រទះបញ្ហាប្រឈមក្នុងការកំណត់អត្តសញ្ញាណការត្រួតគ្នានៃប័ណ្ណកម្មសិទ្ធិដីធ្លីបុគ្គល ដែលត្រូវបានដាក់ជាទ្រព្យបញ្ចាំជាមួយនឹង ICLTs ផងដែរ។

[31] AS ដែលបានផ្តល់ហិរញ្ញប្បទាន និងគាំទ្រដល់បរិយាបន្នហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជារួមមាន៖ AS #564187, #601954, #607528, #599902, #606119.

[32] ការស្រាវជ្រាវពាក់ព័ន្ធរួមមាន៖ ការវាយតម្លៃលើកិច្ចការពារអ្នកប្រើប្រាស់នៅកម្ពុជា (ក្រុមពិគ្រោះយោបល់ដើម្បីជួយជនក្រីក្រឆ្នាំ 2009), វេទិកាស្តីពីមីក្រូហិរញ្ញវត្ថុ និងវិបត្តិហិរញ្ញវត្ថុពិភពលោក (IFC 2009), របាយការណ៍ស្តីពីកិច្ចការពារ អ្នកប្រើប្រាស់ហិរញ្ញវត្ថុនៅកម្ពុជា (IFC 2015), របាយការណ៍ MIMOSA (2015), មីក្រូហិរញ្ញវត្ថុកម្ពុជា និងសុខុមាលភាពគ្រួសារ (WBG 2019), របាយការណ៍ MIMOSA (2019), ផលប៉ះពាល់នៃការកំណត់អត្រាការប្រាក់ទៅលើបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា (មូលនិធិរូបិយវត្ថុអន្តរជាតិ, 2021).

70. រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិនាដើមទសវត្សរ៍ឆ្នាំ 2000 ដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា បានលើកកម្ពស់តម្លាភាព ជំរុញចំណាប់អារម្មណ៍ពីវិស័យឯកជន និងដោះស្រាយហានិភ័យនៃបំណុលលើសលប់។ ទោះជាយ៉ាងណាក៏ដោយ ក្របខណ្ឌនេះមិនបានរួមបញ្ចូលនូវធាតុផ្សំសំខាន់ៗទាំងអស់ ដែលចាំបាច់សម្រាប់រចនាសម្ព័ន្ធកិច្ចការពារអ្នកប្រើប្រាស់ដ៏គ្រប់ជ្រុងជ្រោយនោះទេ។

71. ក្នុងន័យនេះ គម្រោង AS ដំបូងរបស់ IFC ដែលមានគោលបំណងពង្រឹងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវរបស់កម្ពុជា ត្រូវបានដាក់ឱ្យដំណើរការនៅឆ្នាំ 2008 ដើម្បីគាំទ្រដល់NBC ក្នុងការបង្កើតការិយាល័យឥណទានកម្ពុជា (CBC)។ ការបង្កើត និងការពង្រីកការិយាល័យឥណទាននៅក្នុងទីផ្សារដែលកំពុងរីកចម្រើនរបស់ IDA គឺជាសសរស្តម្ភមួយនៃការឆ្លើយតបរបស់ WBG ចំពោះវិបត្តិហិរញ្ញវត្ថុពិភពលោក។ នៅឆ្នាំ 2011 NBC បានបង្កើតក្របខណ្ឌបទប្បញ្ញត្តិជាមូលដ្ឋានសម្រាប់ប្រព័ន្ធរាយការណ៍ឥណទានគ្រប់ជ្រុងជ្រោយមួយ ដែលនាំទៅដល់ការបង្កើត CBC ហើយបានចេញបទប្បញ្ញត្តិមួយដើម្បីធានាឱ្យមានការអនុវត្តឥណទានប្រកបដោយភាពយុត្តិធម៌ តម្លាភាព សមហេតុផល និងការទទួលខុសត្រូវ រួមទាំងលក្ខខណ្ឌតម្រូវសម្រាប់ការបង្ហាញអំពីនីតិវិធីដំណើរការ លក្ខខណ្ឌ អត្រា និងថ្លៃសេវាផ្សេងៗ។ ជំហានទាំងនេះគឺជាជំហានដំបូងដ៏សំខាន់ ដោយសារប្រព័ន្ធព័ត៌មានឥណទាននៅលើពិភពលោក បានបង្ហាញថាវាមានសារៈសំខាន់ក្នុងការកាត់បន្ថយហានិភ័យ និងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងចីរភាព។

72. CBC បានចាប់ផ្តើមដំណើរការជាផ្លូវការនៅឆ្នាំ 2012។ ស្ថាប័ននេះធ្វើការប្រមូល និងចែករំលែកប្រវត្តិឥណទានរបស់អ្នកខ្ចីទៅដល់ស្ថាប័នផ្តល់កម្ចី ដើម្បីឱ្យការវាយតម្លៃលើប្រាក់កម្ចីអាចប្រព្រឹត្តទៅបានដោយការទទួលខុសត្រូវ ការកាត់បន្ថយបំណុលលើសលប់ និងជួយឱ្យអ្នកខ្ចីអាចទទួលបានឥណទានតាមលក្ខខណ្ឌដែលកាន់តែច្បាស់លាស់ កាន់តែយុត្តិធម៌ និងកាន់តែមានតម្លាភាព។ ការិយាល័យឥណទាននេះត្រូវបានទទួលស្គាល់ថាជាករណីសិក្សាដ៏វិជ្ជមានមួយ នៅក្នុងមគ្គុទេសក៍ចំណេះដឹងស្តីពីការរាយការណ៍ឥណទានរបស់ IFC នៅឆ្នាំ 2012 ហើយត្រូវបានចាត់ទុកថាជាគំរូនៃការអនុវត្តល្អបំផុតនៅក្នុងទ្វីបអាស៊ី។[33] ដោយមានការគាំទ្រជាបន្តបន្ទាប់ពី IFC បច្ចុប្បន្ន CBC កំពុងបម្រើដល់
អ្នកខ្ចីប្រាក់ចំនួន 5.04 លាននាក់ ដែលគ្របដណ្តប់ប្រហែលពាក់កណ្តាលនៃចំនួនប្រជាជនពេញវ័យរបស់ប្រទេសនេះ។ មូលដ្ឋានទិន្នន័យរបស់ស្ថាប័ននេះ រួមមានអង្គភាពអាជីវកម្មជិត 2,000 និងទទួលបានទិន្នន័យពីស្ថាប័នសមាជិកចំនួន 199 ស្ថាប័ន ដូចជាធនាគារ MFIs និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។

73. នៅឆ្នាំ 2013, Smart Campaign បានដាក់ឱ្យដំណើរការកម្មវិធីវិញ្ញាបនបត្រការពារអតិថិជនជាសកលរបស់ខ្លួន ដែល CMA បានជួយនាំយកមកអនុវត្តភ្លាមៗនៅក្នុងប្រទេសកម្ពុជា។ កម្មវិធីផ្តល់វិញ្ញាបនបត្រនេះ គឺជាស្ម័គ្រចិត្ត និងត្រូវបានទទួលស្គាល់ជាសកល ដែលវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រដល់អ្នកផ្តល់សេវាហិរញ្ញវត្ថុស្តីពីអនុលោមភាពរបស់ពួកគេតាមគោលការណ៍ការពារអតិថិជន។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ 2024 ស្ថាប័ន Cerise+SPTF បានលើកឡើងពីសមិទ្ធផលរបស់ប្រទេសក្នុងការដាក់ឱ្យអនុវត្តគោលការណ៍ការពារអតិថិជននៅថ្នាក់ជាតិ។[34] គ្រឹះស្ថានហិរញ្ញវត្ថុកម្ពុជាចំនួនប្រាំមួយ ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងរបស់ CAO សុទ្ធតែទទួលបានវិញ្ញាបនបត្រក្នុងចន្លោះឆ្នាំ 2015 ដល់ឆ្នាំ 2021។ នៅក្នុងឆ្នាំ 2025 គ្រឹះស្ថានអិលអូអិលស៊ី, អម្រឹត, អេស៊ីលីដា និងស្ថាបនាបានធ្វើបច្ចុប្បន្នភាពវិញ្ញាបនបត្ររបស់ពួកគេ និងទទួលបានកម្រិតវិញ្ញាបនបត្រខ្ពស់បំផុត (កម្រិតមាស)។

74. កង្វល់អំពីបំណុលលើសលប់ និងការឡើងកម្តៅនៃទីផ្សារ ដែលទាក់ទងទៅនឹងអត្រាកំណើនខ្ពស់ ការកើនឡើងនៃទំហំកម្ចី និងការខ្ចីប្រាក់ពីស្ថាប័នច្រើនកន្លែងដោយអ្នកប្រើប្រាស់បានចាប់ផ្តើមកើនឡើងនៅឆ្នាំ 2013។ ដោយមានការគាំទ្រពី IFC ទីភ្នាក់ងារអភិវឌ្ឍន៍អូទ្រីស, FMO, Incofin និង Proparco សមាគម CMA បានដាក់ឱ្យដំណើរការនូវសំណុំនៃគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវនៅឆ្នាំ 2016 ដែលផ្តល់នូវក្របខណ្ឌគ្រប់គ្រងដោយខ្លួនឯង ដើម្បីចៀសវាងប្រភេទនៃការអនុវត្តនានាដែលងាយបំផុតនឹងនាំឱ្យអ្នកប្រើប្រាស់មានបំណុលលើសលប់។ គោលការណ៍ណែនាំដំបូងត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ 2018 ជាមួយនឹងការឯកភាពគ្នារបស់សមាជិក CMA ដើម្បីកំណត់កម្ចីដែលមាន "ហានិភ័យខ្ពស់" ដូចជាកម្ចីសម្រាប់បុនហិរញ្ញប្បទានជាដើម។ បច្ចុប្បន្ន CBC ផលិតផ្ទាំងគ្រប់គ្រងប្រចាំខែនៃសូចនាករដែលអាចផ្ទៀងផ្ទាត់បាន ដូចជាកម្ចីច្រើនកន្លែង និងសមាមាត្រកម្ចីធៀបនឹងចំណូល ដើម្បីធានាបាននូវការត្រួតពិនិត្យដោយឯករាជ្យលើការគោរពតាមគោលការណ៍ណែនាំដោយអ្នកផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុ។

[33] IFC, 2012, មគ្គុទេសក៍ចំណេះដឹងស្តីពីការរាយការណ៍ឥណទាន, អាចចូលមើលបានតាមរយៈគេហទំព័រ https://openknowledge.worldbank.org/entities/publication/bfe6e031-7a02-55e0-ad45-235b268facf5

[34] Cerise+SPTF, 2025, ផ្លូវឆ្ពោះទៅរកការការពារអតិថិជន, របាយការណ៍ប្រចាំឆ្នាំ 2024, អាចចូលមើលបាននៅលើគេហទំព័រ https://cerise-sptf.org/wp-content/uploads/2025/07/CP-Pathway-Annual-Report-2024.pdf

75. នៅឆ្នាំ 2017 NBC បានចាត់វិធានការបន្ថែម រួមទាំងការចេញបទប្បញ្ញត្តិស្តីពីការកំណត់អត្រាការប្រាក់ខ្ពស់បំផុត 18 ភាគរយក្នុងមួយឆ្នាំ លើប្រាក់កម្ចីដែលផ្តល់ដោយ BFIs គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងប្រតិបត្តិករភតិសន្យាហិរញ្ញវត្ថុ ដោយមានគោលបំណងទប់ស្កាត់ការកំណត់តម្លៃបែបកេងប្រវ័ញ្ច។ ថ្លៃខ្ពស់បំផុតនេះបានអនុវត្តចំពោះប្រាក់កម្ចីថ្មី ប្រាក់កម្ចីដែលបានរៀបចំឡើងវិញ និងប្រាក់កម្ចីបុនហិរញ្ញប្បទាន។

76. NBC ក៏បានចេញបទប្បញ្ញត្តិស្តីពីការដោះស្រាយពាក្យបណ្តឹងអ្នកប្រើប្រាស់ ដែលបានបង្កើតប្រព័ន្ធពីរដំណាក់កាលសម្រាប់ការដោះស្រាយពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ។ ដំណាក់កាលទីមួយ អ្នកប្រើប្រាស់ត្រូវដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុនោះ។ បន្ទាប់មក ប្រសិនបើអ្នកប្រើប្រាស់មិនយល់ស្របនឹងការសម្រេចចិត្តរបស់គ្រឹះស្ថាននោះទេ អ្នកប្រើប្រាស់ និង/ឬគ្រឹះស្ថាននោះ អាចស្នើសុំឱ្យ NBC ធ្វើការពិនិត្យឡើងវិញជាផ្លូវការ។ CMA និង ABC បានបង្កើតខ្សែទូរសព្ទទាន់ហេតុការណ៍សម្រាប់ទទួលពាក្យបណ្តឹងដាច់ដោយឡែកពីគ្នានៅឆ្នាំ 2018 ដើម្បីបំពេញបន្ថែមដល់ប្រព័ន្ធពីរដំណាក់កាលនេះ។

77. ការផ្ទុះឡើងនៃជំងឺរាតត្បាតក្នុងខែមីនា ឆ្នាំ 2020 បានជះឥទ្ធិពលយ៉ាងខ្លាំងលើសេដ្ឋកិច្ចកម្ពុជា ដែលបណ្តាលឱ្យមានកំណើន GDP អវិជ្ជមាន ព្រមទាំងមានផលប៉ះពាល់បន្តលើអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ អ្នកខ្ចីប្រាក់ដែលបាត់បង់ការងារ ឬរងផលប៉ះពាល់ដោយសារការរឹតត្បិតលើការធ្វើដំណើរ និងសកម្មភាពសេដ្ឋកិច្ច ដែលយល់ថាវាមានការលំបាកក្នុងការសងប្រាក់កម្ចីរបស់ពួកគេ។ ម្ចាស់បណ្តឹងទាំងអស់សុទ្ធតែត្រូវបានរងផលប៉ះពាល់ ទាំងដោយផ្ទាល់ ឬដោយប្រយោលពីជំងឺរាតត្បាតនេះ។

78. NBC បានដាក់ចេញនូវវិធានការនានា ដើម្បីធានានូវភាពធន់ និងស្ថិរភាពនៃវិស័យធនាគារ រួមទាំងលក្ខខណ្ឌតម្រូវឱ្យគ្រឹះស្ថានហិរញ្ញវត្ថុធ្វើការរៀបចំកម្ចីឡើងវិញជូនដល់អ្នកខ្ចីដែលរងផលប៉ះពាល់ពីជំងឺរាតត្បាត COVID-19។ យោងតាម NBC គ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជាបានធ្វើការរៀបចំកម្ចីឡើងវិញដែលមានទំហំទឹកប្រាក់ប្រមាណ $4.2 ពាន់លានដុល្លារអាមេរិក សម្រាប់អ្នកខ្ចីប្រាក់ចំនួន 285,074 នាក់ ក្នុងឆ្នាំ 2020 និងប្រមាណ $5.5 ពាន់លានដុល្លារអាមេរិក សម្រាប់អ្នកខ្ចីប្រាក់ចំនួន 367,239 នាក់ គិតត្រឹមឆមាសទីមួយនៃឆ្នាំ 2021។[35] វិស័យមីក្រូហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោកក្នុងការជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ច តាមរយៈការផ្តល់ជំនួយសាច់ប្រាក់ដល់សហគ្រាសធុនមីក្រូ និងសហគ្រាសខ្នាតតូចដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាត។

79. ចាប់តាំងពីពេលនោះមក វិស័យនេះបានបន្តពង្រឹងបរិយាកាសសម្រាប់កិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដើម្បីឆ្លើយតបទៅនឹងការប្រឈមនឹងកង្វល់ដែលនៅបន្តកើតមាន រួមទាំងកង្វល់ដែលត្រូវបានលើកឡើងនៅក្នុងការស៊ើបអង្កេតអនុលោមភាពរបស់ CAO។ ក្រោមការដឹកនាំរបស់វិស័យនេះ និងដោយមានការគាំទ្រពី NBC រួមទាំងជំនួយគាំទ្រពី IFC វិធានការបន្ថែមត្រូវបានដាក់ឱ្យអនុវត្តដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងក្រមសីលធម៌វិជ្ជាជីវៈ ដែលរួមមានការអនុវត្តលើការផ្តល់ប្រាក់កម្ចី និងការទារបំណុល តម្លាភាព និងការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិចជាទ្រព្យបញ្ចាំសម្រាប់កម្ចី។

80. នៅឆ្នាំ 2022, ABC, CMA និងសមាគមហិរញ្ញវត្ថុ និងបច្ចេកវិទ្យាកម្ពុជា (CAFT) បានដាក់ឱ្យដំណើរការជាផ្លូវការនូវក្រមសីលធម៌សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលបានកែសម្រួលថ្មី និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រាក់កម្ចីដែលត្រូវបានធ្វើបច្ចុប្បន្នភាពដោយបញ្ចូលនូវគោលការណ៍ និងស្តង់ដាដែលបានធ្វើបច្ចុប្បន្នភាព ព្រមទាំងដាក់ឱ្យមានកម្មវិធីវិញ្ញាបនបត្រផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវជាកាតព្វកិច្ច ដែលមន្ត្រីផ្តល់ប្រាក់កម្ចីទាំងអស់ពី BFIs ត្រូវតែចូលរួម និងទទួលបានវិញ្ញាបនបត្រ (សូមមើលកថាខណ្ឌទី 82 ខាងក្រោម)។ ក្រមប្រតិបត្តិ និងកម្មវិធីវិញ្ញាបនបត្រនេះកំណត់នូវការអនុវត្តប្រកបដោយក្រមសីលធម៌សម្រាប់ការផ្តល់ប្រាក់កម្ចី និងការទារបំណុល រួមទាំងលក្ខខណ្ឌតម្រូវក្នុងការវាយតម្លៃឱ្យបានហ្មត់ចត់នូវលទ្ធភាពសងបំណុលរបស់អ្នកខ្ចី និងការទប់ស្កាត់ការដាក់សម្ពាធហួសហេតុដើម្បីឱ្យសងបំណុលជាដើម។

81. ចាប់តាំងពីខែមករា ឆ្នាំ 2023 មក តាមរយៈសេចក្តីសម្រេចរបស់ NBC គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ដែលជាសមាជិករបស់ ABC និង CMA ត្រូវបានតម្រូវឱ្យដាក់បញ្ចូលលក្ខខណ្ឌកិច្ចសន្យាស្តង់ដានៅក្នុងកិច្ចសន្យាប្រាក់កម្ចីរបស់ពួកគេជាមួយអ្នកខ្ចី។ កិច្ចសន្យាប្រាក់កម្ចីស្តង់ដានេះ រួមមានលក្ខខណ្ឌសំខាន់ៗដែលទាក់ទងនឹងរយៈពេលជាប់កិច្ចសន្យា រយៈពេលជូនដំណឹងសម្រាប់ការសងប្រាក់កម្ចីមុនកាលកំណត់ក្នុងអំឡុងពេលជាប់កិច្ចសន្យា និងនីតិវិធីនៃការដោះលែងទ្រព្យបញ្ចាំបន្ទាប់ពីការសងប្រាក់កម្ចីរួចរាល់។ កិច្ចសន្យាទាំងនេះក៏រួមបញ្ចូលផងដែរនូវលេខទំនាក់ទំនងរបស់ផ្នែក CCM នៃ BFIs រៀងៗខ្លួន ក៏ដូចជាលេខខ្សែទូរសព្ទទាន់ហេតុការណ៍សម្រាប់យ

[35] ខ្មែរថាមស៍, ថ្ងៃទី 31 ខែកក្កដា ឆ្នាំ 2021, កម្ពុជារៀបចំកម្ចីឡើងវិញទំហំ $5.5 ពាន់លានដុល្លារ ដើម្បីសម្រាលបន្ទុកប្រជាជន, អាចចូលមើលបាននៅលើគេហទំព័រ៖ https://www.khmertimeskh.com/50905311/cambodia-restructures-5-5-billion-worth-of-loans-to-ease-peoples-burden/?utm_source=chatgpt.com

ន្តការដោះស្រាយពាក្យបណ្តឹងអតិថិជនកម្រិតវិស័យទាំងមូល។ កិច្ចសន្យាគំរូទាំងនេះ គឺជាសមិទ្ធផលដ៏សំខាន់មួយក្នុងការពង្រឹងអក្ខរកម្មហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។[36]

82. នៅឆ្នាំ 2023 ដូចគ្នាដែរ IBF នៅកម្ពុជាបានក្លាយជាស្ថាប័នផ្តល់វិញ្ញាបនបត្រសម្រាប់កម្មវិធីវិញ្ញាបនបត្រផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវរបស់ CMA និង ABC។ ការទទួលបានវិញ្ញាបនបត្រនេះបានក្លាយជាកាតព្វកិច្ចសម្រាប់មន្ត្រីឥណទាន និងបុគ្គលិកដែលពាក់ព័ន្ធទាំងអស់ត្រឹមដំណាច់ឆ្នាំ 2025។ យោងតាមសមាគម CMA ត្រឹមដំណាច់ឆ្នាំ 2023 មន្ត្រីឥណទាន និងបុគ្គលិកដែលពាក់ព័ន្ធប្រមាណ 76 ភាគរយ មកពីគ្រឹះស្ថានសមាជិកបានប្រឡងជាប់កម្មវិធីវិញ្ញាបនបត្រនេះដោយជោគជ័យ។ ចាប់តាំងពីឆ្នាំ 2024 មក IFC បានចូលរួមចំណែកក្នុងការកែសម្រួលកម្មវិធីសិក្សារបស់កម្មវិធីនេះជាមួយ IBF។ នៅខែធ្នូ ឆ្នាំ 2025 កំណែដែលបានធ្វើបច្ចុប្បន្នភាព ដែលមានការណែនាំជាក់លាក់ស្តីពីការគ្រប់គ្រងការគំរាមកំហែង និងការសងសឹក ការដោះស្រាយពាក្យបណ្តឹងអ្នកប្រើប្រាស់ និងការអនុវត្តល្អបំផុតក្នុងការទារបំណុលត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

83. នៅខែសីហា ឆ្នាំ 2024, CMA និង ABC បានប្រកាសដាក់ចេញនូវច្បាប់ថ្មី ដើម្បីដោះស្រាយហានិភ័យនៃការកេងប្រវ័ញ្ចលើសហគមន៍ជនជាតិដើមភាគតិច ដោយទប់ស្កាត់ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិចជាទ្រព្យបញ្ចាំសម្រាប់ប្រាក់កម្ចី។ បច្ចុប្បន្ន BFIs ត្រូវបានលើកទឹកចិត្តឱ្យផ្តល់ឥណទានថ្មីដល់បុគ្គល និងសហគមន៍ជនជាតិដើមភាគតិច តាមរយៈវិធីសាស្ត្រផ្តល់ប្រាក់កម្ចីដោយមិនប្រើប្រាស់ទ្រព្យបញ្ចាំ។ សមាគម CMA និង ABC ក៏បានណែនាំផងដែរឱ្យមានការរៀបចំកម្ចីឡើងវិញជូនដល់អតិថិជនចាស់ ដែលរងផលប៉ះពាល់ដោយសារការផ្លាស់ប្តូរនេះ ដូចជាអ្នកដែលកំពុងប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិចរបស់ពួកគេជាទ្រព្យបញ្ចាំស្រាប់ជាដើម។ ដើម្បីឆ្លើយតបទៅនឹងពាក្យបណ្តឹងរបស់ CAO ស្ថាប័ន IFC បានទាក់ទងទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីគាំទ្រដល់ការពង្រឹងសមត្ថភាពរបស់វិស័យហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងដំណើរការនៃការចេញប័ណ្ណកម្មសិទ្ធិដីធ្លី និងបញ្ជីចុះឈ្មោះដីធ្លីរបស់ប្រទេស។

84. ចំណុចសំខាន់គឺថា នៅខែវិច្ឆិកា ឆ្នាំ 2024 ជាលទ្ធផលនៃការងារប្រឹក្សាយោបល់របស់ IFC, NBC បានបង្កើតអគ្គនាយកដ្ឋានថ្មីមួយគឺ អគ្គនាយកដ្ឋានបរិយាបន្នហិរញ្ញវត្ថុ និងបទប្បញ្ញត្តិ ដែលក្នុងនោះក៏មាននាយកដ្ឋានការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុថ្មីមួយដែលបម្រើការពេញម៉ោងផងដែរ។ ការបង្កើតនេះស្របទៅនឹងការអនុវត្តជាទូទៅក្នុងចំណោមធនាគារកណ្តាលអាស៊ី។ ស្ថាប័នថ្មីនេះមានគោលបំណងបញ្ចប់សេចក្តីព្រាងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំស្តីពីកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមដានការអនុវត្តរបស់តួអង្គក្នុងទីផ្សារ ព្រមានអ្នកប្រើប្រាស់អំពីហានិភ័យដែលកំពុងកើតមាន ធ្វើការត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុទាំងនៅនឹងទីតាំង និងក្រៅទីតាំង ព្រមទាំងដាក់ទណ្ឌកម្មទៅលើគ្រឹះស្ថានដែលមិនមានអនុលោមភាព។ IFC បានផ្តល់ការបណ្តុះបណ្តាលបឋមដល់ក្រុមការងារនេះស្តីពីការអនុវត្តកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ។

85. កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតកំពុងត្រូវបានអនុវត្ត ដើម្បីពង្រឹងយន្តការដោះស្រាយពាក្យបណ្តឹងអ្នកប្រើប្រាស់ក្នុងកម្រិតវិស័យទាំងមូលសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ NAADR ត្រូវបានបង្កើតឡើងនៅខែវិច្ឆិកា ឆ្នាំ 2023 និងបានចាប់ផ្តើមដំណើរការនៅខែមីនា ឆ្នាំ 2024។ អាណត្តិរបស់ NAADR គឺផ្តល់នូវការសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការសម្រាប់វិវាទផ្នែករដ្ឋប្បវេណី ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ដោយកាត់បន្ថយភាពកកស្ទះនៃសំណុំរឿងនៅតុលាការ និងធ្វើការចេញនូវការសម្រុះសម្រួលដែលមានលក្ខណៈចងកាតព្វកិច្ចតាមផ្លូវច្បាប់។ នៅក្នុងវិស័យហិរញ្ញវត្ថុ NAADR ផ្តល់សេវាសម្រុះសម្រួលដោយឥតគិតថ្លៃសម្រាប់វិវាទដែលទាក់ទងនឹងប្រាក់កម្ចី ហើយកំពុងសហការជាមួយ ABC និង CMA ដើម្បីពង្រឹងការដោះស្រាយពាក្យបណ្តឹង និងកសាងសមត្ថភាពសម្រាប់ការដោះស្រាយវិវាទផ្នែកហិរញ្ញវត្ថុ។

[36] ទោះបីជា IFC ឬអតិថិជន និងអតិថិជនរងរបស់ IFC មិនមានសិទ្ធិចូលមើលកិច្ចសន្យាប្រាក់កម្ចីរបស់ម្ចាស់បណ្តឹងទាំង 18 នាក់នោះក៏ដោយ កិច្ចសន្យាទាំងនោះត្រូវបានធ្វើឡើងមុនឆ្នាំ 2023 ដូច្នេះទំនងជាមិនមានដាក់បញ្ចូលនូវបទប្បញ្ញត្តិស្តង់ដាទាំងនេះទេ។

86. FCC ត្រូវបានបង្កើតឡើងនៅខែមករា ឆ្នាំ 2025 ដែលជាលទ្ធផលស្នូលនៃគម្រោងប្រឹក្សាយោបល់របស់ IFC។ FCC គឺជាស្ថាប័នឯករាជ្យមួយដែលមានតួនាទីទទួលខុសត្រូវលើការដោះស្រាយពាក្យបណ្តឹង ការផ្តល់ប្រឹក្សា និងការរកដំណោះស្រាយសម្រាប់សំណួរទូទៅផ្នែកធនាគារ និងហិរញ្ញវត្ថុ កង្វល់ពាក់ព័ន្ធនឹងការទូទាត់តាមប្រព័ន្ធឌីជីថល ក៏ដូចជាការផ្សព្វផ្សាយ និងការអប់រំដល់អ្នកប្រើប្រាស់។ FCC ក៏ត្រូវបានរំពឹងទុកថានឹងដើរតួជាលេខាធិការដ្ឋាននៃអ្នកស៊ើបអង្កេតបណ្តឹងហិរញ្ញវត្ថុនាពេលអនាគតផងដែរ។ លទ្ធផលពីខែមករាដល់ខែកញ្ញា ឆ្នាំ 2025 បង្ហាញថា FCC បានទទួលពាក្យបណ្តឹងពីអ្នកប្រើប្រាស់ចំនួន 276 ករណី ដែលក្នុងនោះ 81 ភាគរយត្រូវបានដោះស្រាយរួចរាល់។ បញ្ហាចម្បងដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងទាំងនេះ គឺទាក់ទងនឹងលទ្ធភាព និងនីតិវិធីនៃការសងបំណុល បញ្ហាប្រឈមក្នុងការសងបំណុល និងឱកាសក្នុងការរៀបចំប្រាក់កម្ចីឡើងវិញ។[37] IFC នឹងបន្តគាំទ្រដល់ FCC ក្នុងការអនុវត្តអាណត្តិស្នូលរបស់ខ្លួន។

87. នៅក្នុងឆ្នាំខាងមុខៗទៀត កិច្ចខិតខំប្រឹងប្រែងរបស់ IFC នឹងមានគោលបំណងដើម្បី (i) លើកកម្ពស់ការប្រមូល និងការវិភាគទិន្នន័យ ព្រមទាំងការរាយការណ៍ឥណទានរួមបញ្ចូលគ្នាតាមរយៈ CBC (ii) បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងជាសាធារណៈសម្រាប់ FCC (iii) ពង្រឹងប្រព័ន្ធគ្រប់គ្រងករណី និងប្រព័ន្ធបញ្ជូនបន្តសម្រាប់ពាក្យបណ្តឹង (iv) ផ្តល់អនុសាសន៍ជូន NBC លើការពង្រឹងមុខងារត្រួតពិនិត្យរបស់ខ្លួន (v) កសាងសមត្ថភាពរបស់អ្នកចូលរួមក្នុងទីផ្សារលើការអប់រំអ្នកប្រើប្រាស់ ការប្រតិបត្តិទីផ្សារប្រកបដោយការទទួលខុសត្រូវ ការទារបំណុលប្រកបដោយក្រមសីលធម៌ និងយុត្តិធម៌ ការគ្រប់គ្រងពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ និងយន្តការដោះស្រាយពាក្យបណ្តឹង (vi) រៀបចំសម្រាប់ការបង្កើតស្ថាប័នអ្នកស៊ើបអង្កេតបណ្តឹងហិរញ្ញវត្ថុ និង (vii) បន្តពង្រឹងសមត្ថភាពស្វ័យបទប្បញ្ញត្តិ របស់ ABC និង CMA។

88. បច្ចុប្បន្ន FCC កំពុងទទួលបានការគាំទ្រលើការកសាងសមត្ថភាពពីធនាគារអភិវឌ្ឍន៍អូទ្រីស តាមរយៈវិទ្យាស្ថានកសាងការឯកភាព ដែលជាក្រុមហ៊ុនជំនាញផ្នែកសម្របសម្រួល/សម្រុះសម្រួលរបស់សហរដ្ឋអាមេរិក។ នៅខែវិច្ឆិកា ឆ្នាំ 2025, ADB បានអនុម័តឥណទានផ្អែកលើគោលនយោបាយដើម្បីពង្រឹងវិស័យហិរញ្ញវត្ថុរបស់កម្ពុជា រួមទាំងស្ថាប័ន FCC ផងដែរ។ ថ្មីៗនេះ IFC បានសម្របសម្រួលការបណ្តុះបណ្តាលស្តីពីការដោះស្រាយវិវាទ ដែលធ្វើឡើងដោយអ្នកជំនាញនៃស្ថាប័ន CAO។ NAADR ដែលផ្តល់សេវាដោះស្រាយវិវាទ កំពុងទទួលបានការគាំទ្រពីស្ថាប័ន FMO និងអង្គការ Oxfam។

89. ការចាប់ផ្តើមដំណើរការនៃយន្តការ FCC និង NAADR គឺជាគោលដៅសំខាន់ក្នុងការកសាងរចនាសម្ព័ន្ធបំពេញមុខងារពេញលេញសម្រាប់ដំណោះស្រាយពាក្យបណ្តឹងផ្នែកសេវាហិរញ្ញវត្ថុ ដែលស្របទៅនឹងការអនុវត្តឧត្តមានុវត្តន៍ល្អ (សូមមើលផងដែរនូវរូបទី 1)។ ជាដំណាក់កាលទីមួយ អ្នកខ្ចីប្រាក់អាចផ្ញើកង្វល់របស់ពួកគេទៅកាន់ផ្នែក CCM នៃគ្រឹះស្ថានហិរញ្ញវត្ថុពាក់ព័ន្ធ។ បន្ទាប់មក ប្រសិនបើមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គ្រឹះស្ថាននោះទេ ពួកគេអាចជ្រើសរើសប្រើប្រាស់យន្តការដោះស្រាយពាក្យបណ្តឹង ដែលអាចទទួលបានតាមរយៈខ្សែទូរសព្ទទាន់ហេតុការណ៍ របស់ NBC ឬ FCC។ លើសពីនេះទៅទៀត អ្នកខ្ចីប្រាក់ក៏អាចដាក់ទៅរកសេវាសម្រុះសម្រួល ឬទៅរកអ្នកស៊ើបអង្កេតបណ្តឹងហិរញ្ញវត្ថុនៅពេលអនាគតបានផងដែរ។ ជាចុងក្រោយ នីតិវិធីមជ្ឈត្តកម្ម ឬនីតិវិធីតុលាការក៏នឹងមានសម្រាប់អ្នកខ្ចីប្រាក់ផងដែរ ប្រសិនបើពួកគេមិនពេញចិត្តនឹងលទ្ធផលនៃសេវាសម្រុះសម្រួល។ រចនាសម្ព័ន្ធនេះ ជាពិសេសសេវាកម្មរបស់ FCC និង NAADR មិនទាន់មានសម្រាប់ម្ចាស់បណ្តឹងនៅក្នុងឆ្នាំ 2022 នៅពេលដែលពួកគេដាក់ពាក្យបណ្តឹងទៅកាន់ CAO ដោយផ្ទាល់នោះទេ ប៉ុន្តែបច្ចុប្បន្នសេវាកម្មទាំងនេះមានសម្រាប់ពួកគេ ក៏ដូចជាសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា។

## VIII. កិច្ចសហប្រតិបត្តិការរបស់ IFC ជាមួយដៃគូអភិវឌ្ឍន៍

90. បន្ថែមលើវិធានការដែលបានអនុវត្តខាងលើ NBC និងអង្គការ UN បានសហការគ្នារៀបចំដំណើរការពិគ្រោះយោបល់ពហុភាគីពាក់ព័ន្ធស្តីពីវិស័យមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា នៅខែវិច្ឆិកា ឆ្នាំ 2023 ដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅក្នុងវិស័យហិរញ្ញវត្ថុ រួមទាំងបញ្ហាបំណុលលើសលប់ផងដែរ។ ក្រោមការដឹកនាំរបស់ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិ (UNRC) ប្រចាំកម្ពុជា ភាគីពាក់ព័ន្ធដែលតំណាងឱ្យក្រុម និងស្ថាប័នចំនួន 100 ផ្សេងគ្នា ត្រូវបានអញ្ជើញមកពិគ្រោះយោបល់ ដែលរួមមានតំណាងមកពីរាជរដ្ឋាភិបាល ស្ថាប័ននិ

[37] មជ្ឈមណ្ឌលអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៃកម្ពុជា, របាយការណ៍ខែមករា – ខែកញ្ញា ឆ្នាំ 2025។

យ័តករ BFIs សមាគមនានា វិនិយោគិន សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នស្រាវជ្រាវ (Think tanks) និងដៃគូអភិវឌ្ឍន៍ រួមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិផងដែរ។[38]

91. IFC ចូលរួម និងសហការយ៉ាងសកម្មនៅក្នុងដំណើរការនេះ។ នៅឆ្នាំ 2024 គំនិតផ្តួចផ្តើមរបស់ NBC-UN បានកំណត់នូវសកម្មភាពអាទិភាពចំនួន 22 ដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅក្នុងវិស័យនេះ។[39] យោងតាមការរាយការណ៍នៅខែកញ្ញា ឆ្នាំ 2025 បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់ពហុភាគីរវាង NBC-UN លើកទីបី សកម្មភាពអាទិភាពចំនួនដប់ត្រូវបានបញ្ចប់ ហើយសកម្មភាពចំនួនដប់ពីរទៀតកំពុងស្ថិតក្នុងដំណាក់កាលអនុវត្ត ដែលគ្របដណ្តប់លើវិស័យសំខាន់ៗចំនួនប្រាំ៖

(i) **និយ័តកម្ម និងការមើលខុសត្រូវ៖** ក្រមសីលធម៌ដែលមានគោលការណ៍កំណត់តម្លៃប្រកបដោយការទទួលខុសត្រូវ ត្រូវបានបញ្ចប់នៅឆ្នាំ 2023 គម្រោងបង្កើតមូលនិធិវិស័យនឹងត្រូវចាប់ផ្តើម ដើម្បីផ្តល់ហិរញ្ញប្បទានដល់សកម្មភាពអក្ខរកម្មហិរញ្ញវត្ថុ ការផ្តល់ប្រឹក្សាអំពីបំណុល និងសកម្មភាពលើកកម្ពស់ការយល់ដឹងដល់អ្នកប្រើប្រាស់ រួមជាមួយការងារបន្តលើការបង្កើតក្របខ័ណ្ឌលើកទឹកចិត្តសម្រាប់ការផ្តល់ប្រាក់កម្ចីប្រកបដោយការទទួលខុសត្រូវ និងការតាមដានអនុលោមភាព។

(ii) **ការការពារអ្នកខ្ចីប្រាក់៖** FCC ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងពាក្យបណ្តឹង ដែលមានយន្តការផ្សេងៗទៀតមកបំពេញបន្ថែម ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុកំពុងត្រូវបានពង្រឹង ហើយយុទ្ធនាការអក្ខរកម្មហិរញ្ញវត្ថុនៅទូទាំងប្រទេសកំពុងត្រូវបានពង្រីកជាបន្តបន្ទាប់។

(iii) **ទិន្នន័យ៖** ភាគីពាក់ព័ន្ធកំពុងអភិវឌ្ឍគំរូនៃការចែករំលែកទិន្នន័យហាយប្រ៊ីតរវាងស្ថាប័ននិយ័តករធនាគារ BFIs និងស្ថាប័នមិនមែនធនាគារ ដើម្បីពង្រឹងការផ្តល់កម្ចីប្រកបដោយការទទួលខុសត្រូវ លើសពីនេះ និយមន័យស្តង់ដាសម្រាប់មីក្រូឥណទានក៏កំពុងស្ថិតក្នុងដំណាក់កាលបញ្ចប់ការពិនិត្យផងដែរ។

(iv) **ការផ្តល់ប្រាក់កម្ចីក្រៅប្រព័ន្ធ និងអាជ្ញាធរមូលដ្ឋាន៖** សេចក្តីថ្លែងការណ៍រួមមួយត្រូវបានចេញផ្សាយ ដើម្បីជំរុញកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ និងកំណត់គោលដៅការអនុវត្តការផ្តល់ប្រាក់កម្ចីខុសច្បាប់ ប្រព័ន្ធគ្រប់គ្រងប័ណ្ណកម្មសិទ្ធិដីធ្លីតាមប្រព័ន្ធអនឡាញកំពុងត្រូវបានពង្រីក ហើយភាគីពាក់ព័ន្ធបានផ្តល់អនុសាសន៍ឱ្យមានការសាកល្បងនូវគំរូកម្ចីផ្អែកលើសហគមន៍ ដើម្បីកាត់បន្ថយការពឹងផ្អែកលើការខ្ចីប្រាក់តាមប្រព័ន្ធក្រៅផ្លូវការ។

(v) **ការធានារ៉ាប់រង និងហិរញ្ញប្បទានជំនួស៖** កិច្ចខិតខំប្រឹងប្រែងកំពុងត្រូវបានធ្វើឡើង ដើម្បីពង្រីកលទ្ធភាពទទួលបានឥណទាន និងការការពារហានិភ័យសម្រាប់កសិករខ្នាតតូច តាមរយៈសហករណ៍កសិកម្មបែបទំនើប និងផលិតផលធានារ៉ាប់រងដែលមានបរិយាបន្ន គំរូនៃការចែករំលែកថ្លៃដើមក៏កំពុងស្ថិតក្រោមការពិភាក្សាផងដែរ ដើម្បីធ្វើឱ្យកសិករកាន់តែមានលទ្ធភាពទទួលបានសេវាទាំងនេះក្នុងតម្លៃសមរម្យ។

92. ជាផ្នែកមួយនៃដំណើរការ NBC-UN និងស្របតាមតួនាទីរបស់ IFC ក្នុងការផ្តល់អំណាចដល់រចនាសម្ព័ន្ធដោះស្រាយពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជា IFC កំពុងចូលរួមយ៉ាងសកម្មនៅក្នុងក្រុមការងារស្តីពី "យន្តការដោះស្រាយបណ្តឹងសាទុក្ខ ការផ្តល់ប្រឹក្សាអំពីបំណុល និងការសម្រុះសម្រួល"។ ក្រុមការងារនេះមានគោលបំណងគាំទ្រដល់ការបង្កើតនូវយន្តការដោះស្រាយពាក្យបណ្តឹងរបស់អ្នកប្រើប្រាស់ទូទាំងវិស័យឯករាជ្យមួយ រួមជាមួយនឹងយន្តការផ្សេងៗទៀត ដើម្បីសម្របសម្រួលទំនុកចិត្តលើប្រព័ន្ធហិរញ្ញវត្ថុ និងទទួលបាននូវលទ្ធផលកាន់តែប្រសើរសម្រាប់អ្នកខ្ចីប្រាក់នៅកម្ពុជា។[40] លើសពីនេះ IFC បានរួមចំណែកផ្តល់នូវជំនាញរបស់ខ្លួននៅក្នុងក្រុមការងារ "ទិន្នន័យ" ដែលមានភារកិច្ចសិក្សាអំពីប្រព័ន្ធរាយការណ៍ឥណទាន ដែលអាចរួមបញ្ចូលទិន្នន័យពីសេវាធនាគារ និងសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឧ. ដូចជាអ្នកផ្តល់កម្ចីក្រៅប្រព័ន្ធជាដើម។

93. ជាសង្ខេប ការងាររបស់ IFC នៅកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចាប់ផ្តើម និងជំរុញវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងការពង្រឹងកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅក្នុងវិស័យនេះ។ តាមរយៈការវិនិយោគដោយផ្តោតលើគោលដៅ សេវាប្រឹក្សាយោបល់ និងការសហការជាមួយភាគីពាក់ព័ន្ធទាំងក្នុង និងក្រៅប្រទេស ព្រមទាំងការជំរុញឱ្យមានកំណែទម្រង់ ការកសាងសមត្ថភាព និងការគាំទ្រដល់ការកែលម្អជាប្រព័ន្ធ IFC មិនត្រឹមតែបានពង្រឹងការប្រតិបត្តិទីផ្សារ និងការត្រួតពិនិត្យបទប្បញ្ញត្តិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលើកកម្ពស់ប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុដែលមានសុវត្ថិភាព និងបរិយាបន្នជាងមុនសម្រាប់អ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជាផងដែរ។ យ៉ាងណាក៏ដោយ កិច្ចការងារនៅមានចំណុចដែលត្រូវបន្តដោះស្រាយលើបញ្ហាប្រឈ

38 តំណាងអង្គការ CSO គឺអង្គការ LICADHO និងអង្គការ EC ត្រូវបានអញ្ជើញឱ្យចូលរួមពិគ្រោះយោបល់ ប៉ុន្តែពួកគេបានបដិសេធមិនចូលរួមក្នុងគំនិតផ្តួចផ្តើមនេះទេ។

39 UN, 2024, បញ្ជីសកម្មភាពអាទិភាពដែលបានណែនាំ និងអនុម័ត, https://cambodia.un.org/sites/default/files/2024-07/Recommended%20Priority%20Actions_Adopted_12Jul2024.pdf

40 ក្រុមការងារនេះក៏មានការចូលរួមពី CSOs ផងដែរ។ តំណាងអង្គការ CSO នៃករណី CAO បានបដិសេធមិនចូលរួម។

មសំខាន់ៗនៃវិស័យនេះ ដូចជាបញ្ហាបំណុលលើសលប់ តម្លាភាពក្នុងការផ្តល់កម្ចី CCMs និងភាពងាយរងគ្រោះរបស់សហគមន៍ជនជាតិដើមភាគតិច។ នៅកម្រិតស្ថាប័ន IFC បានទទួលស្គាល់ថា ទោះបីជាមានក្របខ័ណ្ឌការពារអ្នកប្រើប្រាស់ដែលមានលក្ខណៈរឹងមាំបំផុតក៏ដោយ  ក៏មិនអាចលុបបំបាត់ទាំងស្រុងនូវហានិភ័យនៃភាពមិនប្រក្រតីដែលកើតឡើងក្នុងករណីបុគ្គលនីមួយៗបានដែរ។ ហេតុដូច្នេះហើយ IFC នឹងនៅតែផ្តោតការយកចិត្តទុកដាក់លើការធ្វើការងារជាមួយគ្រឹះស្ថាននានា ដែលមានប្រព័ន្ធ ការលើកទឹកចិត្ត និងការរៀបចំអភិបាលកិច្ចដែលត្រឹមត្រូវ។ IFC ប្តេជ្ញាចិត្តក្នុងការបន្តការចូលរួមរបស់ខ្លួននៅក្នុងផ្នែកទាំងនេះ ដើម្បីបង្កើនផលប៉ះពាល់ជាប្រព័ន្ធឱ្យបានជាអតិបរមា និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលមិនបានគ្រោងទុកឱ្យនៅកម្រិតទាបបំផុត។

## IX. ការឆ្លើយតបរបស់ IFC ចំពោះលទ្ធផលរកឃើញ និងអនុសាសន៍របស់ស្ថាប័ន CAO

94. ដូចដែលបានរៀបរាប់ខាងលើ IFC ទទួលស្គាល់ថា ផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម-សេដ្ឋកិច្ច និងបញ្ហាប្រឈមក្នុងវិស័យដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍ស៊ើបអង្កេតរបស់ CAO គឺជារឿងធ្ងន់ធ្ងរ និងតម្រូវឱ្យមានការវិភាគ និងចំណាត់ការបន្ថែមទៀតពីសំណាក់ IFC និងភាគីពាក់ព័ន្ធផ្សេងទៀតនៅច្រើនកម្រិត។ ចំណាត់ការទាំងនោះរួមមាន៖ (i) ការជួយសម្របសម្រួលដោះស្រាយករណីចំនួន 18 ករណី (ii) ការគាំទ្រដល់អតិថិជនរបស់ IFC ដើម្បីបន្តពង្រឹងគោលនយោបាយ និងនីតិវិធីផ្ទៃក្នុង (iii) ការធ្វើការងារនៅកម្រិតវិស័យ និងកម្រិតនិយតកម្ម ដើម្បីដោះស្រាយបញ្ហាប្រឈមជាប្រព័ន្ធ និង (iv) ការចូលរួមចំណែកក្នុងគំនិតផ្តួចផ្តើមពហុភាគីពាក់ព័ន្ធរបស់អង្គការ UN និងដៃគូអភិវឌ្ឍន៍ដទៃទៀត។

95. ទោះជាយ៉ាងណាក៏ដោយ IFC មិនយល់ស្របនឹងលទ្ធផលរកឃើញរបស់ CAO ដែលថាខ្លួនបានអនុវត្តមិនស្របតាមគោលនយោបាយចីរភាពឆ្នាំ 2012 នោះទេ។ គោលនយោបាយចីរភាពរបស់ IFC រួមជាមួយស្តង់ដាប្រតិបត្តិគឺមានបំណងដើម្បីដោះស្រាយហានិភ័យ និងផលប៉ះពាល់ផ្នែក E&S ដែលទាក់ទងនឹងការប្រើប្រាស់ចុងក្រោយនៃចំណូលនៃហិរញ្ញប្បទានរបស់ IFC ។ ការងារផ្នែកបរិយាបន្នហិរញ្ញវត្ថុ និងវិធីសាស្ត្រឆ្ពោះទៅរកមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវរបស់ IFC ដែលផ្អែកលើការអនុវត្តឧស្សាហកម្មល្អគឺគ្រប់គ្រងហានិភ័យសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជាបញ្ហាបំណុលលើសលប់ជាដើម ដែលហានិភ័យទាំងនេះក៏មានទិដ្ឋភាពសង្គម-សេដ្ឋកិច្ចដ៏សំខាន់ផងដែរ។ ស្រដៀងគ្នានេះដែរ គោលនយោបាយ និងក្របខ័ណ្ឌរបស់ក្រុម WBG ស្តីពីអំពើពុករលួយ សុចរិតភាព ការលាងលុយកខ្វក់ និងលទ្ធកម្មជាដើម ក៏គ្រប់គ្រងលើបញ្ហាប្រឈម និងផលប៉ះពាល់ផ្នែកសង្គម-សេដ្ឋកិច្ចនៃគំនិតផ្តួចផ្តើមអភិវឌ្ឍន៍នានាផងដែរ ប៉ុន្តែបញ្ហាទាំងនេះមិនមែនជាផ្នែកនៃគោលនយោបាយចីរភាពនោះទេ។

96. ការបកស្រាយរបស់ CAO ដែលថាកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ គួរតែត្រូវបានចាត់ទុកថាជាផ្នែកមួយដែលរួមបញ្ចូលនៅក្នុងក្របខ័ណ្ឌចីរភាព ដោយសារតែវាមិនត្រូវបានបញ្ជាក់ថាមិនរាប់បញ្ចូលនោះ នឹងធ្វើឱ្យវិសាលភាពនៃក្របខ័ណ្ឌចីរភាពរបស់ IFC កាន់តែទូលំទូលាយជាងមុនយ៉ាងខ្លាំង។ យោងតាមគោលនយោបាយរបស់ CAO មុខងារអនុលោមភាពរបស់ CAO វាយតម្លៃលើការមិនមានអនុលោមភាពតាមគោលនយោបាយ E&S បច្ចុប្បន្នរបស់ IFC[41] ក្រោមគោលបំណងដែលបានកំណត់របស់ខ្លួន។[42] មុខងារអនុលោមភាពរបស់ CAO មិនវាយតម្លៃលើភាពគ្រប់គ្រាន់ ឬភាពសមស្របនៃគោលនយោបាយទាំងនោះឡើយ។[43] ម្យ៉ាងវិញទៀត ការស៊ើបអង្កេតលើអនុលោមភាពរបស់ CAO មិនអាចពង្រីកវិសាលភាពនៃក្របខ័ណ្ឌចីរភាពរបស់ IFC ហើយសន្និដ្ឋានអំពីភាពមិនអនុលោមតាមរបស់ IFC ដោយមានអានុភាពប្រតិសកម្មបានទេ។

---

[41] នៅក្នុងគោលនយោបាយរបស់ CAO "គោលនយោបាយ E&S" ត្រូវបានឲ្យនិយមន័យថាជា៖ (i) គោលនយោបាយស្តីពីនិរន្តរភាពបរិស្ថាន និងសង្គមរបស់ IFC ឬ MIGA តាមដែលអាចអនុវត្តបាន (ii) បទប្បញ្ញត្តិជាក់លាក់តាមគម្រោងនៃគោលនយោបាយស្តីពីការចូលប្រើប្រាស់ព័ត៌មានរបស់ IFC ឬ MIGA តាមដែលអាចអនុវត្តបាន និង (iii) រាល់ការប្តេជ្ញាចិត្តផ្សេងទៀតផ្នែកបរិស្ថាន និងសង្គមសម្រាប់គម្រោងដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

[42] គោលនយោបាយរបស់ CAO (កថាខណ្ឌទី 76) ចែងថា៖ “[គោលបំណងនៃមុខងារអនុលោមភាពរបស់ CAO គឺដើម្បីធ្វើការពិនិត្យឡើងវិញនូវអនុលោមភាពរបស់ IFC/MIGA ជាមួយនឹងគោលនយោបាយ E&S វាយតម្លៃលើការផលប៉ះពាល់អវិជ្ជមានដែលពាក់ព័ន្ធ និងផ្តល់អនុសាសន៍លើសកម្មភាពសម្រុះសម្រួល តាមការសមគួរ”។

[43] គោលនយោបាយរបស់ CAO (កថាខណ្ឌទី 77) ចែងថា៖ “មុខងារអនុលោមភាពរបស់ CAO មិនវាយតម្លៃលើភាពគ្រប់គ្រាន់ ឬភាពសមស្របនៃគោលនយោបាយ E&S ទេ ហើយមិនធ្វើការសន្និដ្ឋានទាក់ទងនឹងអនុលោមភាពនៃគម្រោង គម្រោងរង អតិថិជន ឬអតិថិជនរងជាមួយនឹងស្តង់ដាប្រតិបត្តិឡើយ។ យ៉ាងណាក៏ដោយ នៅក្នុងការធ្វើការសន្និដ្ឋានទាក់ទងនឹងផលប៉ះពាល់អវិជ្ជមាន និងថាតើផលប៉ះពាល់អវិជ្ជមានណាមួយមានពាក់ព័ន្ធនឹងការមិនមានអនុលោមភាពតាមរបស់ IFC/MIGA ជាមួយនឹងគោលនយោបាយ E&S របស់ពួកគេដែរឬទេនោះ CAO នឹងវាយតម្លៃ តាមភាពពាក់ព័ន្ធ នូវការត្រួតពិនិត្យ និងការត្រួតត្រារបស់ IFC/MIGA លើលក្ខខណ្ឌតម្រូវផ្នែក E&S របស់ខ្លួននៅកម្រិតគម្រោង ឬគម្រោងរង និងពិចារណាលើការអនុវត្ត E&S នៅកម្រិតគម្រោង ឬគម្រោងរងផងដែរ។”

97. អំណះអំណាងមួយចំនួនដែលត្រូវបានលើកឡើងនៅក្នុងការស៊ើបអង្កេតលើអនុលោមភាពគឺទាមទារឱ្យមានការបំភ្លឺបន្ថែម ហើយនឹងត្រូវលើកយកមកដោះស្រាយនៅក្នុងកថាខណ្ឌខាងក្រោម។

## វិសាលភាពនៃក្របខ័ណ្ឌចីរភាពរបស់ IFC

98. នៅក្នុងខែវិច្ឆិកា ឆ្នាំ 2022 ស្ថាប័ន IFC បានបញ្ជាក់នូវជំហររបស់ខ្លួនថា ហានិភ័យ និងផលប៉ះពាល់ដែលទាក់ទងនឹងការផ្តល់ប្រាក់កម្ចី និងការអនុវត្តការទារបំណុល ហើយជាលទ្ធផល កិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុមិនស្ថិតនៅក្នុងវិសាលភាពនៃក្របខ័ណ្ឌចីរភាពរបស់ IFC នោះទេ។

99. គោលបំណង និងវិសាលភាពនៃគោលនយោបាយចីរភាពឆ្នាំ 2012 គឺដើម្បីគ្រប់គ្រងហានិភ័យ E&S និងផលប៉ះពាល់ដែលអាចកើតមានលើសហគមន៍ជុំវិញ កម្មករនិយោជិត និងបរិស្ថាន ដែលបណ្តាលមកពីសកម្មភាពអាជីវកម្មដែលទទួលបានការគាំទ្រពី IFC។[44] ទាក់ទងនឹងអន្តរការីហិរញ្ញវត្ថុ សកម្មភាពអាជីវកម្មដែល IFC គាំទ្រតាមរយៈអតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ខ្លួន គឺសកម្មភាពអាជីវកម្មដែលកើតចេញពីការប្រើប្រាស់ចុងក្រោយនៃចំណូលប្រាក់កម្ចីដោយអ្នកខ្ចីបន្ត ឧ. អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាដើម។ ជាឧទាហរណ៍ ប្រសិនបើអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រើប្រាស់កម្ចីពីអតិថិជនអន្តរការីហិរញ្ញវត្ថុ ដើម្បីធ្វើចម្ការដំឡូងមី ការធ្វើចម្ការដំឡូងមីនេះគឺជា "សកម្មភាពអាជីវកម្ម" ដែលទទួលបានការគាំទ្រ—មិនមែនជាទំនាក់ទំនងកិច្ចសន្យាផ្តល់ប្រាក់កម្ចីរវាងអតិថិជនរបស់ IFC និងអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះទេ។

100. ស្តង់ដាប្រតិបត្តិទី 1 អនុញ្ញាតឱ្យមានការពិចារណាកាន់តែទូលំទូលាយទៅលើភាគីពាក់ព័ន្ធ ដែលអាចរងផលប៉ះពាល់ដោយគម្រោងរបស់ IFC,[45] ដូចជាអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន គម្រោងជិតខាង និង/ឬអង្គការមិនមែនរដ្ឋាភិបាល។[46] អតិថិជន ឬអ្នកប្រើប្រាស់ផលិតផល ឬសេវាកម្មរបស់អតិថិជន ក្នុងករណីនេះគឺអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនត្រូវបានចាត់ទុកជាប្រភេទនៃភាគីពាក់ព័ន្ធ ដែលវិធានការកាត់បន្ថយហានិភ័យផ្នែក E&S ត្រូវអនុវត្តតាមនោះទេ នៅក្នុងគោលនយោបាយចីរភាព ឬស្តង់ដាប្រតិបត្តិ។

101. រូបទី 2 ផ្តល់នូវរូបភាពនៃរបៀបគ្រប់គ្រងលើកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ និងហានិភ័យផ្នែក E&S នៅក្នុងប្រតិបត្តិការរបស់ IFC។ គោលការណ៍ការពារអតិថិជនគ្រប់គ្រងលើហានិភ័យរបស់អ្នកប្រើប្រាស់ និងអនុវត្តចំពោះការទទួលប្រាក់កម្ចី និងការសងប្រាក់កម្ចីវិញ។ ក្របខ័ណ្ឌចីរភាពរបស់ IFC អនុវត្តចំពោះការប្រើប្រាស់ចំណូល។ គោលការណ៍ការពារអតិថិជនសម្រាប់កិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ និងលក្ខខណ្ឌតម្រូវនៃក្របខ័ណ្ឌចីរភាពរបស់ IFC គឺជាឧទាហរណ៍សម្រាប់បង្ហាញជូនប៉ុណ្ណោះ ហើយមិនមែនជាបញ្ជីរាយនាមពេញលេញនោះទេ។

---

[44] គោលនយោបាយចីរភាពឆ្នាំ 2012 (កថាខណ្ឌទី 3, ជើងទំព័រលេខ 2) ចែងថា៖ "[ផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម សំដៅលើការផ្លាស់ប្តូរណាមួយ ទាំងសក្តានុពល ឬជាក់ស្តែង ចំពោះ (i) បរិស្ថានរូបវន្ត ធម្មជាតិ ឬវប្បធម៌ និង (ii) ផលប៉ះពាល់លើសហគមន៍ជុំវិញ និងនិយោជិតកម្មករ ដែលបណ្តាលមកពីសកម្មភាពអាជីវកម្មដែលនឹងត្រូវទទួលបានការគាំទ្រដោយ IFC។" "សហគមន៍ជុំវិញ និងនិយោជិតកម្មករ" គឺជាភាគីពាក់ព័ន្ធដែលត្រូវបានពិចារណានៅពេលវាយតម្លៃលើហានិភ័យផ្នែក E&S ជាសក្តានុពល និងផលប៉ះពាល់ដែលអាចកើតមាន។

[45] សម្រាប់គោលបំណងនៃស្តង់ដាប្រតិបត្តិទី 1 ពាក្យថា "គម្រោង" សំដៅលើ"សំណុំនៃសកម្មភាពអាជីវកម្មដែលបានកំណត់ រួមទាំងសកម្មភាពដែលជាតុធ្យូររូបវន្តជាក់លាក់ ទិដ្ឋភាព និងសម្ភារៈនានាទំនងជាបង្កើតឱ្យមានហានិភ័យ និងផលប៉ះពាល់ ដែលមិនទាន់ត្រូវបានកំណត់អត្តសញ្ញាណនៅឡើយ (ឧទាហរណ៍ សាជីវកម្មដែលមានផលប័ត្រនៃទ្រព្យសកម្មរូបវន្តដែលមានស្រាប់ និង/ឬមានបំណងអភិវឌ្ឍ ឬទិញយកសម្ភារៈថ្មីៗ និងមូលនិធិវិនិយោគ ឬអន្តរការីហិរញ្ញវត្ថុដែលមានផលប័ត្រនៃទ្រព្យសកម្មដែលមានស្រាប់ និង/ឬដែលមានបំណងវិនិយោគលើសម្ភារៈថ្មីៗ)។"

[46] ស្តង់ដាប្រតិបត្តិទី 1 ក៏បានបញ្ជាក់ផងដែរអំពី "ភាគីពាក់ព័ន្ធដទៃទៀត" (ក្រៅពីសហគមន៍ជុំវិញ និងនិយោជិតកម្មករ) ថាជាអាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន គម្រោងជិតខាង និង/ឬអង្គការមិនមែនរដ្ឋាភិបាល (កថាខណ្ឌទី 1 ជើងទំព័រលេខ 1)។

**រូបទី 2៖ ការគ្រប់គ្រងហានិភ័យនៅក្នុងការវិនិយោគរបស់ IFC លើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**




102. ដោយសារតែគោលនយោបាយចីរភាពរបស់ IFC មិនមានបំណងអនុវត្តចំពោះអ្នកប្រើប្រាស់ ប៉ុន្តែមានបំណងអនុវត្តចំពោះហានិភ័យផ្នែក E&S និងផលប៉ះពាល់ដែលអាចកើតឡើងលើសហគមន៍ជុំវិញ និងនិយោជិតកម្មករ ដែលបណ្តាលមកពីសកម្មភាពអាជីវកម្មដែលទទួលបានការគាំទ្រពីចំណូលរបស់ IFC នោះ ការវាយតម្លៃលើភាពងាយរងគ្រោះរបស់អ្នកខ្ចីប្រាក់ម្នាក់ៗ និងសមត្ថភាពរបស់ពួកគេក្នុងការសងប្រាក់កម្ចីវិញ មិនដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃការវាយតម្លៃហានិភ័យផ្នែក E&S របស់ IFC ឡើយ។

103. នេះមិនមែនជាការខ្វះចន្លោះនោះទេ ប៉ុន្តែគឺជាការសម្រេចចិត្តប្រកបដោយការពិចារណា ដើម្បីដោះស្រាយបញ្ហាសំខាន់ៗទាំងនេះតាមរយៈវិធីសាស្រ្តដាច់ដោយឡែកមួយ ដែលស្របតាមការអនុវត្តល្អជាអន្តរជាតិ។ ដូចករណីសម្រាប់ស្ថាប័ន DFIs ធំៗទាំងអស់ រួមទាំងធនាគារពិភពលោកផងដែរ IFC វាយតម្លៃ គ្រប់គ្រង និងកាត់បន្ថយហានិភ័យសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តាមរយៈការងារផ្នែកបរិយាបន្នហិរញ្ញវត្ថុ និងគោលការណ៍ការពារអតិថិជនរបស់ខ្លួន។ នៅក្នុងបច្ចុប្បន្នភាពថ្មីៗនៃគោលនយោបាយ E&S ទាំងធនាគារអឺរ៉ុបសម្រាប់ការកសាងឡើងវិញ និងការអភិវឌ្ឍ និងធនាគារ ADB បានបញ្ជាក់យ៉ាងច្បាស់ថា ការពិចារណាណាមួយអំពីកិច្ចការពារអ្នកប្រើប្រាស់ក្រោមការគ្រប់គ្រងហានិភ័យផ្នែក E&S គឺមានកម្រិតត្រឹមតែសុវត្ថិភាពផលិតផលប៉ុណ្ណោះ។ IFC ដឹងថា យុត្តាធិការមួយចំនួនផ្តល់អនុសាសន៍ឱ្យគ្រឹះស្ថានហិរញ្ញវត្ថុធ្វើសមាហរណកម្មការគ្រប់គ្រងហានិភ័យផ្នែក E&S និងកិច្ចការពារអ្នកប្រើប្រាស់ ហើយថាគោលនយោបាយ E&S ឆ្នាំ 2022 របស់ធនាគារវិនិយោគអឺរ៉ុបក៏បានដើរតាមវិធីសាស្រ្តបែបនេះផងដែរ។ យ៉ាងណាក៏ដោយ ការអនុវត្តនេះមិនផ្លាស់ប្តូរវិសាលភាពនៃក្របខ័ណ្ឌចីរភាពឆ្នាំ 2012 របស់ IFC ឡើយ។

**ការអនុវត្តឧស្សាហកម្មល្អជាអន្តរជាតិក្នុងកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ**

104. នៅក្នុងការស៊ើបអង្កេតរបស់ខ្លួន CAO បញ្ជាក់ថា IFC បានកំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យផ្នែក E&S ទៅលើសហគមន៍ជុំវិញ និងនិយោជិតកម្មករនៅក្នុងការវិនិយោគរបស់ IFC បានគ្រប់គ្រាន់។ ស្រដៀងគ្នានេះដែរ CAO ទទួលស្គាល់ថា ហានិភ័យផ្នែកហិរញ្ញវត្ថុនៅទូទាំងវិស័យ ដូចជាបញ្ហាបំណុលជាដើមក៏ត្រូវបានកំណត់ឃើញ និងដោះស្រាយនៅក្នុងកិច្ចសន្ទនាផ្លូវច្បាប់ស្តីពីការផ្តល់កម្ចីប្រកបដោយការទទួលខុសត្រូវផងដែរ។

ទោះជាយ៉ាងណាក៏ដោយ CAO បានផ្តល់អនុសាសន៍ថា បន្ថែមពីលើនេះ IFC គួរតែពង្រីកវិសាលភាពនៃលក្ខខណ្ឌតម្រូវផ្នែក E&S របស់ខ្លួន ដើម្បីរួមបញ្ចូលទាំងគោលការណ៍ការពារអតិថិជនផងដែរ។ ដើម្បីបង្កើតអំណះអំណាងនេះ CAO ណែនាំថា គោលការណ៍ការពារអតិថិជន Cerise+SPTF រួមជាមួយនឹងការអនុវត្តល្អរបស់ធនាគារពិភពលោកសម្រាប់កិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុគួរតែត្រូវបានពិចារណាថាជាការអនុវត្តល្អក្នុងឧស្សាហកម្មអន្តរជាតិ (GIIP) នៅក្នុងការគ្រប់គ្រងហានិភ័យផ្នែក E&S។

105. ក្រោមគោលនយោបាយចីរភាពរបស់ IFC, IFC អនុវត្ត GIIP នៅពេលវាយតម្លៃហានិភ័យផ្នែក E&S នៃសកម្មភាពអាជីវកម្មដែលខ្លួននឹងផ្តល់ការគាំទ្រ។ គោលការណ៍ណែនាំស្តីពីបរិស្ថាន សុខភាព និងសុវត្ថិភាពរបស់ក្រុមធនាគារពិភពលោកបម្រើជាឯកសារយោងបច្ចេកទេសចម្បងសម្រាប់ GIIP។

106. IFC បញ្ជាក់ថាគោលការណ៍ការពារអតិថិជន គឺជាស្តង់ដាដែលត្រូវបានទទួលស្គាល់ជាសកលនៃ GIIP នៅក្នុងវិស័យការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ—មិនមែននៅក្នុងការគ្រប់គ្រងហានិភ័យផ្នែក E&S នោះទេ។ WBG បានបង្កើត និង/ឬអនុវត្ត GIIP នៅក្នុងវិស័យជាច្រើន។ គោលនយោបាយ និងក្របខ័ណ្ឌស្តីពីលទ្ធកម្ម ការប្រឆាំងការលាងលុយកខ្វក់ សុចរិតភាព និងកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ WBG បានកំណត់ស្តង់ដាសកលនៅក្នុងហិរញ្ញវត្ថុអភិវឌ្ឍន៍ និងវិស័យហិរញ្ញវត្ថុ។ GIIP ដែលអនុវត្តចំពោះបញ្ហានៅក្រៅវិសាលភាពនៃក្របខ័ណ្ឌចីរភាពរបស់ IFC (ដូចជាចំណុចដែល CAO បានលើកឡើងនៅក្នុងការស៊ើបអង្កេតលើអនុលោមភាពរបស់ខ្លួន) មិនមែនជា GIIP ផ្នែក E&S នោះទេ។

**មីក្រូហិរញ្ញវត្ថុសម្រាប់ជនជាតិដើមភាគតិច**

107. ការស៊ើបអង្កេតរបស់ CAO ទទួលស្គាល់ថា អតិថិជន និងអតិថិជនរងបានបង្កើតនីតិវិធីដើម្បីបដិសេធទុកជាមុន នូវសកម្មភាពអាជីវកម្មដែលអាចបង្កផលប៉ះពាល់អវិជ្ជមាន ដូចដែលបានកំណត់នៅក្នុងបញ្ជីរាយសកម្មភាពហាមឃាត់របស់ IFC។ CAO បានគូសបញ្ជាក់ថា បញ្ជីរាយសកម្មភាពហាមឃាត់របស់ IFC បានចែងថាកម្មវិធីមីក្រូហិរញ្ញវត្ថុមិនត្រូវផ្តល់ហិរញ្ញប្បទានដល់ "ផលិតកម្ម ឬសកម្មភាពទាំងឡាយណាដែលរំលោភលើដីធ្លីដែលជាកម្មសិទ្ធិ ឬត្រូវបានទាមទារដោយមានការកាត់ក្តី ដោយជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពេញលេញពីជនជាតិដើមភាគតិចទាំងនោះឡើយ។"

108. CAO ផ្តល់អនុសាសន៍ថា អ្នកខ្ចីប្រាក់ដែលជាជនជាតិដើមភាគតិច ដែលបានលក់ដីធ្លីរបស់ខ្លួនដើម្បីសងបំណុលដល់អតិថិជន MFI ផ្ទាល់ ឬប្រយោលរបស់ IFC ឬម្ចាស់បំណុលដទៃទៀត គឺជាការបង្កផលប៉ះពាល់អវិជ្ជមានដល់សហគមន៍ជនជាតិដើមភាគតិច និងដីធ្លីរបស់ពួកគេ ហើយ IFC គួរតែតម្រូវឱ្យអតិថិជន និងអតិថិជនរងរបស់ខ្លួនអនុវត្តតាមបញ្ជីរាយសកម្មភាពហាមឃាត់ ដើម្បីទប់ស្កាត់ការអនុវត្តបែបនេះ។ បញ្ជីរាយសកម្មភាពហាមឃាត់របស់ IFC មានបំណងអនុវត្តនៅក្នុងបរិបទនៃការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសខ្នាតមីក្រូ ដែលសកម្មភាពអាជីវកម្មរបស់សហគ្រាសនោះអាចប៉ះពាល់ដល់ដីធ្លីរបស់ជនជាតិដើមភាគតិច។ បញ្ជីនេះមិនមានបំណងសម្រាប់អនុវត្តចំពោះអ្នកខ្ចីប្រាក់ដែលជាជនជាតិដើមភាគតិចជាលក្ខណៈបុគ្គលនោះទេ។

109. ស្ថានភាពនៅប្រទេសកម្ពុជាមានភាពស្មុគស្មាញ។ កម្ពុជាទទួលស្គាល់ជនជាតិដើមភាគតិចចំនួន 24 ក្រុម ដែលមានចំនួនប្រជាជនប្រហែល 400,000 នាក់ ឬស្មើនឹង 1.4 ភាគរយនៃចំនួនប្រជាជនសរុបរបស់ប្រទេស។ ច្បាប់ភូមិបាលឆ្នាំ 2001 របស់កម្ពុជា អនុញ្ញាតឱ្យជនជាតិដើមភាគតិចទទួលបានបណ្ណកម្មសិទ្ធិដីសហគមន៍។ ដំណើរការនៃការចុះបញ្ជីកម្មសិទ្ធិដីធ្លីសហគមន៍នៅកម្ពុជា បានទទួលជោគជ័យក្នុងការថែរក្សាទំនៀមទម្លាប់ប្រពៃណី ការពារសន្តិសុខដីធ្លី និងការលើកកម្ពស់ជីវភាពរស់នៅរបស់ជនជាតិដើមភាគតិច ប៉ុន្តែវាកំពុងជួបប្រទះបញ្ហាប្រឈម និងការពន្យារពេលផ្សេងៗ។ ការទាមទារដីធ្លីត្រួតគ្នាលើដីសហគមន៍ ដីសាធារណៈ និងដីឯកជន គឺជាបញ្ហាដែលតែងតែជួបប្រទះជាញឹកញាប់។ សហគមន៍ជនជាតិដើមភាគតិចមួយចំនួនកំពុងដាកចេញពីការចុះបញ្ជីដីធ្លីសហគមន៍ ដោយសារតែការដាក់ពាក្យស្នើសុំបណ្ណកម្មសិទ្ធិដីធ្លីសហគមន៍របស់ពួកគេចំណាយពេលយូរពេក ហើយដីដែលស្ថិតនៅក្រោមបណ្ណកម្មសិទ្ធិសហគមន៍មិនអាចដាក់បញ្ចាំ ឬលក់ទៅឱ្យអ្នកក្រៅសហគមន៍បាន។[47]

[47] Heinrick Boell Stiftung, 2022, ការចុះបញ្ជីដីធ្លីសហគមន៍របស់ជនជាតិដើមភាគតិចនៅកម្ពុជា, https://kh.boell.org/en/2022/08/10/indigenous-communal-land-titling-still-hundred-years-go

110. ច្បាប់កម្ពុជាអនុញ្ញាតឱ្យប្រើប្រាស់ "ប័ណ្ណកម្មសិទ្ធិដីធ្លីប្លង់ទន់" ជាទ្រព្យបញ្ចាំបាន។ ចំណុចនេះបាននាំឱ្យមានស្ថានភាពដែលអ្នកខ្ចីប្រាក់ជាជនជាតិដើមភាគតិច បានទទួលប្លង់ទន់ជាលក្ខណៈបុគ្គលនៃដីរបស់ពួកគេ ហើយយកវាទៅដាក់ជាទ្រព្យបញ្ចាំដើម្បីទទួលបានប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ពួកគេជារឿយៗធ្វើបែបនេះដោយមានការដឹងឮពីសហគមន៍ជនជាតិដើមភាគតិចរៀងៗខ្លួន និងធ្វើឡើងនៅលើដីដែលកំពុងស្ថិតក្នុងបណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ដែលមានស្រាប់ ឬក្នុងអំឡុងពេលដែលបណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ទាំងនោះកំពុងស្ថិតក្នុងដំណើរការរៀបចំ។ នៅក្នុងឆ្នាំ 2024, NBC បានពង្រឹងបទប្បញ្ញត្តិដែលមានស្រាប់ថា បណ្ណកម្មសិទ្ធិដីធ្លីសហគមន៍របស់ជនជាតិដើមភាគតិចមិនអាចប្រើប្រាស់ជាទ្រព្យបញ្ចាំសម្រាប់ប្រាក់កម្ចីបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ បញ្ជីសារពើភណ្ឌជាតិនៅខ្វះខាតព័ត៌មានអំពីដីសហគមន៍ ហើយមិនគ្របដណ្ដប់ទៅលើប្លង់ទន់នោះទេ។ ដូច្នេះហើយ វាជាការលំបាកសម្រាប់គ្រឹះស្ថានផ្តល់កម្ចីមីក្រូហិរញ្ញវត្ថុក្នុងការត្រួតពិនិត្យថាតើប្លង់ទន់ជាលក្ខណៈបុគ្គលដែលយកមកដាក់ជាទ្រព្យបញ្ចាំនោះជាន់គ្នាជាមួយបណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ឬយ៉ាងណា។

111. ម្ចាស់បណ្ដឹងចំនួនប្រាំពីរនាក់ ក្នុងចំណោម 18 នាក់ គឺជាជនជាតិដើមភាគតិច។ ពួកគេបានប្រើប្រាស់ប្លង់ទន់ជាលក្ខណៈបុគ្គល ដើម្បីដាក់ជាទ្រព្យបញ្ចាំសម្រាប់ខ្ចីប្រាក់ ដោយមានខ្លះទទួលបានការដឹងឮពីអាជ្ញាធរជនជាតិដើមភាគតិចមូលដ្ឋានផងដែរ។ ម្ចាស់បណ្ដឹងទាំងនេះបានរាយការណ៍ដោយខ្លួនឯងទៅកាន់ CAO និង IFC ថា ប្លង់ទន់របស់ពួកគេមានការជាន់គ្នាជាមួយបណ្ណកម្មសិទ្ធិដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៃសហគមន៍របស់ពួកគេ។ អតិថិជន និងអតិថិជនរងរបស់ IFC បានទទួលយកប្លង់ទន់ជាលក្ខណៈបុគ្គលទាំងនេះ ដោយមិនអាចផ្ទៀងផ្ទាត់បានថា តើដីទាំងនោះស្ថិតក្រោមការទាមទារដីធ្លីផ្សេងទៀតដែរឬទេ។ ពួកគេមិនបានទទួលយកទ្រព្យបញ្ចាំលើបណ្ណកម្មសិទ្ធិដីសហគមន៍ជនជាតិដើមភាគតិចដោយផ្ទាល់នោះទេ ហើយក៏មិនបានអនុវត្តការរឹបអូសទ្រព្យបញ្ចាំណាមួយពីម្ចាស់បណ្ដឹងទាំងប្រាំពីរនាក់នេះដែរ។

112. ម្ចាស់បណ្ដឹងទាំងប្រាំពីរនាក់នេះបានរាយការណ៍ថា ពួកគេបានលក់ដីដើម្បីសងបំណុលរបស់ពួកគេ។ ក្នុងចំណោមម្ចាស់បណ្ដឹងទាំងប្រាំពីរនាក់នេះ មានប្រាំនាក់បានលក់ដីទៅឱ្យបុគ្គលនៅក្នុងសហគមន៍ជនជាតិដើមភាគតិចដូចគ្នា ដូច្នេះមិនមានផលប៉ះពាល់អវិជ្ជមានណាមួយទៅលើដីជនជាតិដើមភាគតិច ឬសហគមន៍ជនជាតិដើមភាគតិចនោះទេ។ មានតែអ្នកខ្ចីប្រាក់ជាជនជាតិដើមភាគតិចពីរនាក់ប៉ុណ្ណោះ ដែលបានលក់ដីទៅឱ្យបុគ្គលក្រៅសហគមន៍ជនជាតិដើមភាគតិច ដែលបាននាំឱ្យមានជម្លោះជាមួយអាជ្ញាធរជនជាតិដើមភាគតិចរបស់ពួកគេ ហើយជម្លោះទាំងនោះត្រូវបានដោះស្រាយរួចរាល់ហើយ។ ចំណុចសំខាន់គឺថា មិនមានពាក្យបណ្ដឹងណាមួយពីសំណាក់សហគមន៍ជនជាតិដើមភាគតិចផ្ទាល់ ដែលចោទប្រកាន់ពីការបង្កផលប៉ះពាល់អវិជ្ជមានដល់ដីធ្លី ឬអត្តសញ្ញាណរបស់ពួកគេ ដោយសារសកម្មភាពរបស់អ្នកខ្ចីប្រាក់ជាជនជាតិដើមភាគតិច ឬអតិថិជន និងអតិថិជនរងរបស់ IFC នោះទេ។

113. IFC មិនយល់ស្របនឹងការលើកឡើងរបស់ CAO ដែលថា បញ្ជីរាយសកម្មភាពហាមឃាត់របស់ IFC គួរតែត្រូវបានបកស្រាយថាជាការហាមឃាត់ការប្រើប្រាស់ដីធ្លីជាទ្រព្យបញ្ចាំ ឬហាមឃាត់សិទ្ធិក្នុងការលក់ដីដោយជនជាតិដើមភាគតិចនោះទេ។ ការបកស្រាយបែបនេះអាចនាំឱ្យមានការអនុវត្តបែបរើសអើងប្រឆាំងនឹងជនជាតិដើមភាគតិច។ ក្រោមការបកស្រាយរបស់ CAO, MFIs ក៏អាចនឹងមានការស្ទាក់ស្ទើរក្នុងការផ្តល់ប្រាក់កម្ចីដល់អ្នកខ្ចីជាជនជាតិដើមភាគតិច ឬនៅក្នុងតំបន់ជនជាតិដើមភាគតិច ដែលនឹងធ្វើឱ្យមានការកម្រិតលទ្ធភាពទទួលបានហិរញ្ញប្បទាន និងបន្តរុញច្រានក្រុមអ្នកងាយរងគ្រោះឱ្យនៅដាច់ដោយឡែកពីសង្គម។

## យន្តការដោះស្រាយបណ្ដឹងអ្នកប្រើប្រាស់

114. ការស៊ើបអង្កេតរបស់ CAO បញ្ចូលយន្តការដោះស្រាយបណ្ដឹងសាទុក្ខរបស់ភាគីពាក់ព័ន្ធ (GRMs) និងយន្តការដោះស្រាយបណ្ដឹងអ្នកប្រើប្រាស់ (CCMs) ចូលគ្នា។ យន្តការទាំងពីរនេះត្រូវបានតម្រូវឱ្យមានទាំងក្រោមច្បាប់ជាតិ និងដោយ IFC។ GRMs ត្រូវបានតម្រូវដោយក្របខ័ណ្ឌចីរភាពរបស់ IFC ហើយអនុវត្តចំពោះនិយោជិតកម្មករដែលបម្រើការក្នុងគម្រោង និងសហគមន៍ដែលរងផលប៉ះពាល់ដោយសកម្មភាពអាជីវកម្មនៃគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ IFC។ CCMs ត្រូវបានតម្រូវជាផ្នែកមួយនៃវិធីសាស្ត្ររបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ (ស្របតាមការអនុវត្តឧស្សាហកម្មល្អ) ហើយត្រូវបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ IFC។ អតិថិជនវិស័យមីក្រូហិរញ្ញវត្ថុត្រូវបានតម្រូវឱ្យមានយន្តការទាន់ពេលវេលា និងយន្តការឆ្លើយតបសម្រាប់ពាក្យបណ្ដឹង និងការដោះស្រាយបញ្ហាសម្រាប់អ្នកខ្ចីប្រាក់ ដែលមានបំណងចង់ចូលរួមជាមួយបុគ្គលដទៃទៀតក្រៅពីមន្ត្រីឥណទានរបស់ពួកគេ និង/ឬប្រធានរបស់មន្ត្រីរូបនោះ។

115. នៅក្នុងលទ្ធផលរកឃើញរបស់ខ្លួន CAO បានលើកឡើងថា GRMs ដែលត្រូវបានបង្កើតឡើងនៅក្នុងការវិនិយោគរបស់ IFC សម្រាប់សហគមន៍ដែលរងផលប៉ះពាល់ ក៏គួរតែទទួលបានពាក្យបណ្ដឹងអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុផងដែរ។ ទោះបីជាគ្រឹះស្ថានហិរញ្ញវត្ថុខ្នាតតូចជាងនេះអាចដំណើរការយន្តការទាំងពីរនេះរួមគ្នា ដោយសារការខ្វះខាតធនធានក៏ដោយ ក៏ CCMs ត្រូវបានរៀបចំឡើង និងត្រួតពិនិត្យដោយផ្អែកលើគោលការណ៍ការពារអ

តិថិជនដែរ។ ការខ្វះការយល់ដឹង ឬការមិនយល់ច្បាស់អំពី CCMs ដោយអ្នកខ្ចីប្រាក់ពីអតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ IFC មិនអាចចាត់ទុកថាជាការមិនមានអនុលោមភាពក្រោមក្របខ័ណ្ឌចិរភាពនោះទេ។

## សកម្មភាពរបស់ IFC ដែលឆ្លើយតបទៅនឹងអនុសាសន៍របស់ CAO

116. IFC ប្តេជ្ញាចិត្តយ៉ាងពេញលេញក្នុងការពង្រឹងវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបន្តដោះស្រាយបញ្ហាប្រឈមនានាដែលបានលើកឡើងនៅក្នុងការស៊ើបអង្កេតរបស់ CAO។ ថ្នាក់គ្រប់គ្រងក៏ប្តេជ្ញាយ៉ាងពេញលេញផងដែរក្នុងការគាំទ្រដល់ដំណោះស្រាយករណីរបស់ម្ចាស់បណ្តឹងទាំង 18 នាក់ តាមរយៈយន្តការដោះស្រាយបណ្តឹងរបស់អ្នកប្រើប្រាស់ដែលមានស្រាប់នៅតាមមូលដ្ឋាន។

117. គោលនយោបាយរបស់ CAO ចែងថា ក្នុងករណីដែល CAO រកឃើញការមិនមានអនុលោមភាព និងផលប៉ះពាល់អវិជ្ជមានដែលពាក់ព័ន្ធ CAO នឹងផ្តល់អនុសាសន៍ឱ្យ IFC ពិចារណានៅពេលបង្កើត MAP។ នៅក្នុងរបាយការណ៍ស៊ើបអង្កេតរបស់ខ្លួន CAO បានផ្តល់អនុសាសន៍ចំនួនប្រាំពីរ រួមទាំងសម្រាប់ឱ្យ IFC អនុវត្តសកម្មភាពសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា ជាមួយអតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ខ្លួន ក្នុងកម្រិតវិស័យ និងជាមួយដៃគូអភិវឌ្ឍន៍។ IFC កោតសរសើរចំពោះអនុសាសន៍ទាំងនេះ ដោយសារវាឆ្លុះបញ្ចាំងពីតួនាទីរបស់ IFC ក្នុងការពង្រឹងកិច្ចការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែផលប៉ះពាល់អវិជ្ជមានដែលបានបង្ហាញនៅក្នុងរបាយការណ៍ស៊ើបអង្កេតរបស់ CAO មិនពាក់ព័ន្ធនឹងការមិនមានអនុលោមភាពតាមគោលនយោបាយចិរភាពរបស់ IFC នោះទេ ដូច្នេះ IFC មិនដាក់បង្ហាញនូវ MAP ឡើយ។

118. ផ្នែកខាងក្រោមនេះពន្យល់ពីរបៀបដែលសកម្មភាពកន្លងមក បច្ចុប្បន្ន និងអនាគតឆ្លើយតបទៅនឹងអនុសាសន៍កម្រិតគម្រោងរបស់ CAO។ ដើម្បីជួយសម្រួលដល់ការយល់ដឹង IFC បានសង្ខេបអនុសាសន៍របស់ CAO តាមប្រធានបទ និងបានចាត់ក្រុមសកម្មភាពតាមផ្នែកប្រធានបទដូចដែលបានលើកឡើងនៅក្នុងអនុសាសន៍របស់ CAO យោងតាមតារាងខាងក្រោម។

**សេចក្តីសង្ខេបនៃអនុសាសន៍របស់ CAO ជាក់លាក់តាមគម្រោង**

| **អនុសាសន៍របស់ CAO ជាក់លាក់តាមគម្រោង** |
| --- |
| ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ស៊ើបអង្កេតអនុលោមភាពរបស់ CAO ខែតុលា ឆ្នាំ 2025 |
| **អនុសាសន៍ទី 1** ដោះស្រាយដំណោះស្រាយបណ្តឹងរបស់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា រួមទាំងម្ចាស់បណ្តឹងទាំង 18 នាក់ |
| **អនុសាសន៍ទី 2** ផ្តោតលើការអភិវឌ្ឍផ្នែកបទប្បញ្ញត្តិ និងកម្រិតវិស័យ |
| **អនុសាសន៍ទី 3 និងទី 4** ដោះស្រាយគោលនយោបាយ និងនីតិវិធីរបស់អតិថិជន ក៏ដូចជាការបណ្តុះបណ្តាល និងការកសាងសមត្ថភាព |
| **អនុសាសន៍ទី 5** កំណត់គោលដៅលើការពង្រឹងសមត្ថភាពហិរញ្ញវត្ថុ និងអក្ខរកម្មហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |

119. ទាក់ទងនឹងអនុសាសន៍ទី 1 របស់ CAO នោះ IFC នឹងជួយសម្របសម្រួលដល់ការត្រួតពិនិត្យ និងដំណោះស្រាយករណីទាំង 18 ករណី ដូចដែលបានពិពណ៌នានៅក្នុងផ្នែក V ខាងលើ។ អ្នកប្រឹក្សាយោបល់ឯករាជ្យមួយរូបនឹងជួយគាំទ្រដល់ដំណើរការនេះ តាមរយៈ CCMs រៀងៗខ្លួនរបស់អតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ IFC។

120. IFC កោតសរសើរចំពោះអនុសាសន៍ទី 2 របស់ CAO ក្នុងការបន្តពង្រឹងយន្តការដោះស្រាយបណ្តឹងកម្រិតវិស័យ។ តំណាងអង្គការ CSO បានបញ្ជាក់ថា យន្តការដោះស្រាយបណ្តឹងកម្រិតវិស័យដោយឯករាជ្យ គឺជាអាទិភាពរបស់ពួកគេ។ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ IFC បានគាំទ្រដល់ការបង្កើតរចនាសម្ព័ន្ធដោះស្រាយបណ្តឹងអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅកម្ពុជា។ ដោយក្រឡេកមើលទៅថ្ងៃអនាគត ការផ្តោតរបស់ IFC នឹងផ្លាស់ប្តូរទៅរកFCC ដែលទើបនឹងបង្កើតថ្មី។ អាណត្តិរបស់ FCC គឺទទួល និងដោះស្រាយពាក្យបណ្តឹងអ្នកប្រើប្រាស់ ផ្តល់កម្មវិធីអក្ខរកម្មហិរញ្ញវត្ថុ និងដើរតួជាលេខាធិការដ្ឋាននៃស្ថាប័នមន្ត្រីស៊ើបអង្កេតបណ្តឹងហិរញ្ញវត្ថុ នាពេលអនាគតនៅក្នុងប្រទេសកម្ពុជា។ ជាផ្នែកមួយនៃការងារផ្តល់ប្រឹក្សាយោបល់ដែលកំពុងបន្តរបស់ខ្លួន IFC នឹងបន្តលើកកម្ពស់ការអភិវឌ្ឍក្របខ័ណ្ឌការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុដ៏រឹងមាំនៅក្នុងប្រទេសកម្ពុជា ដោះស្រាយចន្លោះប្រហោងនៃបទប្បញ្ញត្តិ និងលើកកម្ពស់វិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។

121. នៅក្នុងអនុសាសន៍ទី 3 និងទី 4, CAO ផ្តល់អនុសាសន៍ឱ្យពង្រីកលក្ខខណ្ឌតម្រូវផ្នែក E&S ដែលមានចែងនៅក្នុងស្តង់ដាប្រតិបត្តិការរបស់ IFC ទៅដល់អតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ខ្លួន។ ទោះបីជា IFC មិនយល់ស្របនឹងវិធីសាស្ត្រនេះក៏ដោយ ក៏ IFC បានចាត់វិធានការជាច្រើនដើម្បីត្រួតពិនិត្យ និងពង្រឹងសមត្ថភាពរបស់អតិថិជនផ្ទាល់ និងអតិថិជនប្រយោលរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ដែលទាក់ទងនឹង CCMs ការចូលរួមរបស់ភាគីពាក់ព័ន្ធ ការគំរាមកំហែង និងការសង្កត់សឹក ក៏ដូចជាការផ្តល់ប្រាក់កម្ចីប្រកបដោយក្រមសីលធម៌ ស្របតាមវិធីសាស្ត្ររបស់ខ្លួនក្នុងការការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ។

122. គំនិតផ្តួចផ្តើមទាំងនេះត្រូវបានពង្រីកលើសពីអតិថិជនរបស់ IFC ហើយកំពុងត្រូវបានផ្តល់ជូនដល់ MFIs ដទៃទៀត និងភាគីពាក់ព័ន្ធក្នុងវិស័យនេះ។ កាលពីពេលថ្មីៗនេះ IFC បានគាំទ្រដល់ IBF ក្នុងការដាក់ឱ្យដំណើរការនូវកម្មវិធីផ្តល់វិញ្ញាបនបត្រដែលបានធ្វើបច្ចុប្បន្នភាពរបស់ខ្លួនសម្រាប់មន្ត្រីឥណទានទាំង 65,000 នាក់នៅក្នុងប្រទេសកម្ពុជា។

123. IFC នឹងបន្តគាំទ្រ និងលើកកម្ពស់ CCMs របស់អតិថិជនខ្លួន រួមជាមួយនឹងបណ្តាញដោះស្រាយបណ្តឹងសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅទូទាំងវិស័យទាំងមូល។ ដោយសហការជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ IFC នឹងរៀបចំកម្មវិធីបណ្តុះបណ្តាលសមត្ថភាពសម្រាប់វិស័យហិរញ្ញវត្ថុស្តីពីការចុះបញ្ជីកម្មសិទ្ធិដីធ្លី និងការប្រើប្រាស់ប្រព័ន្ធដែលមានដើម្បីផ្ទៀងផ្ទាត់ទ្រព្យបញ្ចាំជាដីធ្លី។

124. អនុសាសន៍ទី 5 របស់ CAO ផ្តោតលើការផ្តល់សិទ្ធិអំណាច និងអក្ខរកម្មហិរញ្ញវត្ថុ។ NBC និង FCC គឺជាដៃគូដ៏សំខាន់ក្នុងកិច្ចការនេះ។ IFC នឹងបន្តគាំទ្រស្ថាប័នទាំងនេះក្នុងការអនុវត្តអាណត្តិរបស់ពួកគេ ដើម្បីពង្រឹងអក្ខរកម្មហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា រួមទាំងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនការយល់ដឹងរបស់អ្នកខ្ចីប្រាក់អំពីយន្តការដោះស្រាយបណ្តឹងដែលមានស្រាប់ ដែលនេះគឺជាបញ្ហាប្រឈមជាក់លាក់សម្រាប់ម្ចាស់បណ្តឹងទាំង 18 នាក់នោះ។

125. ជាចុងក្រោយ IFC នឹងបន្តរួមចំណែកក្នុងការចូលរួមរបស់ភាគីពាក់ព័ន្ធ ដូចជាផែនការសកម្មភាព 22 ចំណុចរបស់ NBC-UN ដើម្បីសហការ និងរួមចំណែកដល់គំនិតផ្តួចផ្តើមនៅកម្រិតវិស័យ ក្នុងផ្នែកបទប្បញ្ញត្តិ ការផ្តល់ប្រឹក្សា និងសម្រុះសម្រួលបំណុល អក្ខរកម្មហិរញ្ញវត្ថុ ការសម្របសម្រួលរវាងវិស័យផ្តល់ប្រាក់កម្ចីផ្លូវការ និងក្រៅផ្លូវការ ក៏ដូចជាការធ្វើឱ្យកាន់តែច្បាស់លាស់នូវតួនាទីរបស់អាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ការប្រើប្រាស់ប័ណ្ណកម្មសិទ្ធិដីធ្លីជាន់គ្នាដោយខុសគោលដៅ។

126. រូបទី 3 បង្ហាញពីពេលវេលាកំណត់ដែលបង្ហាញពីសមិទ្ធផលនានាក្នុងវិស័យការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានការគាំទ្រពី IFC។ ម្ចាស់បណ្តឹងបានទទួលកម្ចីតាំងពីឆ្នាំ 2007 មកម្ល៉េះ ដូច្នេះពេលវេលានេះគូសបញ្ជាក់ពីសកម្មភាពពាក់ព័ន្ធដែលចាប់ផ្តើមពីឆ្នាំ 2012 នៅពេលដែល CBC ត្រូវបានបង្កើតឡើង។ សកម្មភាពជាច្រើនឆ្លើយតបទៅនឹងអនុសាសន៍របស់ CAO ច្រើនជាងមួយចំណុច ដូចដែលបានបង្ហាញដោយស្លាកសញ្ញាពណ៌។

**រូបទី 3៖ ពេលវេលាកំណត់នៃសកម្មភាពរបស់ IFC ដែលឆ្លើយតបទៅនឹងអនុសាសន៍របស់ CAO**




**សម្គាល់**

- **អនុសាសន៍ទី 1៖** ការដោះស្រាយបណ្តឹង
- **អនុសាសន៍ទី 2៖** ការអភិវឌ្ឍផ្នែកនិយ័តកម្ម និងកម្រិតវិស័យ
- **អនុសាសន៍ទី 3 និងទី 4៖** ការកសាងសមត្ថភាពសម្រាប់អតិថិជនរបស់ IFC និងភាគីពាក់ព័ន្ធក្នុងវិស័យនេះ
- **អនុសាសន៍ទី 5៖** ការផ្តល់សិទ្ធិអំណាច និងអក្ខរកម្មហិរញ្ញវត្ថុ

**ការពង្រឹងការអនុវត្តជាសកល**

127. CAO ក៏ផ្តល់អនុសាសន៍កម្រិតប្រព័ន្ធចំនួនពីរ ដែល IFC បានពិចារណាផងដែរ។ នៅកម្រិតសកល IFC សហការជាមួយ DFIs ផ្សេងទៀតដែលអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវក្នុងប្រតិបត្តិការផ្តល់ប្រាក់កម្ចីរបស់ពួកគេ ហើយក៏ជាសមាជិក និងជាអ្នកផ្តល់ហិរញ្ញប្បទានដល់អង្គការ Cerise+SPTF ផងដែរ។[48] ចាប់តាំងពីឆ្នាំ 2011 មក IFC បានដាក់បញ្ចូលវិធីសាស្រ្តរបស់ខ្លួនស្តីពីមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវទៅក្នុងឯកសារគម្រោងនានា រួមទាំងការបង្ហាញហានិភ័យ ការវាយតម្លៃហានិភ័យឥណទាន ការពិនិត្យឯកសារកម្ចី និងបទប្បញ្ញត្តិផ្លូវច្បាប់ដែលស្របតាមគោលការណ៍ការពារអតិថិជននៃឧស្សាហកម្មមីក្រូហិរញ្ញវត្ថុ។

128. ដូចដែលបានរៀបរាប់ខាងលើ ក្នុងឆ្នាំ 2023 IEG របស់ WBG បានពិនិត្យ និងផ្តល់អនុសាសន៍ឱ្យពង្រឹងការងាររបស់ WBG លើបរិយាបន្នហិរញ្ញវត្ថុ។[49] ស្រដៀងគ្នានេះដែរ ការស៊ើបអង្កេតរបស់ CAO បានបញ្ជាក់ពីតម្រូវការក្នុងការពង្រឹងការត្រួតពិនិត្យនៅក្នុងវិធីសាស្រ្តរបស់ IFC ចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ។ ដូច្នេះ IFC កំពុងដាក់ឱ្យប្រើប្រាស់នូវនីតិវិធីផ្លូវការសម្រាប់ការត្រួតពិនិត្យ និងការមើលខុសត្រូវយ៉ាងហ្មត់ចត់លើគម្រោងនៃការវិនិយោគរបស់ IFC ដែលក្នុងនោះការប្រើប្រាស់ចំណូលរួមមានសហគ្រាសខ្នាតមីក្រូ ឬសហគ្រាសក្រៅផ្លូវការ ឬអ្នកប្រើប្រាស់ម្នាក់ៗ ក៏ដូចជាការដាក់ចេញនូវលក្ខខណ្ឌតម្រូវនៃកិច្ចសន្យាបន្ថែម ដើម្បីពង្រឹងការត្រួតពិនិត្យ និងគណនេយ្យភាព។

129. វិធីសាស្រ្តដែលបានធ្វើបច្ចុប្បន្នភាពនេះនឹងគិតទៅលើចំនួនដែលកំពុងកើនឡើង និងភាពចម្រុះនៃអ្នកផ្តល់សេវាហិរញ្ញវត្ថុដែលកំពុងបម្រើអ្នកខ្ចីប្រាក់ដែលមានចំណូលទាប និងចន្លោះប្រហោងក្នុងបទប្បញ្ញត្តិស្តីពីការការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ក៏ដូចជាហានិភ័យជិតកើតឡើងចំពោះអ្នកប្រើប្រាស់ដែលពាក់ព័ន្ធនឹងសេវាហិរញ្ញវត្ថុឌីជីថល។ ការអនុវត្តនីតិវិធីទាំងនេះ នៅពេលដែលបានបញ្ចប់ ក៏នឹងត្រូវដាក់បញ្ចូលជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនៃកិច្ចសន្យាផងដែរ រួមទាំងការព្រមព្រៀងផ្លូវការជាកាតព្វកិច្ច និងលក្ខខណ្ឌតម្រូវនៃការរាយការណ៍ ដើម្បីជួយធានាថាអ្នកទទួលផលគោលដៅរបស់ IFC ទទួលបានអត្ថប្រយោជន៍ពីសេវាហិរញ្ញវត្ថុ និងមានលទ្ធភាពទទួលបានយន្តការដោះស្រាយបណ្តឹងអ្នកប្រើប្រាស់នៅមូលដ្ឋាន។

130. ជាចុងក្រោយ វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា ការអនុវត្តសកម្មភាពនានាដែលមានចែងក្នុងរបាយការណ៍គ្រប់គ្រងនេះ ដែលផ្តល់ជូនតាមរយៈការងារប្រឹក្សាយោបល់របស់ IFC និងស្របតាមក្របខ័ណ្ឌភាពជាដៃគូប្រចាំប្រទេស របស់ WBG នៅកម្ពុជា ព្រមទាំងការអនុវត្តនីតិវិធីស្ថាប័ននៅកម្រិតសកល ត្រូវបានវាយតម្លៃ និងតាមដានដោយ IEG របស់ WBG ដែលត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាល។ តាមការស្នើសុំ IFC ក៏អាចរាយការណ៍ដោយផ្ទាល់ជូនក្រុមប្រឹក្សាភិបាលផងដែរ។

## X. សេចក្តីសន្និដ្ឋាន

131. របាយការណ៍គ្រប់គ្រងរបស់ IFC ទទួលស្គាល់ពីកង្វល់ធ្ងន់ធ្ងរដែលត្រូវបានលើកឡើងដោយការស៊ើបអង្កេតរបស់ CAO ទៅលើវិស័យមីក្រូហិរញ្ញវត្ថុរបស់កម្ពុជា រួមទាំងបញ្ហាបំណុលលើសលប់ ការផ្តល់កម្ចី និងការទារបំណុលទាំងសាហាវ។ ទោះបីជា IFC នៅតែរក្សាជំហរថាបញ្ហាទាំងនេះស្ថិតនៅក្រៅវិសាលភាពនៃក្របខ័ណ្ឌចីរភាពរបស់ខ្លួនក៏ដោយ ក៏ IFC ដោះស្រាយបញ្ហាទាំងនេះតាមរយៈវិធីសាស្រ្តដ៏រឹងមាំមួយចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ហើយចាត់វិធានការនៅកម្រិតជាច្រើន ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់ CAO។

132. ដូចដែលបានព្រមព្រៀងជាមួយម្ចាស់បណ្តឹងទាំង 18 នាក់ ក៏ដូចជាជាមួយអតិថិជន និងអតិថិជនរង IFC នឹងសម្របសម្រួលការពិនិត្យករណីទាំង 18 នេះ តាមរយៈយន្តការដោះស្រាយបណ្តឹងអ្នកប្រើប្រាស់ដែលមានស្រាប់របស់អតិថិជន IFC ដែលពាក់ព័ន្ធ។ ម្ចាស់បណ្តឹងក៏នឹងអាចទទួលបានសិទ្ធិចូលប្រើប្រាស់យន្តការដោះស្រាយបណ្តឹងអ្នកប្រើប្រាស់នៅកម្រិតវិស័យទាំងមូលផងដែរ ដូចជា FCC និង NAADR ដែលមិនទាន់មាននៅពេលដែលពួកគេដាក់ពាក្យបណ្តឹងរបស់ពួកគេទៅកាន់ CAO។

133. IFC នឹងបន្តធ្វើការជាមួយអតិថិជនរបស់ខ្លួន ដើម្បីពង្រឹងយន្តការដោះស្រាយបណ្តឹងអ្នកប្រើប្រាស់ និងធានាឱ្យមានការអនុវត្តស្របតាមក្របខ័ណ្ឌការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់ IFC។ IFC ក៏នឹងបន្តផ្តល់ការបណ្តុះបណ្តាលដល់អតិថិជន និងភាគីដទៃទៀតនៅក្នុងវិស័យនេះស្តីពីការផ្តល់ប្រាក់កម្ចី និងការទារបំណុលប្រក

[48] បញ្ជីរាយនាមហត្ថលេខីនៃសេចក្តីថ្លែងការណ៍រួមរបស់ស្ថាប័នផ្តល់សេវាហិរញ្ញវត្ថុដែលត្រូវចូលរួមក្នុងមាគ៌ាការពារអតិថិជនអាចចូលមើលបាននៅទីនេះ៖ https://cerise-sptf.org/sign-the-joint-statement/

[49] WBG IEG, 2023, បរិយាបន្នហិរញ្ញវត្ថុ, មេរៀនពីបទពិសោធរបស់ក្រុមធនាគារពិភពលោក, ឆ្នាំសារពើពន្ធ 2014-22, https://ieg.worldbankgroup.org/evaluations/financial-inclusion

បដោយការទទួលខុសត្រូវ ការដោះស្រាយបណ្តឹងអ្នកប្រើប្រាស់ និងការគ្រប់គ្រងហានិភ័យនៃការសងសឹកនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុផងដែរ។ IFC នឹងពង្រីកការផ្តល់ការបណ្តុះបណ្តាលទាំងនេះ ដើម្បីដោះស្រាយហានិភ័យដែលពាក់ព័ន្ធនឹងការរៀបចំឯកសារទ្រព្យបញ្ចាំជាឌីជីថលផងដែរ។ IFC ក៏នឹងបន្តគាំទ្រដល់ការផ្តល់វិញ្ញាបនបត្រដល់មន្ត្រីឥណទានទាំងអស់នៅក្នុងប្រទេសកម្ពុជាលើផ្នែកផ្តល់ប្រាក់កម្ចី និងការទារបំណុលប្រកបដោយការទទួលខុសត្រូវផងដែរ។

134. នៅកម្រិតវិស័យ IFC នឹងបន្តគាំទ្រដល់ NBC ក្នុងការពង្រឹងក្របខ័ណ្ឌបទប្បញ្ញត្តិហិរញ្ញវត្ថុ ជំរុញឱ្យមានការបង្កើតស្ថាប័នអ្នកស៊ើបអង្កេតបណ្តឹងហិរញ្ញវត្ថុ និងជួយពង្រឹងសមត្ថភាពរបស់ FCC ពាក់ព័ន្ធនឹងការដោះស្រាយបណ្តឹង ក៏ដូចជាការលើកកម្ពស់យន្តការដោះស្រាយបណ្តឹងអ្នកប្រើប្រាស់នៅកម្រិតវិស័យ និងអក្ខរកម្មហិរញ្ញវត្ថុផងដែរ។

135. នៅថ្ងៃខាងមុខ IFC មានគោលបំណងជំរុញវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ គាំទ្រកំណែទម្រង់បទប្បញ្ញត្តិ និងផ្តល់អាទិភាពដល់តម្រូវការរបស់អ្នកខ្ចីប្រាក់ដែលងាយរងគ្រោះ។ តាមរយៈការលើកកម្ពស់ការអនុវត្តល្អៗនៅទូទាំងវិស័យ និងការបន្តកិច្ចសហការជាមួយភាគីពាក់ព័ន្ធ IFC នឹងរួមចំណែកដល់ការបង្កើតប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុមួយដែលមានលក្ខណៈកាន់តែបរិយាបន្ន និងមានភាពធន់នៅក្នុងប្រទេសកម្ពុជា។

## ឧបសម្ព័ន្ធ A. ការចូលរួមរបស់ភាគីពាក់ព័ន្ធរបស់ IFC

នៅក្នុងការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងរបស់ខ្លួនកាលពីខែវិច្ឆិកា ឆ្នាំ 2022, IFC បានស្នើឱ្យមានការចូលរួមជាមួយម្ចាស់បណ្តឹង ព្រមទាំងពិនិត្យ និងដោះស្រាយករណីរបស់ពួកគេ។

ក្នុងខែវិច្ឆិកា ឆ្នាំ 2025, IFC បានជួបជាមួយម្ចាស់បណ្តឹងទាំង 18 នាក់ និងសមាជិកគ្រួសារមួយចំនួនរបស់ពួកគេ ដែលបានធ្វើដំណើរមកពីខេត្តផ្សេងៗគ្នាក្នុងប្រទេសកម្ពុជា ដើម្បីរៀបរាប់ពីបញ្ហារបស់ពួកគេ។ IFC ក៏បានជួបជាមួយអតិថិជន និងអតីតអតិថិជន និងអតិថិជនរងទាំងអស់ អាជ្ញាធរ និងស្ថាប័នជាតិ អង្គការ UN DFIs ដទៃទៀត និងដៃគូអភិវឌ្ឍន៍ ដើម្បីបង្ហាញពីលទ្ធផលនៃការស៊ើបអង្កេតរបស់ CAO និងពិភាក្សាអំពីអាទិភាពជាលទ្ធផលនៃសកម្មភាពរបស់ IFC ដែលបានកំណត់ទុកសម្រាប់ការពង្រឹងការអនុវត្ត និងហេដ្ឋារចនាសម្ព័ន្ធនៃការការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។ IFC បានកោះប្រជុំក្រុមការងារ UN-NBC ស្តីពីយន្តការដោះស្រាយបណ្តឹង ការប្រឹក្សាយោបល់អំពីបំណុល និងការសម្រុះសម្រួល ព្រមទាំងអតិថិជន និងអតិថិជនរងរបស់ IFC ដើម្បីវាយតម្លៃលើវឌ្ឍនភាពដែលសម្រេចបានក្នុងឆ្នាំ 2025 និងគំនិតផ្តួចផ្តើមដែលកំពុងបន្ត។

### ការចូលរួមជាមួយម្ចាស់បណ្តឹង

IFC កោតសរសើរចំពោះទំនុកចិត្ត និងភាពបើកចំហរបស់ម្ចាស់បណ្តឹងក្នុងការចែករំលែករឿងរ៉ាវរបស់ពួកគេ ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍នេះ។ IFC បានដឹងថា កង្វល់របស់ម្ចាស់បណ្តឹងអំពីការសងសឹកនៅដើមដំបូងនៃដំណើរការរបស់ CAO ភាគច្រើនទាក់ទងនឹងការអនុវត្តការទារបំណុលទាំងសាហាវរបស់មន្ត្រីឥណទាន។ ទោះជាយ៉ាងណាក៏ដោយ តំណាងអង្គការ CSO នៅតែមានការភ័យខ្លាចចំពោះការសងសឹក ពីព្រោះក្នុងនាមជាអង្គការមួយ ពួកគេបានសម្តែងការប្រឆាំង និងលើកឡើងពីកង្វល់ផ្សេងៗទៅកាន់ IFC និងអតិថិជនរបស់ខ្លួន។ តាមការយល់ដឹងរបស់ IFC ការចូលរួមជាមួយ IFC ដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេតលើអនុលោមភាពនេះ មិនបាននាំឱ្យមានករណីសងសឹកជាថ្មីឡើយ។ IFC យកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះរាល់ការចោទប្រកាន់ដែលមានភាពជឿជាក់អំពីការសងសឹក។[50]

ក្នុងខែវិច្ឆិកា ឆ្នាំ 2025, IFC បានចែករំលែកជាមួយភាគីពាក់ព័ន្ធអំពីរបៀបដែលខ្លួនមានបំណងឆ្លើយតបទៅនឹងអនុសាសន៍របស់ CAO។ តំណាងអង្គការ CSO បានស្វាគមន៍គំនិតផ្តួចផ្តើមរបស់ IFC ក្នុងការរក្សាទីប្រឹក្សាឯករាជ្យ ដើម្បីគាំទ្រដល់អតិថិជន និងអតិថិជនរងរបស់ IFC ក្នុងការដំណើរការបណ្តឹងទាំង 18 ករណីតាមរយៈ CCMs របស់ពួកគេ។ ទីប្រឹក្សានឹងជួយម្ចាស់បណ្តឹងក្នុងការបង្ហាញករណីរបស់ពួកគេទៅកាន់ CCMs ឬយន្តការកម្រិតវិស័យដែលមាននៅក្នុងប្រទេសកម្ពុជា តាមការពេញចិត្តរបស់ពួកគេ។ ពួកគេបានផ្តល់យោបល់លើលក្ខណៈសម្បត្តិដែលចង់បានរបស់ទីប្រឹក្សាបែបនេះ។ តំណាងទាំងនោះបានបញ្ជាក់ថា អាទិភាពរបស់ពួកគេគឺចង់ឱ្យប្រទេសកម្ពុជាមាន CCM ក្នុងកម្រិតវិស័យមួយដែលមានដំណើរការសម្រាប់អ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ ពួកគេក៏បានគូសបញ្ជាក់ផងដែរថា បំណងរបស់ពួកគេគឺចង់ឱ្យ CAO និងយន្តការទទួលខុសត្រូវរបស់ DFI ផ្សេងទៀតទទួលយកបណ្តឹងពីអ្នកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅលើពិភពលោក។

IFC បានជម្រាបជូនតំណាងអង្គការ CSO អំពីជំហររបស់ IFC លើការស៊ើបអង្កេតរបស់ CAO និងថា IFC ប្រហែលជាមិនដាក់ MAP ជូនក្រុមប្រឹក្សាភិបាលអនុម័តនោះទេ ប៉ុន្តែនឹងសម្របសម្រួលការពិនិត្យ និងដោះស្រាយករណីរបស់ម្ចាស់បណ្តឹងទាំង 18 នាក់ ជាផ្នែកមួយនៃការងាររបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។ ម្ចាស់បណ្តឹងបានផ្តល់មតិយោបល់ និងសំណូមពរជាលាយលក្ខណ៍អក្សរលើសកម្មភាពដែលបានស្នើឡើងរបស់ IFC ក្នុងខែធ្នូ ឆ្នាំ 2025។

### ជំហររបស់អតិថិជន

អតិថិជន និងអតិថិជនរងទាំងអស់បានបង្ហាញការប្តេជ្ញារបស់ពួកគេក្នុងការពិនិត្យមើលករណីរបស់ម្ចាស់បណ្តឹងទាំង 18 នាក់ រួមជាមួយនឹងពាក្យបណ្តឹងអ្នកប្រើប្រាស់ផ្សេងទៀតដែលពួកគេទទួលបាន។ ពួកគេបានស្វាគមន៍សំណើរបស់ IFC ក្នុងការជួលអ្នកប្រឹក្សាយោបល់មួយរូប ដើម្បីសម្របសម្រួលដល់ដំណើរការដោះស្រាយពាក្យបណ្តឹងទាំង 18 ករណី និងការគាំទ្ររបស់ IFC ក្នុងការពង្រឹង CCMs របស់ពួកគេ។

ជាចំណុចសំខាន់ ករណីចំនួនប្រាំបួនបន្ថែមទៀតរបស់ CAO ដែលស្ថិតក្នុងដំណើរការដោះស្រាយវិវាទក្រោមការដឹកនាំរបស់ CAO នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេឃើញថាជាការធ្វើឱ្យប៉ះពាល់ដល់ CCMs របស់ស្ថាប័ន និងយន្តការដោះស្រាយពាក្យបណ្តឹងអ្នកប្រើប្រាស់ទូទាំងវិស័យ។ អតិថិជន និងអតិថិជនរងរបស់ IFC កំពុងចូលរួមក្នុងពេលដំណាលគ្នា ទាំងនៅក្នុងការស៊ើបអង្កេតលើអនុលោមភាព និងដំណើរការដោះស្រាយវិវាទឯករាជ្យជាច្រើន ដែលធ្វើឱ្យមានការបង្វែរធនធានពីការជំរុញដំណោះស្រាយរួមគ្នា។

---

[50] IFC, 2018, សេចក្តីថ្លែងការណ៍អំពីជំហររបស់ IFC ស្តីពីការសងសឹកប្រឆាំងនឹងសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនៃគម្រោង, https://www.ifc.org/content/dam/ifc/doc/2023/201810-ifc-position-statement-on-reprisals-en.pdf

## ការចូលរួមជាមួយ CAO

មុនពេលដាក់ជូនរបាយការណ៍គ្រប់គ្រងនេះ IFC បានជម្រាបទៅ CAO ថា IFC នៅតែរក្សាជំហរកាលពីឆ្នាំ 2022 របស់ខ្លួនថា កិច្ចការពារអ្នកប្រើប្រាស់ហិរញ្ញវត្ថុ មិនស្ថិតនៅក្នុងវិសាលភាពនៃក្របខ័ណ្ឌចីរភាពរបស់ IFC ឡើយ ហើយថា IFC នឹងមិនបង្ហាញ MAP ជូនក្រុមប្រឹក្សាភិបាលអនុម័តនោះទេ។ IFC បានអញ្ជើញក្រុមដោះស្រាយវិវាទរបស់ CAO ឱ្យបន្តផ្តល់ការកសាងសមត្ថភាពលើការសម្រុះសម្រួលដល់ FCC ដោយឯករាជ្យពីដំណើរការនៃអនុលោមភាព។

# ឧបសម្ព័ន្ធ B. ការវិនិយោគរបស់ IFC ដែលស្ថិតក្រោមការស៊ើបអង្កេតរបស់ CAO

ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ 1990 មក IFC បានខិតខំប្រឹងប្រែងជំរុញវិស័យហិរញ្ញវត្ថុរបស់កម្ពុជា ដោយផ្តោតលើការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ការពង្រឹងភាពធន់របស់ស្ថាប័ន និងការគាំទ្រដល់កំណើនវិស័យឯកជនប្រកបដោយចីរភាព តាមរយៈការវិនិយោគផ្ទាល់ សេវាកម្មប្រឹក្សាយោបល់ និងការវិនិយោគដោយប្រយោល។ ឧបសម្ព័ន្ធនេះផ្តល់នូវទិដ្ឋភាពទូទៅនៃការវិនិយោគ និងភាពជាដៃគូរបស់ IFC ជាមួយ BFIs នៅកម្ពុជាចំនួនប្រាំមួយ ដែលជាកម្មវត្ថុនៃរបាយការណ៍ស៊ើបអង្កេតរបស់ CAO ហើយក៏បានរួមបញ្ចូលនូវព័ត៌មានលម្អិតអំពី CCMs ដូចដែលបានផ្តល់ជូនដោយអតិថិជន និងអតិថិជនរងរបស់ IFC ផងដែរ។

## I. ធនាគារអេស៊ីលីដា ភីអិលស៊ី

IFC បានរក្សាភាពជាដៃគូដ៏យូរអង្វែងជាមួយធនាគារអេស៊ីលីដា ដោយបានគាំទ្រការវិវត្តរបស់ធនាគារនេះពីអង្គការក្រៅរដ្ឋាភិបាលទៅជាធនាគារពាណិជ្ជឈានមុខគេមួយ។ គិតត្រឹមខែធ្នូ ឆ្នាំ 2025, IFC មានការវិនិយោគសកម្មចំនួនពីរគម្រោង៖ (i) គម្រោងលេខ 42480 (ប្រាក់កម្ចីបន្ទាប់បន្សំ)៖ ត្រូវបានរៀបចំឡើងជាដើមទុនថ្នាក់ទី 2 គម្រោងនេះគឺជាការកៀងគរទុនបែបនេះជាលើកដំបូងរបស់ IFC នៅក្នុងប្រទេសកម្ពុជា ដែលជួយធ្វើពិពិធកម្មរចនាសម្ព័ន្ធដើមទុនរបស់អេស៊ីលីដា ពង្រឹងភាពគ្រប់គ្រាន់នៃដើមទុន និងគាំទ្រដល់យុទ្ធសាស្ត្រឌីជីថលូបនីយកម្មរបស់ធនាគារ នឹង (ii) គម្រោងលេខ 44882 (ប្រាក់កម្ចីជាន់ខ្ពស់)៖ បានជួយឱ្យអេស៊ីលីដាពង្រីកសេវាកម្មហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs) ជាពិសេសសហគ្រាសដែលដឹកនាំដោយស្ត្រី និងសហគ្រាសក្នុងវិស័យកសិកម្ម ដែលជួយសម្រួលដល់ការងើបឡើងវិញពីជំងឺរាតត្បាត COVID-19។

កិច្ចព្រមព្រៀងផ្លូវច្បាប់របស់ IFC ជាមួយអេស៊ីលីដា ធានាថាចំណូលត្រូវបានកំណត់គោលដៅដាច់ដោយឡែក ដើម្បីគាំទ្រដល់កំណើន SME និងទប់ស្កាត់បុនហិរញ្ញប្បទានលើបំណុលដែលមានស្រាប់ លើកលែងតែសម្រាប់ការទិញយកទ្រព្យសកម្មដើមទុនថ្មី។ លើសពីនេះ IFC បានវិនិយោគទឹកប្រាក់ចំនួន $15 លានដុល្លារអាមេរិកនៅក្នុងក្រុមហ៊ុន North Haven Thai (គម្រោងលេខ 38609) ដែលបានទិញភាគហ៊ុនចំនួន 3.5 ភាគរយនៅក្នុងធនាគារអេស៊ីលីដា កាលពីខែមេសា ឆ្នាំ 2022។

ធនាគារអេស៊ីលីដាបានបង្ហាញភាពជាអ្នកដឹកនាំក្នុងការការពារអតិថិជន ដោយទទួលបានកម្រិតមាសក្នុងការបញ្ជាក់ពីការការពារអតិថិជនប្លុក (Client Protection Certification Plus) ពីស្ថាប័ន MicroFinanza Rating Srl ( MFR) ក្នុងខែតុលា ឆ្នាំ 2025 ដែលជាស្តង់ដាខ្ពស់បំផុតសម្រាប់ការគ្រប់គ្រងការអនុវត្តផ្នែក E&S។ ធនាគារអេស៊ីលីដាបានបង្កើត CCM ដោយផ្តល់ជូននូវបណ្តាញជាច្រើនសម្រាប់អតិថិជនក្នុងការដាក់ពាក្យបណ្តឹង និងធានាបាននូវការដោះស្រាយទាន់ពេលវេលាតាមរយៈប្រព័ន្ធគ្រប់គ្រង CCM របស់ខ្លួន។ ធនាគារបានរាយការណ៍ថា របាយការណ៍ស្តីពីការដោះស្រាយពាក្យបណ្តឹងត្រូវបានដាក់ជូនជាទៀងទាត់ទៅកាន់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងស្ថាប័ននិយ័តករ ហើយរាល់ពាក្យបណ្តឹងចាប់ពីឆ្នាំ 2022 ដល់ឆ្នាំ 2025 ត្រូវបានដោះស្រាយទាន់ពេលវេលា ដោយមិនមានបញ្ហាណាមួយនៅសេសសល់នោះទេ។ ធនាគារអេស៊ីលីដាក៏ផ្តល់ការបណ្តុះបណ្តាលស្តីពីការផ្តល់ប្រាក់កម្ចីដោយការទទួលខុសត្រូវ និងកិច្ចការពារអតិថិជនដល់មន្ត្រីឥណទានរបស់ខ្លួនផងដែរ ដែលពង្រឹងការប្តេជ្ញាចិត្តចំពោះការអនុវត្តតាមក្រមសីលធម៌ និងការពេញចិត្តរបស់អតិថិជន។

## II. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត

IFC បានក្លាយជាម្ចាស់ភាគហ៊ុននៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតចាប់តាំងពីឆ្នាំ 2014 មក ដោយមានភាគហ៊ុនដំបូងចំនួន 19.99 ភាគរយ។ IFC បានផ្តល់ប្រាក់កម្ចីវិលជុំជាន់ខ្ពស់ក្នុងអំឡុងវិបត្តិជំងឺ COVID-19 ដើម្បីគាំទ្រដល់ MSMEs។ គិតត្រឹមខែកញ្ញា ឆ្នាំ 2025 មានតែគម្រោងភាគហ៊ុន (លេខ 34748) ប៉ុណ្ណោះដែលនៅតែសកម្ម ដោយ IFC កាន់កាប់ភាគហ៊ុនចំនួន 9.99 ភាគរយ។ ការផ្លាស់ប្តូរថ្មីៗរួមមាន ការលក់ភាគហ៊ុនភាគច្រើនរបស់ក្រុមហ៊ុន Advans Group ទៅឱ្យធនាគារ Bank SinoPac នៅខែមករា ឆ្នាំ 2025 ដែលក្នុងនោះ IFC នៅតែរក្សាភាគហ៊ុនចំនួន 10 ភាគរយយ៉ាងហោចណាស់ពីរឆ្នាំបន្ទាប់ពីការទិញយក ដើម្បីធានាបាននូវនិរន្តរភាព និងរក្សាឱ្យបាននូវស្តង់ដាបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។

អម្រឹតបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះការការពារអតិថិជន ដោយទទួលបានវិញ្ញាបនបត្រស្តីពីគោលការណ៍ការពារអតិថិជនកម្រិតមាស (Gold-level Client Protection Principles Certification) ពីស្ថាប័នវាយតម្លៃ MFR Global ក្នុងខែឧសភា ឆ្នាំ 2025 ដែលមានសុពលភាពរយៈពេលបីឆ្នាំ។ វិធីសាស្ត្ររបស់អម្រឹត រួមមានការបណ្តុះបណ្តាលបុគ្គលិកជាបន្តបន្ទាប់—ទាំងតាមរយៈការរៀនតាមប្រព័ន្ធអេឡិចត្រូនិក និងកម្មវិធីផ្ទាល់យ៉ាងស៊ីជម្រៅ—ដោយធានាថា មន្ត្រីឥណទានទាំងអស់មានចំណេះដឹងច្បាស់លាស់អំពីការផ្តល់ប្រាក់កម្ចីដោយការទទួលខុសត្រូវ និងស្តង់ដាការពារអតិថិជន។ អតិថិជនអាចដាក់ពាក្យបណ្តឹងតាមរយៈបណ្តាញជាច្រើនដូចជា៖ គេហទំព័រ ការអញ្ជើញទៅកាន់សាខាផ្ទាល់ ខ្សែទូរសព្ទទាន់ហេតុការណ៍ ទំព័រ Facebook ឬអ៊ីមែល។ ពាក្យបណ្តឹងត្រូវបានផ្តល់អាទិភាពទៅតាមកម្រិតបន្ទាន់ និងប្រភេទនៃបញ្ហា ដោយបញ្ហាដែលមានអាទិភាពខ្ពស់ត្រូវដោះស្រាយក្នុងរយៈពេលពីរថ្ងៃធ្វើការ ហើយពាក្យបណ្តឹងទាំងអស់ត្រូវបញ្ចប់ការដោះស្រាយក្នុងរយៈពេល 30 ថ្ងៃ។ អម្រឹតតាមដានពាក្យបណ្តឹងតាមកម្រិតអាទិភាព និងប្រភេទនៃបញ្ហា ដែលក្នុងមួយឆ្នាំៗមានពាក្យបណ្តឹងរាប់ពាន់ត្រូវបានដោះស្រាយ ហើយក្រុមហ៊ុនបានរាយការណ៍ថា មានអនុលោមភាពតាមក្រមសីលធម៌របស់ខ្លួនបាន 100 ភាគរយ។

## III. HTB (ធនាគារហត្ថាភីអិលស៊ី)

ធនាគារហត្ថា ដែលពីមុនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករលីមីតធីត បានផ្លាស់ប្តូរពី MFI ទៅជាធនាគារពាណិជ្ជ ដោយមានការគាំទ្រពី IFC។ គិតត្រឹមចុងឆ្នាំ 2025 ការវិនិយោគរបស់ IFC នៅក្នុងធនាគារ HTB គឺតាមរយៈប្រាក់កម្ចីបន្ទាប់បន្សំ ដែលត្រូវបានផ្តល់ជូនក្រោមគម្រោងលេខ 44742 ដែលជាដើមទុនថ្នាក់ទី 2 ដែលផ្តល់ហិរញ្ញប្បទានដល់ MSME និងអ្នកខ្ចីប្រាក់ជាសហគ្រាស MSME ដែលដឹកនាំដោយស្ត្រី ព្រមទាំងជួយធ្វើពិពិធកម្មរចនាសម្ព័ន្ធដើមទុន និងបង្កើនស្ថិរភាពហិរញ្ញវត្ថុរបស់ធនាគារ HTB ទៀតផង។ កិច្ចសហប្រតិបត្តិការពីមុនរបស់ IFC ជាមួយធនាគារ HTB រួមមានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ HTB សម្រាប់ដំណើរការផ្លាស់ប្តូររបស់ធនាគារ ការធ្វើគោលដៅប្រៀបធៀបផ្នែកហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងគំនិតផ្តួចផ្តើមលើផ្នែកហិរញ្ញវត្ថុយេនឌ័រ។

គ្រប់ខ័ណ្ឌដោះស្រាយពាក្យបណ្តឹងរបស់អតិថិជនរបស់ធនាគារ HTB បានកំណត់គោលនយោបាយ និងនីតិវិធីច្បាស់លាស់សម្រាប់ដោះស្រាយបញ្ហាប្រកបដោយយុត្តិធម៌ ភ្លាមៗ និងតម្លាភាព។ អតិថិជនអាចដាក់ពាក្យបណ្តឹងតាមរយៈបណ្តាញជាច្រើនរួមមាន មជ្ឈមណ្ឌលហៅទូរសព្ទ សាខា គេហទំព័រ អ៊ីមែល បណ្តាញសង្គម បុគ្គលិក ប្រអប់សំណូមពរ និងស្ថាប័ននិយ័តករដូចជា NBC, ABC និង CMA។ អាទិភាពត្រូវបានផ្តល់ជូនករណីដែលពាក់ព័ន្ធនឹងការខាតបង់ហិរញ្ញវត្ថុ ឬក្តីកង្វល់ជាប្រព័ន្ធ ដោយពាក្យបណ្តឹងផ្ទាល់មាត់ត្រូវដោះស្រាយក្នុងរយៈពេលពីរថ្ងៃធ្វើការ និងពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 30 ថ្ងៃ។ រាល់ពាក្យបណ្តឹងទាំងអស់តម្រូវឱ្យមានការទទួលស្គាល់ ការស៊ើបអង្កេត ការកត់ត្រាឯកសារឱ្យបានត្រឹមត្រូវ និងការបញ្ជូនបន្តទៅថ្នាក់លើតាមតម្រូវការ។ កំណត់ត្រាត្រូវបានរក្សាទុកយ៉ាងហោចណាស់បីឆ្នាំ ដោយមានការរាយការណ៍ជាទៀងទាត់ និងការបិទសំណុំរឿងជាប្រព័ន្ធ។ ធនាគារ HTB បានជួលក្រុមហ៊ុន Microfinanza ដែលជាក្រុមហ៊ុនប្រឹក្សាយោបល់ជំនាញខាងហិរញ្ញវត្ថុបរិយាប័ន្ន និងការអភិវឌ្ឍប្រកបដោយចីរភាព ឲ្យវាយតម្លៃលើអនុលោមភាពរបស់ខ្លួនតាមគោលការណ៍ការពារអតិថិជន និងក្រមសីលធម៌របស់ BFI។ របាយការណ៍ចុងក្រោយរបស់ក្រុមហ៊ុន Microfinanza ត្រូវបានរំពឹងថានឹងចេញផ្សាយនៅខែកុម្ភៈ ឆ្នាំ 2026។

### ការវិនិយោគដោយប្រយោលរបស់ IFC

IFC មានការវិនិយោគដោយប្រយោលនៅក្នុង BFIs របស់កម្ពុជាតាមរយៈយានវិនិយោគ និងមូលនិធិដែលមានរចនាសម្ព័ន្ធ៖

- **MEF/GGSF** (គម្រោងលេខ 27827)៖ ត្រូវបានបង្កើតឡើងជាការឆ្លើយតបទៅនឹងវិបត្តិហិរញ្ញវត្ថុពិភពលោក MEF ត្រូវបានប្តូរឈ្មោះទៅជា Global Gender-Smart Fund (GGSF) នៅខែមករា ឆ្នាំ 2024។ គិតត្រឹមខែកញ្ញា ឆ្នាំ2025, IFC កាន់កាប់ភាគហ៊ុនចំនួន 23.1 ភាគរយ។ កាលពីមុន MEF/GGSF បានផ្តល់ប្រាក់កម្ចីដល់ប្រាសាក់, អិលអូអិលស៊ី, អម្រឹត, ធនាគារ HTB និងធនាគារស្ថាបនា ប៉ុន្តែបច្ចុប្បន្នមិនមានការវិនិយោគដែលនៅសេសសល់ក្នុងស្ថាប័នទាំងនេះទេ។
- **MIFA Debt Fund** (គម្រោងលេខ 31467)៖ ផ្តោតលើតំបន់អាស៊ី ដោយ IFC កាន់កាប់ភាគហ៊ុនចំនួន 8.71 ភាគរយ គិតត្រឹមខែកញ្ញា ឆ្នាំ 2025។ បច្ចុប្បន្ន MIFA មានការវិនិយោគជាប្រាក់កម្ចីចំនួន $1 លានដុល្លារអាមេរិកនៅក្នុង អិលអូអិលស៊ី ដែលនឹងត្រូវដល់កាលកំណត់សងនៅខែមិថុនា ឆ្នាំ 2026។
- **North Haven Thai Private Equity Fund** (គម្រោងលេខ 38609)៖ IFC បានវិនិយោគទឹកប្រាក់ចំនួន $15 លានដុល្លារអាមេរិកនៅក្នុងមូលនិធិនេះ ដែលបានកាន់កាប់ភាគហ៊ុនចំនួន 3.5 ភាគរយនៅក្នុងធនាគារអេស៊ីលីដា។ មូលនិធិនេះត្រូវបានបិទបញ្ចប់នៅខែមិថុនា ឆ្នាំ 2025។
- **Advans** ដែលជាក្រុមមីក្រូហិរញ្ញវត្ថុអន្តរជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ 2005។ IFC បានក្លាយជាម្ចាស់ភាគហ៊ុនស្ថាបនិកមួយរូប ជាមួយនឹងការវិនិយោគទុនចំនួន $12 លានដុល្លារអាមេរិក ដើម្បីជួយបង្កើត និងពង្រីកបណ្តាញមីក្រូហិរញ្ញវត្ថុ Advans នៅតំបន់អាហ្វ្រិក អាស៊ី និងមជ្ឈិមបូព៌ា។ នៅក្នុងប្រទេសកម្ពុជា IFC និង Advans គឺជាម្ចាស់ភាគហ៊ុនអម្រឹត។

អ្នកគ្រប់គ្រងមូលនិធិប្រតិបត្តិការដោយឯករាជ្យ ដោយអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងគោលការណ៍ ESG ទៅលើការវិនិយោគនានា។ LOLC Cambodia និងធនាគារស្ថាបនាបានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ និងកិច្ចការពារអតិថិជន ដែលត្រូវបានបញ្ជាក់តាមរយៈការទទួលបានរបស់ពួកគេនូវវិញ្ញាបនបត្រការពារអតិថិជនកម្រិតមាស (Gold-level Client Protection Certification)។

**LOLC Cambodia** ត្រូវបានផ្តល់វិញ្ញាបនបត្រគោលការណ៍ការពារអតិថិជនកម្រិតមាស (មានសុពលភាពពីឆ្នាំ 2025–2028) ដោយស្ថាប័ន M-CRIL ដែលទទួលស្គាល់ពីភាពល្អប្រសើររបស់ក្រុមហ៊ុនក្នុងការរចនាផលិតផលប្រកបដោយតម្លាភាព ការបង្ការបំណុលលើសលប់ ការប្រព្រឹត្តដោយយុត្តិធម៌ ឯកជនភាព និងការកំណត់តម្លៃច្បាស់លាស់។ ការបណ្តុះបណ្តាលស្តីពីការផ្តល់ប្រាក់កម្ចីដោយការទទួលខុសត្រូវ និងកិច្ចការពារអតិថិជនត្រូវបានបញ្ចូលទៅក្នុងកម្មវិធីតម្រង់ទិសបុគ្គលិកថ្មី និងកម្មវិធីរំលឹកចំណេះដឹងប្រចាំឆ្នាំរបស់ LOLC ដោយមានមន្ត្រីឥណទានរាប់រយនាក់ទទួលបានការបញ្ជាក់លើស្តង់ដាទាំងនេះចាប់តាំងពីឆ្នាំ 2022 មក។ ពាក្យបណ្តឹង និងមតិកែលម្អអាចត្រូវបានដាក់ជូនតាមរយៈបណ្តាញជាច្រើន—រួមមានខ្សែទូរសព្ទទាន់ហេតុការណ៍ ការហៅទូរសព្ទផ្ទាល់ ការអញ្ជើញទៅកាន់សាខាផ្ទាល់ ប្រអប់មតិយោបល់ គេហទំព័រ អ៊ីមែល និងស្ថាប័នខាងក្រៅដូចជា FCC ជាដើម។ ពាក្យបណ្តឹងត្រូវបានតាមដាន ចាត់ថ្នាក់ និងដោះស្រាយជាប្រព័ន្ធ ស្របតាមពិធីសារដែលមានរចនាសម្ព័ន្ធ ដោយមានការត្រួតពិនិត្យយ៉ាងជិតដល់លើការអនុវត្ត និងការរាយការណ៍ ដើម្បីបង្ហាញពីតម្លាភាព និងការកែលម្អជាបន្តបន្ទាប់។

**ធនាគារស្ថាបនា** ទទួលបានវិញ្ញាបនបត្រគោលការណ៍ការពារអតិថិជនកម្រិតមាសពីស្ថាប័ន M-CRIL (មានសុពលភាពពីខែមីនា ឆ្នាំ 2025–ខែមីនា ឆ្នាំ 2028) បន្ទាប់ពីឆ្លងកាត់ដំណើរការវាយតម្លៃយ៉ាងហ្មត់ចត់។ ធនាគារធ្វើការបណ្តុះបណ្តាលជាប្រចាំស្តីពីការផ្តល់ប្រាក់កម្ចីដោយការទទួលខុសត្រូវ និងកិច្ចការពារអតិថិជនដល់បុគ្គលិកពាក់ព័ន្ធទាំងអស់ ទាំងក្នុងអំឡុងពេលតម្រង់ទិសបុគ្គលិកថ្មី និងតាមរយៈកម្មវិធីរំលឹកចំណេះដឹង។ អតិថិជនអាចដាក់ពាក្យបណ្តឹងតាមរយៈបណ្តាញជាច្រើនរួមមាន អ៊ីមែល ទូរសព្ទ បណ្តាញសង្គម ទម្រង់បែបបទអនឡាញ ការអញ្ជើញទៅកាន់សាខាផ្ទាល់ ឬតាមរយៈ FCC។ ផ្នែកថែទាំអតិថិជនរបស់ធនាគារស្ថាបនាដំណើរការ 24/7 ដែលធានាថាពាក្យបណ្តឹងត្រូវបានកត់ត្រា ចាត់ថ្នាក់តាមកម្រិតធ្ងន់ធ្ងរ និងប្រភេទនៃបញ្ហា ហើយត្រូវបានដោះស្រាយតាមរយៈពិធីសារបញ្ជូនទៅថ្នាក់លើយ៉ាងច្បាស់លាស់។ បញ្ហាទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ត្រូវបានដោះស្រាយតាមរយៈដំណើរការដាច់ដោយឡែកជាមួយនឹងពេលវេលាកំណត់យ៉ាងតឹងរឹង ហើយពាក្យបណ្តឹងសំខាន់ៗដែលមិនទាន់ត្រូវបានដោះស្រាយ នឹងត្រូវបញ្ជូនទៅថ្នាក់គ្រប់គ្រងជាន់ខ្ពស់។ ប្រព័ន្ធដ៏រឹងមាំរបស់ធនាគារធានាបាននូវការរាយការណ៍ជាទៀងទាត់ទៅថ្នាក់គ្រប់គ្រង និងស្ថាប័ននិយ័តករ ហើយគោលនយោបាយមិនអត់ឱនចំពោះការប្រព្រឹត្តខុសរបស់ពួកគេកាន់តែពង្រឹងការប្តេជ្ញាចិត្តរបស់ពួកគេចំពោះស្តង់ដាសីលធម៌ និងការកែលម្អជាបន្តបន្ទាប់។

## តារាង និងទិន្នន័យ៖ ទិដ្ឋភាពទូទៅនៃការវិនិយោគ

**តារាងទី 1៖ គម្រោងរបស់ IFC ជាមួយធនាគារអេស៊ីលីដាដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងដំបូង**

| លេខគម្រោង | ឈ្មោះគម្រោង | ឆ្នាំដែលបានសន្យាផ្តល់ជូន | ទឹកប្រាក់ដំបូងដែលបានសន្យាផ្តល់ជូន | | | ស្ថានភាពគិតត្រឹមថ្ងៃទី 7 ខែមេសា ឆ្នាំ 2022 | ស្ថានភាពគិតត្រឹមរបាយការណ៍គ្រប់គ្រងនេះ | ចំណាត់ថ្នាក់ E&S |
|---|---|---|---|---|---|---|---|---|
| | | | ការវិនិយោគគណនីផ្ទាល់ខ្លួនរបស់ IFC | ការកៀងគរ IFC | សរុប | | | |
| #30607 | ACLEDA Sub- Debt | 2011 | 6 | - | 6 | បិទ | បិទ | FI |
| #32642 | CF ACLEDA Sub- Debt 2 | 2012 | 40 | - | 40 | បិទ | បិទ | FI-2 |
| #34386 | ACLEDA Loan 2013 | 2013 | 50 | - | 50 | បិទ | បិទ | FI-2 |
| #35963 | ACLEDA Group Loan | 2015 | 40 | 70 | 110 | បិទ | បិទ | FI-2 |
| #37594 | ACLEDA Gender Loan | 2016 | 100 | 130 | 230 | បិទ | បិទ | FI-2 |
| #42480 | ACLEDA Sub- Debt | 2019 | 60 | 50 | 110 | ដំណើរការ | ដំណើរការ | FI-2 |
| #44882 | ACLEDA Senior 2020 | 2021 | 100 | 69 | 169 | ដំណើរការ | ដំណើរការ | FI-2 |

FI – អន្តរការីហិរញ្ញវត្ថុ

**តារាងទី 2៖ គម្រោងរបស់ IFC ជាមួយអម្រឹតដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងដំបូង**

| លេខគម្រោង | ឈ្មោះគម្រោង | ឆ្នាំដែលបានសន្យាផ្តល់ជូន | ទឹកប្រាក់ដំបូងដែលបានសន្យាផ្តល់ជូន | | | ស្ថានភាពគិតត្រឹមថ្ងៃទី 7 ខែមេសា ឆ្នាំ 2022 | ស្ថានភាពគិតត្រឹមរបាយការណ៍គ្រប់គ្រងនេះ | ចំណាត់ថ្នាក់ E&S |
|---|---|---|---|---|---|---|---|---|
| | | | ការវិនិយោគគណនីផ្ទាល់ខ្លួនរបស់ IFC | ការកៀងគរ IFC | សរុប | | | |
| #34748 | AMRET Equity Project | 2014 | 17.5 | - | 17.5 | ដំណើរការ | ដំណើរការ | FI-2 |
| #37505 | AMRET AB Loan | 2016 | 7 | 53 | 60 | បិទ | បិទ | FI-2 |
| #601602 | AMRET Transform | 2016-2017 | គម្រោងប្រឹក្សាយោបល់ | | | បិទ | បិទ | |
| #41294 | AMRET Senior 18 | 2018 | 2.5 | 15 | 17.5 | ដំណើរការ | បិទ | FI-2 |
| #44231 | WCS COVID Tranche 1 | 2020 | 12.5 | 12.5 | 25 | ដំណើរការ | បិទ | FI-3 |
| #44231 | WCS COVID Tranche 2 | 2021 | 12.5 | - | 12.5 | ដំណើរការ | បិទ | FI-3 |

AB – កម្ចីប្រភេទ A និង B របស់ IFC; WCS – ដំណោះស្រាយដើមទុនបង្វិល; FI – អន្តរការីហិរញ្ញវត្ថុ

**តារាងទី 3៖ គម្រោងរបស់ IFC ជាមួយធនាគារ HTB ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងដំបូង**

| លេខគម្រោង | ឈ្មោះគម្រោង | ឆ្នាំដែលបានសន្យាផ្តល់ជូន | ទឹកប្រាក់ដំបូងដែលបានសន្យាផ្តល់ជូន | | | ស្ថានភាពគិតត្រឹមថ្ងៃទី 7 ខែមេសា ឆ្នាំ 2022 | ស្ថានភាពគិតត្រឹមរបាយការណ៍គ្រប់គ្រងនេះ | ចំណាត់ថ្នាក់ E &S |
|---|---|---|---|---|---|---|---|---|
| | | | ការវិនិយោគគណនីផ្ទាល់ខ្លួនរបស់ IFC | ការកៀងគរ IFC | សរុប | | | |
| #36242 | HKL Senior Loan | 2015 | 10 | - | 10 | បិទ | បិទ | FI-3 |
| #38239 | HKL AB Loan | 2016 | 20 | 30 | 50 | បិទ | បិទ | FI-3 |
| #39167 | HKL Senior 2017 | 2017 | 5 | - | 5 | ដំណើរការ | បិទ | FI-3 |
| #41223 | DCM HKL LCY Bond | 2018 | 20 | - | 20 | បិទ | បិទ | FI-3 |
| #44211 | WCS Covid HKL | 2020 | 25 | - | 25 | ដំណើរការ | បិទ | FI-3 |
| #44742 | HTB Sub-Debt | 2021 | 10 | 30 | 40 | ដំណើរការ | ដំណើរការ | FI-2 |
| #45535 | Base of Pyramid (BOP) HTB Senior | 2021 | 10 | 60 | 70 | ដំណើរការ | បិទ | FI-2 |

AB – កម្ចីប្រភេទ A និង B របស់ IFC; BOP –មូលដ្ឋាននៃពីរ៉ាមីតសេដ្ឋកិច្ច; DCM – ទីផ្សារមូលធនបំណុល; WCS - ដំណោះស្រាយដើមទុនបង្វិល; FI – អន្តរការីហិរញ្ញវត្ថុ

**តារាងទី 4៖ គម្រោងរបស់ IFC ជាមួយធនាគារ PRASAC ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងដំបូង**

| លេខគម្រោង | ឈ្មោះគម្រោង | ឆ្នាំដែលបានសន្យាផ្តល់ជូន | ទឹកប្រាក់ដំបូងដែលបានសន្យាផ្តល់ជូន | | | ស្ថានភាពគិតត្រឹមថ្ងៃទី 7 ខែមេសា ឆ្នាំ 2022 | ស្ថានភាពគិតត្រឹមរបាយការណ៍គ្រប់គ្រងនេះ | ចំណាត់ថ្នាក់ E &S |
|---|---|---|---|---|---|---|---|---|
| | | | ការវិនិយោគគណនីផ្ទាល់ខ្លួនរបស់ IFC | ការកៀងគរ IFC | សរុប | | | |
| #36280 | PRASAC Sr Loan 3 | 2015 | 10 | - | 10 | បិទ | បិទ | FI-2 |
| #38235 | PRASAC AB Loan | 2016 | 20 | 70 | 90 | បិទ | បិទ | FI-2 |

AB - កម្ចីប្រភេទ A និង B របស់ IFC; FI – អន្តរការីហិរញ្ញវត្ថុ

**តារាងទី 5៖ គម្រោងរបស់ IFC ជាមួយ MEF, MIFA និង North Haven ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្តឹងដំបូង**

| លេខគម្រោង | ឈ្មោះគម្រោង | ឈ្មោះមូលនិធិ | ឆ្នាំដែលបានសន្យាផ្តល់ជូន | ទឹកប្រាក់ដំបូងដែលបានសន្យាផ្តល់ជូន | ស្ថានភាពគិតត្រឹមខែកញ្ញា ឆ្នាំ 2025 | ស្ថានភាពគិតត្រឹមរបាយការណ៍គ្រប់គ្រងនេះ |
|---|---|---|---|---|---|---|
| #27827 | IFC – MLF | MEF | 2009 | 150 | ដំណើរការ | ដំណើរការ |
| #31467 | MIFA Debt Fund | MIFA Debt Fund | 2012 | 16.75 | ដំណើរការ | ដំណើរការ |
| #38609 | North Haven Fund | North Haven Thai Private Equity Fund L.P. | 2018 | 15 | ដំណើរការ | ដំណើរការ |

**តារាងទី 6៖ ការវិនិយោគរបស់ MEF លើ BFIs របស់កម្ពុជា**

| MEF (គម្រោងលេខ 27827) | ប្រភេទផលិតផល | ទឹកប្រាក់ដែលបានសន្យាផ្តល់ជូនលាន US$ | ការវិនិយោគមិនទាន់សងគិតត្រឹមខែកញ្ញា ឆ្នាំ 2025 លាន US$ |
|---|---|---|---|
| LOLC កម្ពុជា | ប្រាក់កម្ចីជាន់ខ្ពស់ | 14.2 | សូន្យ |
| Amret | ប្រាក់កម្ចីជាន់ខ្ពស់ | 13.8 | សូន្យ |
| PRASAC | ប្រាក់កម្ចីជាន់ខ្ពស់ | 7.8 | សូន្យ |
| HTB | ប្រាក់កម្ចីជាន់ខ្ពស់ | 5.5 | សូន្យ |
| **ការវិនិយោគសរុបរបស់ MEF លើ BFIs កម្ពុជា** | | **41.3** | **-** |

**តារាងទី 7៖ ការវិនិយោគរបស់ MIFA លើ BFIs របស់កម្ពុជា**

| MIFA (គម្រោងលេខ 31467) | ប្រភេទផលិតផល | ទឹកប្រាក់ដែលបានសន្យាផ្តល់ជូនលាន US$ | ការវិនិយោគមិនទាន់សងគិតត្រឹមខែកញ្ញា ឆ្នាំ 2025 លាន US$ |
|---|---|---|---|
| ធនាគារស្ថាបនា ភីអិលស៊ី | ប្រាក់កម្ចីបន្ទាប់បន្សំ | 4.0 | សូន្យ |
| Amret | ប្រាក់កម្ចីជាន់ខ្ពស់ | 2.5 | សូន្យ |
| Amret | ប្រាក់កម្ចីជាន់ខ្ពស់ | 3.0 | សូន្យ |
| LOLC កម្ពុជា | ប្រាក់កម្ចីបន្ទាប់បន្សំ | 5.0 | សូន្យ |
| LOLC កម្ពុជា | ប្រាក់កម្ចីបន្ទាប់បន្សំ | 5.0 | 1.0 |
| **ការវិនិយោគសរុបរបស់ MIFA លើ BFIs កម្ពុជា** | | **19.5** | **1.0** |

**តារាងទី 8៖ ការវិនិយោគរបស់ North Haven លើ BFIs កម្ពុជា**

| North Haven (គម្រោងលេខ 38609) | ប្រភេទផលិតផល | ទឹកប្រាក់ដែលបានសន្យាផ្តល់ជូន លានដុល្លារ US$ | កម្ចីដែលមិនទាន់ទូទាត់សង លានដុល្លារ US$ |
|---|---|---|---|
| ធនាគារអេស៊ីលីដា | ភាគហ៊ុន 3.5% ដែលបានសន្យាវិនិយោគនៅ ខែមេសា ឆ្នាំ 2022 | 44.8 | 44.8 |

**សេចក្តីថ្លែងការណ៍បដិសេធ**

របាយការណ៍គ្រប់គ្រងរបស់ IFC នេះ ត្រូវបានផ្តល់ជាការឆ្លើយតបទៅនឹងរបាយការណ៍ស៊ើបអង្កេតរបស់ការិយាល័យទីប្រឹក្សាអនុលោមភាព (CAO) ដែលទាក់ទងនឹងពាក្យបណ្តឹងអំពីការចោទប្រកាន់ថា IFC មិនមានអនុលោមភាពតាមគោលនយោបាយរបស់ខ្លួនស្តីពីចិរភាពបរិស្ថាន និងសង្គម នៅក្នុងគម្រោងដែលទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ ឬការវិនិយោគពី IFC។

CAO គ្រប់គ្រងយន្តការគណនេយ្យភាពរបស់ IFC ដើម្បីដោះស្រាយពាក្យបណ្តឹងពីសំណាក់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយគម្រោងដែលទទួលបានការគាំទ្រពី IFC។ ដូចដែលបានកត់សម្គាល់ក្នុងកថាខណ្ឌទី 9 នៃគោលនយោបាយយន្តការគណនេយ្យភាពឯករាជ្យ (CAO) របស់ IFC/MIGA នោះ CAO មិនមានសិទ្ធិអំណាចពាក់ព័ន្ធនឹងដំណើរការតុលាការឡើយ។ CAO មិនមែនជាយន្តការអនុវត្តតាមផ្លូវច្បាប់ ឬប្រព័ន្ធតុលាការឡើយ ហើយ CAO ក៏មិនមែនជាស្ថាប័នជំនួសឱ្យតុលាការ ឬដំណើរការនិយ័តកម្មដែរ ហើយការវិភាគ ការសន្និដ្ឋាន និងរបាយការណ៍របស់ CAO មិនត្រូវបានកំណត់ ឬរៀបចំឡើងដើម្បីប្រើប្រាស់ក្នុងដំណើរការតុលាការ ឬដំណើរការនិយ័តកម្ម ឬក្នុងគោលបំណងកំណត់កំហុស ឬការទទួលខុសត្រូវតាមផ្លូវច្បាប់នោះទេ។

គ្មានខ្លឹមសារណាមួយដែលមានក្នុងរបាយការណ៍ស៊ើបអង្កេតរបស់ CAO ឬនៅក្នុងរបាយការណ៍គ្រប់គ្រងរបស់ IFC (1) បង្កើតកាតព្វកិច្ចតាមផ្លូវច្បាប់ណាមួយ (2) អះអាង ឬលះបង់គោលជំហរផ្លូវច្បាប់ណាមួយ (3) កំណត់ការទទួលខុសត្រូវតាមផ្លូវច្បាប់ ការទទួលខុសត្រូវលើសំណង ឬកំហុសឆ្គងណាមួយ (4) បង្កើតជាការទទួលស្គាល់ ឬការព្រមទទួលនូវកាលៈទេសៈជាក់ស្តែង ឬភស្តុតាងនៃកំហុសឆ្គង ឬការប្រព្រឹត្តខុសណាមួយ ឬ (5) បង្កើតជាការលះបង់នូវសិទ្ធិ អភ័យឯកសិទ្ធិ ឬការលើកលែងណាមួយរបស់ IFC ក្រោមលក្ខន្តិកៈនៃកិច្ចព្រមព្រៀង អនុសញ្ញាអន្តរជាតិ ឬច្បាប់ដែលពាក់ព័ន្ធផ្សេងទៀតណាមួយឡើយ។ IFC រក្សាសិទ្ធិគ្រប់យ៉ាងដោយជាក់លាក់។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងសមហេតុផលដើម្បីកំណត់ថាព័ត៌មានដែលមានក្នុងរបាយការណ៍ទាំងនេះមានភាពត្រឹមត្រូវក៏ដោយ ក៏គ្មានការអះអាង ឬការធានាណាមួយត្រូវបានផ្តល់ឱ្យទាក់ទងនឹងភាពត្រឹមត្រូវ ឬភាពពេញលេញនៃព័ត៌មាននោះឡើយ។ ក្នុងការរៀបចំរបាយការណ៍គ្រប់គ្រងនេះ IFC មិនមានចេតនាបង្កើត ទទួលស្គាល់ ឬទទួលយកកាតព្វកិច្ច ឬករណីយកិច្ចតាមផ្លូវច្បាប់ណាមួយឡើយ ហើយក៏មិនមានបំណងបញ្ជាក់អត្តសញ្ញាណ ឬទទួលស្គាល់ការចោទប្រកាន់ណាមួយជុំវិញការរំលោភលើកាតព្វកិច្ច ឬករណីយកិច្ចតាមផ្លូវច្បាប់ណាមួយនោះដែរ។ គ្មានផ្នែកណាមួយនៃរបាយការណ៍ស៊ើបអង្កេតរបស់ CAO ឬរបាយការណ៍គ្រប់គ្រងរបស់ IFC អាចត្រូវបានប្រើប្រាស់ ឬយោងនៅក្នុងដំណើរការតុលាការ ដំណើរការអាជ្ញាកណ្តាល ដំណើរការនិយ័តកម្ម ឬដំណើរការផ្សេងៗទៀតដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរយ៉ាងច្បាស់លាស់ពី IFC ឡើយ។